# ការត្រួតពិនិត្យមីន

## កម្ពុជា ២០០៥



រៀបចំដោយៈ ក្រុមយុទ្ធនាការលុបបំបាត់មីនកម្ពុជា

របាយការណ៍ប្រចាំឆ្នាំលើកទី៧ (២០០៤-២០០៥)

## មាតិកា ទំព័រ


គោលនយោបាយលុបបំបាត់មីន (Mine Ban Policy)……………………………….................…02

ការផលិត ការដឹកជញ្ជូននិងការប្រើប្រាស់មីន (Production, Transfer and Use) .....................05

ការស្តុកទុកនិងការបំផ្លាញឃ្លាំងស្តុកមីន (Stockpiling and Destruction)……….........................05

បញ្ហាមីននិងអាវុធជាតិផ្ទុះដែលសេសសល់ពីសង្គ្រាម ( Landmine & ERW Problem) …….....08

កម្មវិធីសកម្មភាពកំចាត់មីន (Mine Action Programme).......................................…..….........10

ការស្រាវជ្រាវនិងការប៉ាន់ប្រមាណ (Survey and Assessment) ……………….….…...........15

ការបោសសំអាតមីន និង អាវុធជាតិផ្ទុះនៅសល់ពីសង្គ្រាម (Mine and ERW Clearance) ….17

ការអប់រំអំពីគ្រោះថ្នាក់មីន (Mine Risk Education) ………………………………......……25

មូលនិធិនិងជំនួយសំរាប់សកម្មភាពមីន (Funding and Assistance) …....……..............................31

អ្នករងគ្រោះថ្នាក់ដោយសាមីននិងគ្រាប់មិនទាន់ផ្ទុះ (Landmine and UXO Casualties)….........35

ការឧបត្ថម្ភអ្នកនៅរស់រានជីវិតពីគ្រោះថ្នាក់មីន (Survivor Assistance) …....…………........……37

ការអនុវត្តនិងគោលនយោបាយជនពិការ (Disability policy and Practice)…..............…..........48



**ក្រុមស្រាវជ្រាវ:** បងស្រី **ឌេនីស ឆូឥឡិន**

លោក **នី ញ៉ី**

**ដោយ** មានការចូលរួមគាំទ្រពីសមាជិកដែលមានការចាប់អារម្មណ៍ចំពោះយុទ្ធនាការលុបបំបាត់មីនយ៉ាងច្រើន រួមទាំងអ្នកដែលរងគ្រោះដោយសារមីនសំខាន់ៗ និង ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដែលទទួលរងគ្រោះនិងមានផលប៉ះពាល់ដោយសារមីន ។

ក្រុមយុទ្ធនាការលុបបំបាត់មីនកម្ពុជា: ផ្ទះលេខ៩៦ ផ្លូវ ៥៩២ បឹងកក់២ ទួលគោក ភ្នំពេញ

ទូរស័ព្ទ: ០២៣ ៨៨០ ៩៥៥ / ១៣៩

ទូរសារ: ០២៣ ៨៨០ ១៩០


**ប្រទេសកម្ពុជា**

**០១ តុលា ២០០៥**

***ព្រឹត្តិការណ៍សំខាន់ៗចាប់តាំងពីខែតុលាឆ្នាំ២០០៤:*** ចាប់ពីខែ កញ្ញា ឆ្នាំ២០០៣ រហូតដល់ខែធ្នូ ឆ្នាំ២០០៤ ប្រទេសកម្ពុជាបានធ្វើជាសហប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីការបោសសំអាតមីន ការអប់រំស្តីពីគ្រោះថ្នាក់ដោយសារមីន និងបច្ចេកវិទ្យាក្នុងការកំចាត់មីន។ ឧបនាយករដ្ឋមន្ត្រីរបស់ប្រទេសកម្ពុជា បានចូលរួមក្នុងសន្និសីទបូកសរុបការងារមីនលើកទី១ (The First Review Conference) និង ទូតតំណាងយុវជននៃយុទ្ធនាការលុបបំបាត់មីនអន្តរជាតិ (ICBL Youth Ambassador) សុង កុសល បានថ្លែងសុន្ទរកថា ក្នុងកម្មវិធីបើកសន្និសីទនេះ។ ការផ្សព្វផ្សាយ ដ៏សំខាន់នូវរបាយការណ៍ត្រួតពិនិត្យមីនឆ្នាំ២០០៤ (The Landmine Monitor Report 2004) ត្រូវបានគេរៀបចំប្រារព្ធធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ដោយមានការយាងចូលរួមពីព្រះមហាក្សត្រផងដែរ។ ប្រទេសកម្ពុជានាពេលថ្មីៗនេះ បានរកឃើញនិងកំទេចចោលគ្រាប់មីនប្រឆាំងមនុស្សដែលគេរក្សាទុកចំនួន ១៥៤៤៦ គ្រាប់នៅឆ្នាំ ២០០៤ ជាចំនួនដែលច្រើនជាងឆ្នាំណាៗទាំងអស់ ចាប់តាំងពីមានកម្មវិធីកំទេចចោលគ្រាប់មីនបាន ត្រូវរៀបចំឡើងចប់សព្វគ្រប់មក។ នៅខែ មិថុនា ឆ្នាំ ២០០៥ ប្រទេសកម្ពុជាបានធ្វើរបាយការណ៍ជូនទៅបណ្តាភាគីរដ្ឋជាសមាជិក ដែលស្នើរសុំអោយធ្វើការបន្តដល់រយៈពេលកំណត់លើមាត្រាទី៥ (ខែមិនាឆ្នាំ២០១០) បើមិនដូចនេះទេបណ្តាម្ចាស់ជំនួយនឹងមិនបង្កើនផ្តល់មូលនិធិឡើយ។ ជំនួយអន្តរជាតិទាំងឡាយសំរាប់សកម្មភាពកំចាត់មីននៅកម្ពុជា បានកើនឡើងយ៉ាងសន្ធឹកសន្ធាប់នៅ ឆ្នាំ២០០៤ គឺឡើងដល់ជិត៤២លានដុល្លា។ ប្រទេសកម្ពុជាបាន រាយការណ៍ថាទឹកប្រាក់ប្រហែលជិត៣០លានដុល្លា ត្រូវបានចំណាយទៅលើសកម្មភាពកំចាត់មីននៅឆ្នាំ២០០៤។ ការវាយតំលៃលើសកម្មភាពកំចាត់មីន បានអះអាងថាមានតែមួយភាគដប់ប៉ុណ្ណោះនៃតំបន់ ដែលពីមុនត្រូវគេបញ្ជាក់ថា មានបញ្ហាដោយសារមីន ដែលបានទាមទារអោយធ្វើការបោសសំអាត។ ក្រុមប្រតិបត្តិករ HALO Trust បានបង្ហាញពីវិធីសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ភ្លាមៗដោយសារមីន ដើម្បីធ្វើអោយតំបន់ដែលមានគ្រោះថ្នាក់តិចតួចដោយសារគ្រាប់មីនអោយប្រជាជនស៊ីវិលប្រើប្រាស់។ ការវាយតំលៃនេះបានផ្តល់អនុសាសន៍អោយធ្វើការកំណត់សារជាថ្មីនូវតួនាទីរបស់អាជ្ញាធរមីន។ ការធ្វើអោយក្លាយទៅជាអាទិភាពនូវការបោសសំអាតមីន គឺ ត្រូវបានគេធ្វើតាមលក្ខណៈជាវិមជ្ឈកាដើម្បីបង្កើនប្រសិទ្ធិភាព និងដើម្បីរួមបញ្ចូលគ្នានូវសកម្មភាពកំចាត់មីន និង ការអភិវឌ្ឍន៍។ នៅកំឡុងឆ្នាំ ២០០៤ ក្រុមប្រតិបត្តិករដោះមីន ៤ក្រុម បានធ្វើការបោសសំអាតមីនលើផ្ទៃដីជាង ៣២គីឡូម៉ែត្រការ៉េ តិចជាងនៅឆ្នាំ ២០០៣។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៥ ស្តង់ដារជាតិប្រាំ ដើម្បីធ្វើការដោះមីនត្រូវបានអនុម័តយល់ព្រមដោយនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៃប្រទេសកម្ពុជា។ យុទ្ធសាស្ត្រអប់រំ ស្តីពីគ្រោះថ្នាក់មីនសំរាប់រយៈពេលពី ២០០៥-២០០៩ ត្រូវបានយល់ព្រមដោយផ្តោតការយកចិត្តទុកដាក់ទៅលើសម្ព័ន្ធការ និងសមាហរណកម្មសហគមន៍ ជាមួយនឹងសកម្មភាពកំចាត់មីនដទៃទៀត។ មានចំនួនអ្នកស្លាប់ដោយ សារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះកើនឡើងយ៉ាងខ្លាំង ដែលត្រូវបានរាយការណ៍បើប្រៀបធៀបទៅនឹង ឆ្នាំ២០០៣។ អ្នកស្លាប់ភាគច្រើនគឺ

ដោយសារគ្រាប់មិនទាន់ផ្ទុះ ជាចំនួនដែលច្រើនជាងពេលកន្លងមក។ នៅឯសន្និសីទបូកសរុបការងារមីនលើកទី១ (The First Review Conference) ប្រទេសកម្ពុជាត្រូវគេកំណត់ថា ជាភាគីរដ្ឋមួយក្នុងចំនោមភាគីរដ្ឋទាំង ២៤ ដែលមានចំនួនអ្នករស់រានមានជីវិតពីគ្រាប់មីនដ៏ច្រើន និងជាប្រទេសដែលមានសេចក្តីត្រូវការ និងទទួលខុសត្រូវធំបំផុតចំពោះការផ្តល់ជំនួយដល់អ្នករងគ្រោះទាំងនោះអោយបានគ្រប់គ្រាន់។ នៅខែ មិថុនា ឆ្នាំ ២០០៥ ជាផ្នែកមួយនៃការប្តេជ្ញារបស់ខ្លួនចំពោះផែនការសកម្មភាពរបស់ក្រុង ណៃរ៉ូប៊ី (The Nairobi Action Plan) ប្រទេសកម្ពុជា បានបង្ហាញទិសដៅរបស់ខ្លួនមួយចំនួនសំរាប់រយៈពេល ២០០៥-២០០៩ ដើម្បីដោះស្រាយនូវតំរូវការរបស់អ្នករស់រានមានជីវិតពីគ្រាប់មីន។

## គោលនយោបាយលុបបំបាត់មីន

ព្រះរាជាណាចក្រកម្ពុជា បានចុះកិច្ចព្រមព្រៀងលើសន្ធិសញ្ញាហាមប្រើប្រាស់គ្រាប់មីននៅថ្ងៃ ០៣ ខែធ្នូ ឆ្នាំ ១៩៩៧ ដោយបានធ្វើសច្ចាប័នយល់ព្រមនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ១៩៩៩ ហើយសន្ធិសញ្ញានេះបានចូលជាធរមាននៅថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០០។ ច្បាប់អនុវត្តក្នុងស្រុក មានច្បាប់ហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស ត្រូវបានដាក់ចូលជាធរមាននៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩។[1]

រដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលនានា បានបន្តការគាំទ្រយ៉ាងសកម្មដល់សន្ធិសញ្ញាហាមប្រាមការប្រើប្រាស់មីននេះ១ឆ្នាំពេញក្នុងឆ្នាំ២០០៤ និងឆមាសទី១ ឆ្នាំ២០០៥។ លោកឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជាទៅចូលរួមក្នុងសន្និសីទបូកសរុបការងារមីនលើកទី១ (First Review Conference) នេះដែលរៀបចំឡើងនៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា នាខែវិច្ឆិកា និងធ្នូ ឆ្នាំ២០០៤។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា "ទិសដៅរបស់រាជរដ្ឋាភិបាល គឺការច្របាច់បញ្ចូលគ្នានូវសកម្មភាពកំចាត់មីនជាមួយផែនការអភិវឌ្ឍន៍ និងការធ្វើសមាហរណកម្មមនុស្សដែលរួចជីវិតពីគ្រាប់មីនអោយចូលរួមទៅក្នុងសង្គមវិញ " និងការធ្វើការកត់សំគាល់ថា " ការបោសសំអាតមីនគឺមិនគ្រាន់តែជាបញ្ហាសន្តិសុខប៉ុណ្ណោះទេ តែគឺជាបញ្ហាដែលប៉ះពាល់ទៅដល់ការអភិវឌ្ឍន៍ និង សេដ្ឋកិច្ចជាតិផងដែរ ជាពិសេសពាក់ព័ន្ធនឹងការផ្តល់ជីជីមានសុវត្ថិភាពចំពោះក្រុមគ្រួសារកសិករក្រីក្រនៅតាមតំបន់ដាច់ស្រយាល និង តំបន់ជនបទទៀតផង។"[2] ប្រទេសកម្ពុជាបានធ្វើជាអនុប្រធានមួយក្នុងចំណោមអនុប្រធានទាំង ៩ នៅសន្និសីទបូកសរុបការងារមីននេះ។

យុទ្ធនាការលប់បំបាត់មីនកម្ពុជា (CCBL) បានចូលរួមយ៉ាងសកម្មនៅក្នុងសន្និសីទលើកទី១នេះ និងក្នុងព្រឹត្តិការណ៍សំខាន់ៗជាច្រើនរបស់ភាគីខ្លួន។ ទូតយុវជនរបស់យុទ្ធនាការលប់បំបាត់មីនអន្តរជាតិ (ICBL)

---

[1] The law bans the production, use, possession, transfer, trade, sale, import and export of antipersonnel mines. It provides for criminal penalties, including fines and imprisonment for offences committed by civilians or members of the police and the armed forces. It also provides for the destruction of mine stockpiles.

[2] Statement by Deputy Prime Minister Sok An, First Review Conference to the Mine Ban Treaty, Nairobi, 2 December 2004.

**សុង កុសល** ដែលជាអ្នករស់រានជីវិតពីគ្រោះថ្នាក់មីននិងជាជនជាតិកម្ពុជាមួយរូបមានអាយុ ២០ឆ្នាំ បានថ្លែងមតិដ៏គួរក្កុកក្តួលរំជួលចិត្តនៅក្នុងពិធីបើកសន្និសីទនេះ ដោយនាងធ្វើការពិពណ៌នាអំពីការរីកចំរើនដែលសំរេចបានក្នុងរយៈពេល ៥ឆ្នាំនេះ ចាប់តាំងពីមានសន្ធិសញ្ញាលុបបំបាត់មីនបានក្លាយជាច្បាប់អន្តរជាតិមកថា "ជាដំណឹងល្អ" ប៉ុន្តែបានបន្ថែមថា "នៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់"នៅឡើយ។ នាងបានអំពាវនាវអោយរដ្ឋាភិបាលធ្វើអ្វីៗអោយបានច្រើនជាងនេះតទៅទៀត ដោយនាងបញ្ជាក់ថា "មានសហគមន៏រងគ្រោះថ្នាក់ដោយសារមីនជាច្រើនដែលគេទើបបោសសំអាតថ្មីៗនេះ នៅតែមិនទាន់មានផ្ទះជ្រកកោន មិនទាន់មានទឹកប្រើប្រាស់និងបរិភោគ មិនទាន់មានម្ហូបអាហារគ្រប់គ្រាន់ មិនទាន់មានដីដែលមានសុវត្ថិភាពសំរាប់គេធ្វើកសិកម្ម មិនទាន់មានសាលារៀននិងមន្ទីរពេទ្យ ប្រការនេះនៅមិនទាន់ល្អនៅឡើយ។ នៅក្នុងប្រទេសខ្លះ អ្នករងគ្រោះថ្នាក់មីន នៅតែមានជាបន្តបន្ទាប់ដោយសារមីនចាស់ៗ។ បញ្ហាទាំងនេះមិនយុត្តិធម៌ទេ"។ [3] លោក **ទន់ ចាន់ណារ៉េត** ទូតជនពិការនៃក្រុមយុទ្ធនាការលុបបំបាត់មីន អន្តរជាតិ ( ICBL) ដែលជាអ្នករស់រានជីវិតពីគ្រោះថ្នាក់មីនជនជាតិកម្ពុជាដែរក៏បានមានប្រសាសន៏ដូចគ្នាដែរនៅក្នុងពិធីមួយធ្វើនៅក្នុងវិហារមួយដែលចំរុះដោយសាសនាជាច្រើន និងបានចូលរួមនៅក្នុងការរត់ប្រណាំងម៉ារ៉ាតុន និងក្នុងព្រឹត្តិការណ៏ផ្សេងទៀតជាច្រើន។ កញ្ញា **ជិន សុផល្លី** ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំស្តីពីយុវជនក្នុងយុទ្ធនាការលុបបំបាត់មីនពិភពលោក។

ចាប់តាំងពីខែ កញ្ញា ឆ្នាំ ២០០៣ ដល់ ខែ ធ្នូ ឆ្នាំ ២០០៤ ប្រទេសកម្ពុជា បានធ្វើជាសហប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីការបោសសំអាតមីន ការអប់រំពីគ្រោះថ្នាក់មីន និងបច្ចេកវិទ្យាសំរាប់កំចាត់មីនជាមួយប្រទេសជប៉ុន។ អគ្គលេខាធិការនៃអាជ្ញាធរផ្តល់ជំនួយជនរងគ្រោះថ្នាក់មីន និងសកម្មភាពកំចាត់មីនកម្ពុជា (CMAA) **សម សុត្ថា** បានទទួលតួនាទីនេះ ដោយស្នើសុំអោយបណ្តាភាគីរដ្ឋជាសមាជិកទាំងឡាយដែលរងគ្រោះថ្នាក់ដោយសារមីនទាំងអស់ អោយបង្ហាញនិងកំណត់អោយបានច្បាស់នូវផែនការរបស់គេ ការរីកចំរើន និង អាទិភាពទាំងឡាយសំរាប់ជំនួយសកម្មភាពកំចាត់មីនក្នុងពេលដែលមានសន្និសីទបូកសរុបការងារមីននេះត្រូវបានគេប្រារព្ធធ្វើឡើង។

នាថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ក្រុមយុទ្ធនាការលុបបំបាត់មីនកម្ពុជា ( CCBL ) បានរៀបចំធ្វើការផ្សព្វផ្សាយរបាយការណ៏ត្រួតពិនិត្យមីនឆ្នាំ ២០០៤ មុនគេលើពិភពលោក ដែលផ្តោតទៅលើអ្នករស់រានជីវិតពីគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ដែលជាការចាប់ផ្តើមផ្សព្វផ្សាយរបាយការណ៏សំខាន់ៗផ្សេងទៀតនៅក្នុងរបាយការណ៏ត្រួតពិនិត្យមីនពិភពលោកប្រចាំឆ្នាំ២០០៤។ ពិធីផ្សព្វផ្សាយរបាយការណ៏ត្រួតពិនិត្យមីនឆ្នាំ ២០០៤ នេះត្រូវបានយាងចូលរួមដោយព្រះមហាក្សត្រប្រទេសកម្ពុជា **សម្តេចព្រះនរោត្តម សីហមុនី** ដែលជាការបង្ហាញព្រះភ័ក្រលើកដំបូងរបស់ព្រះអង្គជាសាធារណៈផងដែរ បន្ទាប់ពីបានឡើងគ្រងរាជ្យ និងក្នុងនាមជាប្រមុខ

[3] Song Kosal speech, opening ceremony, First Review Conference, Nairobi, 29 November 2004.

រាជវង្សរបស់ប្រទេសកម្ពុជា ហើយត្រូវបានការស្វាគមន៍យ៉ាងកងរំពងពីបណ្តាលជនពិការ និងប្រជាជនប្រមាណជាង ៤២០០នាក់ ដែលបានចូលរួមក្នុងពិធីនេះ ។

នាខែ វិច្ឆិកា ឆ្នាំ ២០០៤ កិច្ចប្រជុំមួយស្តីពីការអប់រំគ្រោះថ្នាក់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅតាមតំបន់ទន្លេមេគង្គ ក៏ត្រូវបានគេធ្វើនៅក្នុងខេត្តសៀមរាបផងដែរ ។ លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានចូលរួមបើកសន្និសីទបូកសរុបការងារផ្នែកសកម្មភាពមីនលើកទី៣ នៅភ្នំពេញនាថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៥ ។[4] ពេញមួយឆ្នាំ ២០០៤ និង ដើមឆ្នាំ ២០០៥ វេទិកាសកម្មភាពមីនរបស់អង្គការក្រៅរដ្ឋាភិបាល បានជួបប្រជុំរៀងរាល់បីខែម្តង ដើម្បីពិភាក្សាផ្តោតលើប្រធានបទទាំងឡាយស្តីពីកង្វល់រួម ដែលមានដូចជា ការប្រមូលទិន្នន័យ ការអប់រំពីគ្រោះថ្នាក់មីន និងគ្រាប់មិនទាន់ផ្ទុះ ការរៀបចំផែនការជាអាទិភាព ការដោះមីនដោយអ្នកភូមិនិងបញ្ហាជនស៊ីវិលផ្សេងៗទៀត ដែលញាំញីដោយសារបញ្ហាមីននិងគ្រាប់មិនទាន់ផ្ទុះ ។

ប្រទេសកម្ពុជាបានដាក់ស្នើនូវរបាយការណ៍មាត្រា ៧ ប្រចាំឆ្នាំលើកទី៦ របស់ខ្លួន ដោយរួមទាំងទំរង់ F ( Voluntary Form F. ) នាថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៥ សំរាប់ឆ្នាំសារពើពន្ធ ២០០៤ ។[5] ប្រទេសកម្ពុជាបានចូលរួមអន្តរប្រជុំទាំងឡាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដោយបានធ្វើសេចក្តីថ្លែងការណ៍ស្តីពីការបោសសំអាតមីន និងជំនួយដល់អ្នករស់រានជីវិតពីគ្រាប់មីន ។

ប្រទេសកម្ពុជាមិនបានចូលរួមក្នុងកិច្ចពិភាក្សាវែកញែកអោយទូលំទូលាយដូចដែលភាគីរដ្ឋទាំងមូលបានចូលរួម អំពីការបកប្រែ និងការអនុវត្តន៍ដែលទាក់ទងទៅនឹងមាត្រា ១,២ និង ទី៣ ។ ហេតុនេះហើយប្រទេសកម្ពុជា មិនបានបញ្ចេញជាសាធារណៈនូវទស្សនៈរបស់ខ្លួនស្តីពីបញ្ហាទាំងឡាយដែលទាក់ទងនឹងកិច្ចប្រតិបត្តិការយោធារួមជាមួយភាគីឧទ្ទាម ដែលទាក់ទងទៅនឹងបញ្ហាគ្រាប់មីនគ្រប់ប្រភេទ ដូចជា មីនប្រឆាំងរថក្រោះ មីនប្រឆាំងមនុស្ស ឧបករណ៍ដោះមីនបាន និងចំនួនគ្រាប់ដែលអនុញ្ញាតសំរាប់ទុកហ្វឹកហាត់នោះឡើយ ។ នាខែមិថុនា ឆ្នាំ ២០០៥ លោកអគ្គលេខាធិការអាជ្ញាធរមីនកម្ពុជា បានប្រាប់ក្រុមអ្នកត្រួតពិនិត្យមីនកម្ពុជាថាប្រទេសកម្ពុជានឹងមិនចូលរួមក្នុងប្រតិបត្តិការណ៍យោធាណាមួយទេ បើគ្មានការស្នើពីអង្គការសហប្រជាជាតិ ។[6]

ប្រទេសកម្ពុជា ជាភាគីរដ្ឋ ដែលបានចូលរួមក្នុងមហាសន្និបាតកែប្រែពង្រាងអនុស្សារណៈទី២ របស់អនុសញ្ញាស្តីពីការប្រើប្រាស់អាវុធ "Amended Protocol II of the Convention on Conventional Weapons: CCW " ប៉ុន្តែមិនបានចូលរួមក្នុងកិច្ចប្រជុំបណ្តាភាគីរដ្ឋសមាជិកប្រចាំឆ្នាំលើកទី៦ ដែលគេប្រារព្ធធ្វើនៅទីក្រុង ហ្សឺណែវ ក្នុងខែវិច្ឆិកា ឆ្នាំ ២០០៤ និងមិនបានដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនតាមមាត្រា

[4] Both the Prime Minister and Deputy Prime Minister Sok An made statements to the National Conference on Mine Action Achievements 1992–2004 of Cambodia, 28 April 2005.

[5] The previous Article 7 reports were submitted on: 30 April 2004; 15 April 2003; 19 April 2002; 30 June 2001; 26 June 2000 (this report covers the period from 1993 to 26 June 2000).

[6] Interview with Sam Sotha, Secretary General, CMAA, at Standing Committee meetings, Geneva, 16 June 2005.

ទី១៣ឡើយ។

## ការផលិត ការដឹកជញ្ជូន និងការប្រើប្រាស់មីន

មីនត្រូវបានគេដាក់បង្កប់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ ១៩៦០ ដល់ ចុងទសវត្សឆ្នាំ១៩៩០មកម្ល៉េះ ដោយមានរបាយការណ៍ និងការអះអាងជាច្រើន ដែលបញ្ជាក់ពីការប្រើប្រាស់គ្រាប់មីន ដោយកងយោពលខេមរភូមិន្ទ និងពួកខ្មែរក្រហមរហូតដល់ឆ្នាំ ១៩៩៨។ គេគ្មានការបញ្ជាក់ជាក់លាក់អំពីការប្រើប្រាស់ ការផលិត ការផ្ទេរ ដឹកជញ្ជូនគ្រាប់មីនប្រឆាំងមនុស្ស ដោយកងកំលាំងប្រដាប់អាវុធរដ្ឋាភិបាល ឬកងកំលាំងប្រឆាំងណាមួយយទេ តាំងពីឆ្នាំ ១៩៩៩មក។ ប្រទេសកម្ពុជា បានរាយការណ៍ថា ខ្លួនគ្មានកន្លែងផលិតមីនប្រឆាំងមនុស្សតទៅទៀតឡើយ។[7] គេមិនបានអោយដឹងទេថា រដ្ឋាភិបាលកម្ពុជាបានដឹកជញ្ជូនចេញនូវគ្រាប់មីនប្រឆាំងមនុស្សកាលពីពេលមុនឡើយ។[8] ការអះអាងពីការស្តុកទុកគ្រាប់មីនជាលក្ខណៈឯកជនបានកើតឡើងជាប់រហូតចាប់តាំងពីឆ្នាំ ១៩៨០ ដល់ ឆ្នាំ ២០០៥។

## ការស្តុកទុកនិងការបំផ្លាញឃ្លាំងស្តុកមីន

កងយោធពលខេមរភូមិន្ទ បានកំទេចចោលនូវមីនប្រឆាំងមនុស្សដែលរក្សាទុកក្នុងឃ្លាំងចំនួន៧១,៩៩១គ្រាប់ រវាងឆ្នាំ១៩៩៤ និង១៩៩៨ ហើយនាខែកុម្ភៈឆ្នាំ ១៩៩៩ អគ្គបញ្ជាការរងកងយោធពលខេមរភូមិន្ទកម្ពុជាបានអះអាងជាផ្លូវការថា កងយោពលខេមរភូមិន្ទ គ្មានឃ្លាំងស្តុកទុកមីនប្រឆាំងមនុស្សទៀតទេ។[9] នាឆ្នាំ២០០០ ប្រទេសកម្ពុជាបានអោយដឹងពីឃ្លាំងស្តុកមីនប្រឆាំងមនុស្ស១កន្លែង ដែលមានមីនប្រឆាំងមនុស្សចំនួន២,០៣៤គ្រាប់ គ្រប់គ្រងដោយប៉ូលីសជាតិ។[10] ក្រោយមកទៀត គេបានប្រកាសថាគ្មានឃ្លាំងស្តុកមីនប្រឆាំងមនុស្សទៀតទេចាប់ពីឆ្នាំ ២០០១មក។[11]

តែទោះជាដូចនេះក្តី ក៏អង្គភាពប៉ូលីសនិងកងយោធពលខេមរភូមិន្ទបន្តស្វែងរកគ្រាប់មីនប្រឆាំងមនុស្ស និងអាវុធដទៃៗទៀតជាច្រើននៅតំបន់ផ្សេងៗ និងប្រភពដទៃទៀតក្នុងទូទាំងប្រទេស។ មានកន្លែងលាក់អាវុធជាច្រើនដែលបន្សល់ទុកដោយសារសង្រ្គាមអស់រយៈកាលប៉ុន្មានសតវត្សនេះ។ ការដោះមីនដោយអ្នកភូមិ និងអ្នករកស៊ីលក់ដែកអេតចាយចាស់ៗ ក៏ទទួលខុសត្រូវចំពោះការរក្សាទុកគ្រាប់មីនជាច្រើនដែលទើបរកឃើញផងដែរ។ គ្រាប់មីនទាំងនោះគួរតែត្រូវរាយការណ៍ទៅអាជ្ញាធរមីនកម្ពុជា និងប្រគល់ទៅអោយអង្គការ ស៊ីម៉ាក់ ដើម្បីធ្វើការកំទេចចោល ហើយដែលអាចមានគ្រាប់មីនខ្លះៗត្រូវបានគេយកទៅប្រើក្នុងបំណងធ្វើការហ្វឹកហ្វឺន។[12]

---

[7] Article 7 Report, Form E, 22 April 2005. In the 1970s, Cambodia manufactured one type of antipersonnel landmine, the KN-10 Claymore-type mine, and various forces manufactured home-made mines in the past.

[8] See *Landmine Monitor Report 2000*, pp. 382–383.

[9] See *Landmine Monitor Report 1999*, p. 391, for annual destruction totals.

[10] Article 7 Report, Form B, 26 June 2000.

[11] Article 7 Report, Form F, 30 April 2004.

[12] Article 7 Report, Forms D and F, 22 April 2005.

ការរកឃើញនិងកំទេចចោលនូវគ្រាប់មីនជាច្រើនទៀត គឺមិនត្រូវបានគេអោយដឹងជាប្រចាំ និងទាំងអស់ ក្នុងរបាយការណ៍មាត្រា៧ ពីមុនៗរបស់ប្រទេសកម្ពុជានោះទេ ។[13]

នៅក្នុងរបាយការណ៍នៃមាត្រា ៧ របស់ខ្លួន ដែលដាក់ជូននាខែមេសា ឆ្នាំ ២០០៥ ប្រទេសកម្ពុជាប្រកាសថា ចាប់ពីឆ្នាំ២០០០ ទល់នឹងឆ្នាំ ២០០៤ ចំនួនមីនប្រឆាំងមនុស្ស ៥៤,២៥៨គ្រាប់ ត្រូវគេរកឃើញ និងបំផ្លាញចោលដែលចំនួននេះ រួមមានមីនចំនួន ១៥,៤៤៦ គ្រាប់ ត្រូវបានបំផ្លាញចោលដោយទីភ្នាក់ងារបីនៅ ក្នុងឆ្នាំ២០០៤ (១០,០៣៣គ្រាប់ដោយអង្គការស៊ីម៉ាក់ (CMAC), ៣,៦៣២គ្រាប់ ដោយអង្គការ HALO Trust និង ១,៧៨១ គ្រាប់ ដោយអង្គការ Mines Advisory Group:MAG) នេះជាចំនួនមួយដែលច្រើនជាងបណ្ដាឆ្នាំណាៗទាំងអស់នាពេលកន្លងមក ។[14]

នៅខែ សីហា ឆ្នាំ ២០០៥ អង្គការ HALO Trust បានរាយការណ៍ថា នៅក្នុងរយៈពេល ២ទៅ៣សប្ដាហ៍កន្លងមកនេះ កងយោធពលខេមរភូមិន្ទបានប្រគល់គ្រាប់មីនប្រឆាំងមនុស្សដែលបានរក្សាទុកចំនួន ជាង ១២០០០គ្រាប់កំទេចចោល ។ HALO Trust បានកំពុងជួយកងយោធពលខេមរភូមិន្ទកំទេចចោលនូវអាវុធដែលមិនចាំបាច់ និងអន់ៗនៅក្នុងឃ្លាំងរក្សាទុកគ្រាប់មីនដ៏ធំនៅក្នុងខេត្តកំពង់ស្ពឺ ។ HALO បានកត់សំគាល់ថា "គ្រាប់មីនភាគច្រើនបំផុតគឺត្រូវបានគេច្រកដាក់ក្នុងឡាំងនិង ក្នុងលក្ខខ័ណ្ឌដែលល្អបំផុត" ហើយបានលើកបញ្ហានេះថា" ជាគំរូរបស់កងយោធពលខេមរភូមិន្ទ ដែលអាចធ្វើការផ្ទៀងផ្ទាត់ដោយឯករាជ្យបានក្នុងគោលបំណងគោរពទៅតាមករណីកិច្ច" ក្នុងសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ។[15]

នៅក្នុងការកំនត់បន្ទាន់មួយនូវតួលេខខាងលើយ៉ាងច្បាស់នោះប្រទេសកម្ពុជាបានរាយការណ៍ថា គ្រាប់មីនប្រឆាំងមនុស្សចំនួន១៦,៩៥៩គ្រាប់ ត្រូវបានគេប្រគល់ទៅអោយអង្គការស៊ីម៉ាក់ ដើម្បីធ្វើការកំទេចចោល នៅរវាងឆ្នាំ ១៩៩៧ និង ឆ្នាំ ២០០២ ដែលមានមីន ៣គ្រាប់នៅឆ្នាំ ១៩៩៧, មាន ១៣៨៩គ្រាប់ នៅឆ្នាំ ១៩៩៨, ៥២៤៣គ្រាប់នៅឆ្នាំ១៩៩៩, ៦,៦២៦គ្រាប់ នៅឆ្នាំ២០០០, ៥៣៣គ្រាប់នៅឆ្នាំ២០០១, ៣១៦៥គ្រាប់ នៅឆ្នាំ២០០២ ។ គេមិនមានតួលេខចំនួនគ្រាប់មីនសំរាប់ឆ្នាំ ២០០៣ ឬ ឆ្នាំ ២០០៤ ទេ ។[16]

*គ្រាប់មីនដែលគេរក្សាទុកសំរាប់ការស្រាវជ្រាវ និង ការហ្វឹកហ្វឺន*

ក្នុងរបាយការណ៍៦ផ្នែកនៃមាត្រាទី៧របស់ខ្លួនប្រទេសកម្ពុជាបានបង្ហាញថាខ្លួនគ្មានគ្រាប់មីនប្រឆាំងមនុស្ស

[13] For details see *Landmine Monitor Report 2004*, p. 248.

[14] Article 7 Report, Form G, 22 April 2005. In previous years, all the mines were destroyed by CMAC, including: 8,739 in 2000; 7,357 in 2001; 13,509 in 2002; 9,207 in 2003. These numbers match revised totals provided to Landmine Monitor last year by CMAA after inquiries about inconsistencies in Article 7 reporting. *Landmine Monitor Report 2004*, p. 248.

[15] Email from Richard Boulter, Programme Manager, HALO Cambodia, to Denise Coghlan, CCBL and Landmine Monitor, 19 August 2005. He indicated funding for the project came from the US State Department.

[16] Article 7 Report, Form D, 22 April 2005.

ដែលរក្សាទុកក្នុងគោលបំណងការហ្វឹកហ្វឺន និង ការអភិវឌ្ឍន៍ ដូចដែលបានយល់ព្រមតាមមាត្រាទី៣ឡើយ។ តែទោះជាយ៉ាងនេះក្តី ប្រទេសកម្ពុជាក៏បានរាយការណ៍ពីការផ្ទេរគ្រាប់មីនក្នុងធ្វើគោលបំណងហ្វឹកហ្វឺន និង ការអភិវឌ្ឍន៍ទៅអោយមណ្ឌលហ្វឹកហ្វឺនរបស់អង្គការស៊ីម៉ាក់ជារៀងរាល់ឆ្នាំផងដែរ។ ប្រទេសកម្ពុជាបង្ហាញជារៀងរាល់ឆ្នាំថា មានគ្រាប់មីនមួយចំនួនត្រូវគេបញ្ជូនទៅមជ្ឈមណ្ឌលហ្វឹកហ្វឺននៃអង្គការស៊ីម៉ាក់ ដែលមានគ្រាប់មីនជាច្រើនយកចេញពីដីដោយពួកអ្នកដោះមីនរឺជាមីន ដែលគេទើបប្រទះឃើញនៅក្នុងកន្លែងគេលាក់ទុកជាច្រើនកន្លែងទៀតនិងដោយសន្មតថាត្រូវបានគេបំផ្លាញចោលភ្លាមបន្ទាប់ពីបញ្ជូនទៅដល់ ។

តែទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាមិនបានបញ្ជាក់ច្បាស់ថាតើមានគ្រាប់មីនទាំងអស់ (រឺខ្លះ) ដែលបង្វែរទៅអោយអង្គការស៊ីម៉ាក់នោះត្រូវគេយកទៅប្រើប្រាស់រៀងរាល់ឆ្នាំ រឺក៏រក្សាទុកពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីបំរើអោយគោលបំណងហ្វឹកហ្វឺនរឺទេ។ ជាងនេះទៅទៀតប្រទេសកម្ពុជា មិនបានផ្តល់នូវសេចក្តីលំអិតណាមួយពីគោលបំណងដែលគេបានគ្រោងទុក និង ការប្រើប្រាស់គ្រាប់មីនជាក់ស្តែង ដែលបានរក្សាទុកក្នុងគោលបំណងបំរើអោយការហ្វឹកហ្វឺន ដែលជាជំហានមួយមានការព្រមព្រៀងពីបណ្តាភាគីរដ្ឋទាំងឡាយនៅក្នុងផែនការសកម្មភាពនៅទីក្រុងណៃរ៉ូប៊ី (The Nairobi Action Plan) ដែលភ្ជាប់មកពីសន្និសីទបូកសរុបការងារមីនលើកទី១ដែរ។

ប្រទេសកម្ពុជាបានរាយការណ៍ថាក្នុងឆ្នាំ ២០០៤ បណ្តាអង្គភាពដោះមីនផ្សេងៗបានបង្វែរគ្រាប់មីនប្រឆាំងមនុស្សចំនួន ៥៩៦ គ្រាប់ ទៅអោយមជ្ឈមណ្ឌលហ្វឹនហ្វឺនរបស់អង្គការស៊ីម៉ាក់ (CMAC) ដើម្បីធ្វើការគាំទ្រដល់សកម្មភាពហាត់ដោះមីននានា។[17] នៅចន្លោះឆ្នាំ ១៩៩៣ និង ២០០៤ គ្រាប់មីនប្រឆាំងមនុស្សសរុបចំនួន ៣,០៧៩ ត្រូវបានគេរាយការណ៍ថា បានបង្វែរទៅអោយអង្គការស៊ីម៉ាក់ដើម្បីប្រើប្រាស់ក្នុងគោលបំណងហ្វឹកហ្វឺនដោះមីនដែលរួមមានមីន ចំនួន ៣៦៦គ្រាប់ បានមកពីអង្គភាពដោះមីនរបស់អង្គការស៊ីម៉ាក់ផ្សេងៗទៀតនៅឆ្នាំ២០០៣ និងចំនួន២៤០គ្រាប់បានមកពីក្រសួងមហាផ្ទៃក្នុងឆ្នាំ២០០២។[18]

ពីតួលេខផ្សេងៗដែលមាននៅក្នុងរបាយការណ៍លើមាត្រាទី៧ លើរយៈកាលប៉ុន្មានឆ្នាំនេះ វាហាក់ដូចជាមានការលំបាកខ្លាំងចំពោះបណ្តាប្រទេសទាំងឡាយ ដែលទទួលរងគ្រោះដោយសារគ្រាប់មីន ដូចជាប្រទេសកម្ពុជា ដើម្បីធ្វើការបកស្រាយពីបញ្ហាទាំងឡាយស្តីអំពីចំនួនឃ្លាំងផ្ទុកគ្រាប់មីន និង ការខូចខាតអោយបានត្រឹមត្រូវនោះ។ ប្រទេសជាច្រើនក្នុងចំណោមប្រទេសដែលទទួលរងគ្រោះដោយសារគ្រាប់មីននេះ បានទទួលរងការឈឺចាប់អស់រយៈពេលជាច្រើនឆ្នាំ ដោយសារសង្គ្រាម គ្រាប់មីនកប់ក្នុងដី

[17] Article 7 Report, Form D, 22 April 2005.

[18] Article 7 Report, Form D, 22 April 2005. In addition, 348 mines were transferred to CMAC from MCTU/UNTAC in 1993, 236 from CMAC PMU Siem Reap in 1998, 272 from CMAC EOD Preah Vihear in 1999, 546 from CMAC DU2 in 1999, 52 from CMAC HQ Phnom Penh in 2000, and 423 from CMAC DU6 Siem Reap in 2001.

ការបោសសំអាតមីន និង ការបំផ្លិចបំផ្លាញដោយគ្រាប់មីន និង ការបោសសំអាតមីនតាមភូមិដែលគេមិនបានផ្តល់ជារបាយការណ៍ ។ មានការភ័ណ្ឌច្រឡំពីមីនដែលបានបញ្ជូនមកពីចំការមីនមកដើម្បីកំទេចចោលបង្កើតបានជាឃ្លាំងរក្សាទុកមីនជាបណ្តោះអាសន្នកន្លែងលាក់គ្រាប់មីននៅតាមភូមិ និងតំបន់ដីមានគ្រាប់មីនដែលបានរក្សាទុកក្នុងឃ្លាំង ។

## <u>បញ្ហាមីននិងអាវុធជាតិផ្ទុះដែលនៅសេសសល់ពីសង្គ្រាម</u> (ERW)

ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសដែលរងគ្រោះធ្ងន់ធ្ងរបំផុតដោយសារគ្រាប់មីន និង អាវុធជាតិផ្ទុះ ដែលនៅសេសសល់ពីសង្គ្រាម (ERW) ក្នុងរយៈពេលជិត ៣ទសវត្សកន្លងទៅនេះ។ ការបំផ្លាញដោយគ្រាប់មីន និង យុទ្ធភ័ន្តមិនទាន់ផ្ទុះ (UXO) គឺជាបញ្ហាចាក់ស្រេះខ្លាំងក្លា និងធ្ងន់ធ្ងរមួយនៅក្នុងប្រទេស ។ បរិមាណអាវុធដែលត្រូវគេបោះបង់ចោលក៏នៅមានច្រើនដែរ ។

តំបន់មីនក-៥ (K-5) ដែលមានបណ្តោយ៧០គ.ម ទទឹងពី៤០០គ.ម ទៅ៥០០គ.ម នៅប៉ែកពាយ័ព្យប្រទេសគឺត្រូវទទួលរងការបំផ្លិចបំផ្លាញយ៉ាងខ្លាំង និង ក្រាស់ក្រែល ។ តំបន់ក-៥ ត្រូវបានគេបោះបង្គោលព័ទ្ធយ៉ាងត្រឹមត្រូវ ខុសពីផ្នែកដទៃផ្សេងទៀតនៃអតីតតំបន់មានសង្គ្រាម ដែលជាតំបន់ចំការមីនជាច្រើនកន្លែងដែលគេមិនបានកំនត់ជាផែនទីថាមានមីននៅប្រមូលផ្តុំ និងរាយប៉ាយទៅដែលបណ្តាលមកពីការហាត់ដាក់បង្កៃមីនពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីការពារបរិវេណសឹកនៅពេលកងយុទ្ធជនដកថយទៅកាន់កន្លែងមានសុវត្ថិភាពបន្ទាប់ពីរដូវប្រាំងប្រចាំឆ្នាំ។ គ្រាប់មីនប្រឆាំងមនុស្សភាគច្រើនដែលគេរកឃើញជាទូទៅមានដូចជាមីន : PMN, PMN2, PMD-6, MN 79, ប្រភេទ 69, DH10, MON 66150, POMZ-2M, ប្រភេទ 72B ។[19]

ការបំផ្លិចបំផ្លាញដោយសារគ្រាប់មិនទាន់ផ្ទុះ (UXO) មួយផ្នែកធំបណ្តាលមកពីកងកំលាំងសហរដ្ឋអាមេរិកដែលបានទំលាក់គ្រាប់បែកជាង 500,000 តោន លើប្រទេសកម្ពុជា ភាគច្រើនលើបណ្តាខេត្តប៉ែកឥសានដែលមានមនុស្សរស់នៅច្រើនកុះករ ។ ដោយផ្អែកលើការវាយតំលៃលើការបរាជ័យមាន ១០ភាគរយ ដែលមានលក្ខណៈអភិរក្សនិយមនោះថា មានគ្រាប់បែកមិនទាន់ផ្ទុះជិត 50,000 តោន នៅតែមាននៅក្នុងតំបន់ទាំងនេះក្នុងប្រទេសកម្ពុជា ជាងនេះទៀតមានគ្រាប់ផ្លោងមិនទាន់ផ្ទុះ គ្រាប់បែកដៃ និង គ្រាប់កាំភ្លើងត្បាល់ដែលបានប្រើប្រាស់ដោយក្រុមយុទ្ធជនដទៃផ្សេងទៀត ។[20]

---

[19] Article 7 Report Form F, 22 April 2005. Other types of mine found in Cambodia include KN-10, M-62, M14, M16A1, M18A1, MBV-78-A1, MBV-78-A2, MD-82-B, MDH-10, MDH-2, MDH-3, MDH-5, MDH-7, MIN, MN, MODEL, MON, NOMZ2B, OMZ-3, OMZ-4, OMZ-72, P-40 BALL, PMA-2, PMA-3, POMZ-2, PPMI-SR, PPM-2, PSM-1, Type 66. US Department of Defense, Mine Facts CD-ROM, Version 1.2.

[20] Robert Griffin and Robert Keeley, “Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action,” Volume I, Phnom Penh, 4 December 2004, p. 3.

គ្រោះថ្នាក់ដោយគ្រាប់មីនភាគច្រើនកើតឡើងនៅតំបន់ព្រំដែនក-៥ ( មានខេត្តបាត់ដំបង, ព្រះវិហារ បន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិន និង ពោធិសាត់ ) ។ នៅក្នុងខេត្តបាត់ដំបង ក៏មានគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះ (UXO)កើតឡើងច្រើនដែរ ។ គ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះ ដែលគេបានកត់ត្រាជារៀងរាល់ឆ្នាំ ក៏កើតមានឡើងក្នុង ខេត្តកំពង់ចាម សៀមរាប កំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ ស្វាយរៀង ក្រចេះ កណ្តាល នឹងកើតមានក្នុងករិតតិចជាងនេះ មានបណ្តាខេត្តដទៃទៀត ។ គ្រោះថ្នាក់ដោយសារមីនភាគច្រើនបំផុតទាក់ទងទៅនឹងសកម្មភាពប្រកបរបរចិញ្ចឹមជីវិតនៅក្នុងព្រៃ និង ដីចំការ ។[21] នៅឆ្នាំ ២០០៤ ជិត ៩៩ភាគរយ នៃអ្នករងគ្រោះដោយសារគ្រាប់មីន រឺ UXO ជិត៩០០នាក់ ជាជនស៊ីវិល ជាករិតមួយដែលកើតមានរាំរ៉ៃអស់រយៈកាលជាច្រើនឆ្នាំកន្លងទៅនេះ ។ ជាងពាក់កណ្តាលនៃគ្រោះថ្នាក់ដោយសារគ្រាប់មីន UXO បណ្តាលមកពីការកេះកកាយរុករើលេងដោយចេតនា ។[22]

កត្តាមួយទៀត ដែលបង្កអោយមានបញ្ហាមីន រឺ បញ្ហាអាវុធជាតិផ្ទុះសល់ពីសង្គ្រាមនៅក្នុងប្រទេសកម្ពុជាបណ្តាលមកពីមានឃ្លាំង និង កន្លែងលាក់អាវុធជាតិផ្ទុះក្រៅផ្លូវការជាច្រើនទៀត ។ ឧទាហរណ៍ដូចជាដើមខែ សីហា ឆ្នាំ ២០០៥ HALO Trust បានកំពុងជួយដល់កងយោធពលខេមរភូមិន្ទ បោសសំអាតឃ្លាំងរក្សាទុកជាតិផ្ទុះដ៏ធំរបស់ខ្លួនក្នុងខេត្តកំពង់ស្ពឺ ។ បញ្ហានេះទាក់ទងនឹងការកំទេចចោលនូវអាវុធមិនចាំបាច់អន់ៗនិងអាវុធដែលមិនបានដាក់ក្នុងឡាំង បានត្រឹមត្រូវនៅក្នុងឃ្លាំងអាវុធរបស់កងយោធពលខេមរភូមិន្ទ ដែលមានច្រើនជាង ១០តោន នៃអាវុធ អនុសញ្ញា គ្រាប់កាំភ្លើងខ្លីជាងមួយលានគ្រាប់ (២៥តោន) និង គ្រាប់មីនប្រឆាំងមនុស្សជាង ១២,០០០ គ្រាប់ ។[23]

នៅថ្ងៃ៣១ ខែមិនា ឆ្នាំ២០០៥ ឃ្លាំងផ្ទុកអាវុធជាតិផ្ទុះរបស់កងយោធពលខេមរភូមិន្ទមួយកន្លែងនៅក្នុងខេត្តបាត់ដំបងបានផ្ទុះឡើងដោយលាតត្រដាងអោយឃើញថាមានអាវុធនិងបំណែករថយន្តប្រណិតៗជាច្រើនប្រភេទតែគ្មានគ្រាប់មីនប្រឆាំងមនុស្សទេ[24] ។ ការផ្ទុះឡើងដ៏ខ្លាំងក្លា និង ការផ្ទុះកំទេចគ្រាប់ជាបន្តបន្ទាប់គ្នាបានសំលាប់មនុស្សយ៉ាងហោចណាស់០៦នាក់ ធ្វើអោយមានរបួសជាង ២០នាក់ បានបំផ្លាញផ្ទះ១៤ខ្នង និង បានពង្រាយអោយនៅពាសពេញនូវគ្រាប់កាំភ្លើងធំជាង ១,៣០០គ្រាប់ លើតំបន់មួយដែលមានទំហំ ១០គ.មជុំវិញ ។[25]

---

[21] Cambodia Mine/UXO Victim Information System (CMVIS), “Monthly Mine/UXO Report,” January 2005.

[22] Email to Landmine Monitor (HI) from Chhiv Lim, Project Manager, CMVIS, 1 August 2005. See section on Landmine/UXO Casualties.

[23] Email from Richard Boulter, Programme Manager, HALO Cambodia, 19 August 2005.

[24] “RCAF Explosion May Be Sabotage,” *Cambodia Daily*, 28 April 2005, p. 12.

[25] "Cambodia's RCAF identifies causes of ammunition explosion,” *People’s Daily Online*, 4 April 2005.

ការបំផ្លិចបំផ្លាញដោយសារគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក៏ជាឧបសគ្គរាំងស្ទះដល់ការអភិវឌ្ឍន៍ និងគំរោងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗផងដែរដែលកំពុងកើតមានឡើងនៅតំបន់ពាយ័ព្យនៃប្រទេសកម្ពុជា ។[26]

ចំនួននៃការបំផ្លិចបំផ្លាញដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលបន្សល់ទុកក្នុងប្រទេសកម្ពុជា ចាប់តាំងពីប្រតិបត្តិការបោសសំអាតមីននានាត្រូវបានរៀបចំចាត់តាំងឡើង ដែលបានផ្តើមធ្វើសកម្មភាពនៅក្នុងឆ្នាំ ១៩៩២មក គឺមិនមានតួលេខច្បាស់នៅឡើយទេ ហើយក៏នៅតែជាបញ្ហាព្យាករណ៍នៅឡើយដែរ ។

## កម្មវិធីសកម្មភាពកំចាត់មីន

អាជ្ញាធរផ្តល់ជំនួយដល់ជនរងគ្រោះដោយសារសកម្មភាពកំចាត់មីននៅកម្ពុជា (CMAA) បានបន្តធ្វើការសំរបសំរួល និង រៀបចំសកម្មភាពកំចាត់មីនបន្តពីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) នៅខែកញ្ញា ឆ្នាំ២០០០ ។ សកម្មភាពទទួលខុសត្រូវរបស់អាជ្ញាធរមីនកម្ពុជា រួមមានការធ្វើសមាហរណកម្មសកម្មភាពកំចាត់មីនទៅក្នុងផែនការអភិវឌ្ឍន៍របស់រដ្ឋាភិបាលយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ នៅទូទាំងប្រទេស និង ទិសដៅអភិវឌ្ឍន៍ប្រចាំសហវត្ស ។[27] មជ្ឈមណ្ឌលកំចាត់មីនស៊ីម៉ាក់ (CMAC) បានបន្តធ្វើប្រតិបត្តិការរបស់ខ្លួនក្នុងនាមជាភ្នាក់ងារអនុវត្តន៍នូវសកម្មភាពបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។

ការវាយតំលៃមួយដែលធ្វើឡើងនៅឆ្នាំ ២០០៤ ចំពោះក្រុមការងារ អ្នកផ្តល់ជំនួយរបស់ប្រទេសកម្ពុជាដល់សកម្មភាពកំចាត់មីនបានអោយដឹងថា: ក្រុមអ្នកផ្តល់ជំនួយ ព្រមជាមួយក្រុមអ្នកប្រតិបត្តិការខ្វះការជឿទុកចិត្តលើស្ថាប័នអាជ្ញាធរមីន (CMAA) ដោយសារភាពទន់ខ្សោយ និង គ្មានប្រសិទ្ធិភាពរបស់ស្ថាប័ននេះ និង ថាការងាររបស់ខ្លួនមួយផ្នែកធំត្រូវបានគេទុកចោលជាអន្លើៗ ។ ការវាយតំលៃនេះបានផ្តល់អនុសាសន៍ថា ស្ថាប័ននេះផ្តោតការយកចិត្តទុកដាក់តែទៅលើសកម្មភាពតិចតួច ដូចជាការ ធ្វើនយោបាយ ការប្រមូលប្រភពធនធាន ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ និង ការបង្កើតស្តង់ដារមីន។ ការទទួលខុសត្រូវដទៃទៀតរបស់ស្ថាប័ននេះ គួរតែត្រូវបានបំពេញចំពោះភ្នាក់ងារដទៃៗទៀតអោយបានច្រើនជាងនេះ រួមមាន: ការគូសផែនទី, នយោបាយភូមិបាល, ការធ្វើវិភាជន៍ និង ការកំណត់នូវការអប់រំពីគ្រោះថ្នាក់ដោយសារគ្រាប់មីន និង ជំនួយដល់ជនរងគ្រោះដោយសារមីន ។[28]

ការរៀបចំកំនត់ការងារជាអាទិភាពចំពោះសកម្មភាពកំចាត់មីន ត្រូវបានកំនត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងសេដ្ឋកិច្ចសង្គមរបស់ប្រតិបត្តិការបោសសំអាតមីននានា ដែលបានអនុម័តយល់ព្រម នៅថ្ងៃទី

[26] HALO Trust, “Annual Report 2004, for submission to the CMAA,” 21 January 2005, p. 7.
[27] See *Landmine Monitor Report 2004*, p. 251.
[28] Robert Griffin and Robert Keeley, “Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action,” Volume I, Phnom Penh, 4 December 2004, p. 4.

១៧ ខែកញ្ញា ឆ្នាំ២០០៤។[29] ប្រការនេះ បានប្រែក្លាយរចនាសម្ព័ន្ធរបស់អង្គភាពប្រើប្រាស់ដីដោះមីនខេត្ត (Land Use Planning Units) ជាលើកដំបូង ដោយការធ្វើអោយទៅជាអាទិភាពនូវសកម្មភាពកំចាត់មីនជាចំបងនៅកំរិតតំបន់ និង ដោយធ្វើសមាហរណកម្មវាជាមួយខាងការអាទិភាពអភិវឌ្ឍន៍។[30] ដើម្បីសំរេចគោលដៅនេះ ស្ថាប័នអាជ្ញាធរមីន បានបង្កើតអង្គភាពធ្វើគំរោងសកម្មភាពកំចាត់មីនទាំងឡាយ (Mine Action Planing Units:MAPUs) ដោយធ្វើប្រតិបត្តិការ នៅក្រោមការឧបត្ថម្ភរបស់គណៈកម្មាធិការកំចាត់មីននៅតាមខេត្ត (Provincial Mine Action Committee:PMACs) [31] ។ គណៈកម្មាធិការ PMACs នេះ គឺជាអង្គការមិនអចិន្ត្រៃយ៍គ្រប់គ្រងដោយចៅហ្វាយខេត្តរង និង មានភារកិច្ចអនុម័តយល់ព្រមទៅលើគំរោងការការងារបោសសំអាតមីនតាមខេត្តប្រចាំឆ្នាំ ដោយជ្រើសរើសយកដីដែលមានគ្រាប់មីន ដើម្បីធ្វើការបោសសំអាតដោយយោងតាមការងារជាអាទិភាពជាតិ ការអភិវឌ្ឍន៍តាមខេត្ត និង ការធ្វើអោយទៅជាអាទិភាពនូវប្រជាជនក្រីក្រ ។ អង្គភាព MAPUs ជាចំណុចប្រសព្វគ្នាសំរាប់ការសំរបសំរួលរវាងសហគមន៏នានាដែលទទួលរងការបំផ្លិចបំផ្លាញ និង ភ្នាក់ងារអភិវឌ្ឍន៍ ដោះមីនទាំងឡាយ។[32] ដំបូងគណៈកម្មាធិការ PMAC និងអង្គភាព MAPU ត្រូវបានបង្កើតឡើងនៅ ក្នុងខេត្តឧត្តរមានជ័យនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤ ។ គិតដល់ខែ មេសា ឆ្នាំ ២០០៥ មានអង្គភាព MAPUs ចំនួន៩ ដែលធ្វើប្រតិបត្តិការនៅក្នុងបណ្តាខេត្តជាច្រើនដូចៗគ្នា នឹងអង្គភាព Land Use Planning Units អ៊ីចឹងដែរ ។[33]

អង្គភាព MAPUs បានចុះធ្វើការស្រាវជ្រាវនៅនឹងកន្លែងផ្ទាល់ ប្រមូលសំនើររបស់អ្នកភូមិ និង ត្រូវបានជួយឧបត្ថម្ភដោយក្រុមការងារសកម្មភាពកំចាត់មីននៅតាមស្រុក ក្នុងការធ្វើការជ្រើសរើសយកចំការមីន ដើម្បីជាប្រយោជន៏ដល់សហគមន៏នានា។[34] អង្គភាព MAPUs ត្រូវបានឧបត្ថម្ភគាំទ្រដោយបណ្តាអង្គការជាច្រើន និងបានផ្តល់មូលនិធិដោយ UNDP និង ការិយាល័យសេវាកម្មរៀបចំគំរោងរបស់អង្គការសហប្រជាជាតិ (UNOPS) ។ អង្គការ SEILA ជាអ្នកគ្រប់គ្រង់ថវិកា របស់អង្គភាព MAPU ។[35]

---

[29] CMAA, “Mine Action Achievements 1992-2004,” 31 March 2005, p. 6.

[30] The Cambodian government has embarked on a series of major infrastructure projects in the northwest of the country which require mine clearance operations. For details of Land Use Planning Units see *Landmine Monitor Report 2004*, p. 252.

[31] CMAA, “Mine Action Achievements 1992-2004,” 31 March 2005, p. 29.

[32] AVI Information Sheet, April 2005.

[33] Interview with Clare Brazenor, Project Advisor of MAPU, AVI, 29 April 2005.

[34] CMAA, “Mine Action Achievements 1992-2004,” 31 March 2005, p. 29.

[35] SEILA is an acronym for socio-economic improvement of local area, a government program designed to support the country’s decentralization and “deconcentration” reforms. “The Seila Program is an aid mobilization and coordination framework for support to Cambodia's decentralization and de-concentration reforms” - www.seila.gov.kh. See also www.worldbank.org/wbi/reducingpoverty/case-Cambodia-SeilaProgram.html, and H. Evans et al., “Cambodia area rehabilitation and regeneration project (SEILA/CARERE2), CMB/95/011,

ការកសាងសមត្ថភាពចំពោះការធ្វើគំរោងសកម្មភាពកំចាត់មីន ដែលត្រូវបានផ្តល់ដោយអង្គការស្ម័គ្រចិត្តអូស្ត្រាលីអន្តរជាតិ: Australian Volunteers International (AVI), Geo Spatial (GSI) គឺមានការពាក់ព័ន្ធដល់ដំណើរការធ្វើអត្តសញ្ញាណដើម្បីធ្វើអោយប្រសើរនូវការប្រមូលទិន្នន័យដោយបុគ្គលិកMAPU ។ AVI និង GSI ក៏កំពុងតែបង្កើន សមត្ថភាពរបស់ PMAC ក្នុងការគ្រប់គ្រងពតិមាន និង ការប្រមូលទិន្នន័យផងដែរ ។[36]

ផែនការសកម្មភាពកំចាត់មីនរយៈពេល ៥ឆ្នាំ ពីឆ្នាំ ២០០៥-២០០៩ គឺត្រូវគេធ្វើអោយស្របទៅនឹងសមិទ្ធិផលទាំងឡាយដែលសំរេចបាននៅឆ្នាំ ២០០៤ ។ គោលដៅរបស់ផែនការនេះ រួមមានការបោសសំអាតគ្រាប់មីននៅតំបន់ដែលទទួលរងគ្រោះខ្លាំងក្លានៅត្រឹមឆ្នាំ ២០០៩, ការធ្វើសមាហរណកម្មការបោសសំអាតមីនជាមួយនឹងការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ, ការធ្វើអោយប្រសើរឡើងនូវប្រសិទ្ធិភាពលើការចាយវាយ, ការត្រួតពិនិត្យក្រោយពីការធ្វើការបោសសំអាតមីនរួចពីឆ្នាំ ២០០៥ និង "ការធ្វើអោយមានតុល្យភាពនូវបណ្តាសកម្មភាពការពារ និង សកម្មភាពព្យាបាលនានា " ។[37]

ផែនការទូទាំងប្រទេសសំរាប់ឆ្នាំ២០០៥ ដែលប្រមូលផ្តុំផែនការការងារទាំងឡាយពីក្រុមប្រតិបត្តិករសំខាន់ៗទាំង ៤ បានកំនត់ទិសដៅលើផ្ទៃដីចំនួន ៣៥,៤៦០,០០០ម² ដែលត្រូវធ្វើការបោសសំអាត ។ អង្គការ CMAC, អង្គការ HALO Trust និងអង្គការ MAG មានគោលបំណងបោសសំអាតផ្ទៃដីចំនួន ១៨,៥១០,០០០ម² ដើម្បីធ្វើការតាំងលំនៅថ្មី និងការធ្វើកសិកម្ម ដើម្បីផ្តល់ជាប្រយោជន៍ដល់គ្រួសារ ចំនួន ៦៦,០០០គ្រួសារ ដែលគេបានប៉ាន់ស្មាន ។ ប្រតិបត្តិការបោសសំអាតមីន ត្រូវបានគេធ្វើទៅលើចំការមីនជាង ៥០០ កន្លែង ។[38]

ក្នុងកំឡុងឆ្នាំ២០០៤ អាជ្ញាធរមីនបានបញ្ចប់ស្តង់ដារសកម្មភាពដោះមីនកម្ពុជាចំនួន១៧ ។ នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៥ ស្តង់ដារចំនួន ៥ត្រូវបានអនុម័តយល់ព្រមដោយលោកនាយកដ្ឋានមន្ត្រី **ហ៊ុន សែន** ។[39] ដោយផ្អែកលើស្តង់ដាទាំងអស់ក្រុមអ្នកប្រតិបត្តិករដោះមីនទាំងអស់ត្រូវដាក់ពាក្យសុំការជឿទុកចិត្ត និងចុះកិច្ចព្រមព្រៀងជាមួយលោកឯកអគ្គរដ្ឋលេខាធិការរបស់អាជ្ញាធរមីន។ ក្រុមប្រតិបត្តិករទាំងឡាយដែលមានស្រាប់មានរយៈពេល៦ខែចេញពីការសំរេចចិត្តរបស់រដ្ឋាភិបាល (ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៥) "ដើម្បី

Draft Report of the Joint Evaluation Mission," UNDP and SIDA, Cambodia, March 2000.
[36] Interview with Clare Brazenor, Project Advisor of MAPU, AVI, 29 April 2005.
[37] CMAA, "Cambodian Strategy and 2005–2009 Plan, presented to Nairobi Summit," 26 January 2005, p. 3: also available at also available at www.cmac.org.kh/FiveYearStrategic.htm.
[38] CMAA, "Mine Action Achievements 1992-2004," 31 March 2005, p. 47.
[39] Royal Government of Cambodia, Decision No. 29 S.S.R. on The Implementation of Cambodian Mine Action Standard (CMAS) First Five Chapters, 10 August 2005, p. 2; email from Sam Sotha, Secretary General, CMAA, 10 August 2005.

រៀបចំឯកសារកិច្ចព្រមព្រៀងដាក់បទបញ្ជាជាផ្លូវការជាមួយនឹងលោកអគ្គលេខាធិការអាជ្ញាធរមីន" ។[40]

មូលដ្ឋានទិន្នន័យស្តីពីសកម្មភាពកំចាត់មីនជាតិ (NMAD) ទទួលបានទិន្នន័យពីការស្រាវជ្រាវផលប៉ះពាល់ដោយសារមីនក៏រិត១ នាឆ្នាំ២០០២( The 2002 Landmine Impact Survey (LIS)) ។ ពេញមួយឆ្នាំ ២០០៤ ប្រទេសកាណាដាបានបន្តផ្តល់មូលនិធិដល់ NMAD ដើម្បីរក្សានិងប្រមូលទិន្នន័យ និងវិភាគទិន្នន័យ ត្រួតពិនិត្យបច្ចេកទេស និងការបោសសំអាតដីដែល ផ្តល់ដោយក្រុមប្រតិបត្តិករ និងដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងពតិមាន ដើម្បីសកម្មភាពកំចាត់មីន (IMSMA) ។[41] ការឧបត្ថម្ភគាំទ្ររបស់ប្រទេសកាណាដា បានបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៤ និង នៅឆ្នាំ ២០០៥ ប្រទេសបារាំងបានបន្តផ្តល់មូលនិធិដល់គំរោងនេះ ។[42]

*ការវាយតំលៃលើសកម្មភាពកំចាត់មីន*

ការវាយតំលៃរួមទៅលើសកម្មភាពកំចាត់មីន នៅក្នុងប្រទេសកម្ពុជាត្រូវបានគេអនុវត្តន៍ធ្វើឡើងនៅឆ្នាំ ២០០៤ សំរាប់ក្រុមការងារអ្នកផ្តល់ជំនួយរបស់ប្រទេសកម្ពុជាដល់សកម្មភាពកំចាត់មីន ។ ការវាយតំលៃនេះ មានគោលបំណងផ្តល់នូវការវាយតំលៃដែលឯករាជ្យលើសមិទ្ធិផល និងបញ្ហាប្រឈមមុខផ្សេងៗរបស់វិស័យសកម្មភាពកំចាត់មីននៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់អនុសាសន៍ជាយុទ្ធសាស្ត្រសំរាប់ការឧបត្ថម្ភគាំទ្ររបស់អ្នកផ្តល់ជំនួយនាពេលអនាគត និង ដើម្បីផ្តល់នូវមូលដ្ឋានគ្រឹះរួមមួយសំរាប់ភាពជាដៃគូរបស់រដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយជាថ្មីឡើងវិញ ។[43] លទ្ធផលរកឃើញសំខាន់ៗគឺថារបៀបដោះស្រាយដែលមានស្រាប់ទាំងឡាយហាក់ដូចជាកំពុងតែធ្វើអោយគេត្រូវការពេលវេលាអតិបរិមា ដើម្បីលុបបំបាត់បញ្ហាមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) មិនមែនដើម្បីដោះស្រាយបញ្ហាក្នុងលក្ខណៈដែលធ្វើអោយមានប្រសិទ្ធភាពលើការចំណាយ និងតំរង់ទិសដៅទៅរកលទ្ធផលទេ ។[44]

ក្រុមវាយតំលៃបានកត់សំគាល់ថា ការបំផ្លិចបំផ្លាញដោយគ្រាប់មីន ក្នុងប្រទេសកម្ពុជាត្រូវបានគេចាត់ទុកជា "បញ្ហាស្របច្បាប់ចេញពីទស្សនៈរបស់សន្និបាតក្រុងអុតតាវ៉ា (The Ottawa Convention) រឺ ថាជាបញ្ហាចំណាប់អារម្មណ៍និយមខាងភូមិសាស្ត្រចេញពីទស្សនៈរបស់ការស្រាវជ្រាវចំការមីនក៏រិត១ (The Level

[40] Royal Government of Cambodia, Decision No. 29 S.S.R. on The Implementation of Cambodian Mine Action Standard (CMAS) First Five Chapters, 10 August 2005, Article 3.
[41] CMAA, "Mine Action Achievements 1992-2004," 31 March 2005, p. 26.
[42] UNDP, "Terms of Reference, Webmaster – CMAA, Project 00011828 – Support to Mine Action Programs," accessed on 22 August at www.un.org.kh/undp.
[43] Robert Griffin and Robert Keeley, "Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action," Volume I, Phnom Penh, 4 December 2004, co-funded by Australia, New Zealand, Sweden, UNICEF and UNDP.
[44] Robert Griffin and Robert Keeley, "Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action," Volume I, Phnom Penh, 4 December 2004, p. 3.

One Survey)"។[45] ក្រុមអ្នកប្រឹក្សាពិគ្រោះយោបល់បានធ្វើការសាកល្បងលើរបៀបដោះស្រាយពាជំហាន។ ដោយផ្តើមចេញពីតំបន់គ្រោះថ្នាក់ដែលគេសង្ស័យមានផ្ទៃដីសរុប ៤,៤៦៦ គ.ម ដោយ LIS តំបន់ តំបន់ដែលផាត់ចេញមានដីដែលមានតំលៃតិចតួចរឺគ្មានទាល់តែសោះ ដីដែលគេបានបោសសំអាតមីនរួច និងដីកំពុងប្រើប្រាស់ ។ តំបន់ដែលនៅសេសសល់មានផ្ទៃក្រលា ៤៦០ $Km^2$ ដែលគេគិតថា ត្រូវតែកាត់បន្ថយអោយកាន់តែច្រើនជាងនេះ បើសិនជាទិន្នន័យស្តីពីការគូសផែនទីបានត្រូវគេធ្វើសមស្របនោះ ។ ជាមួយនឹងការវាយតំលៃពីការបោសសំអាតមីនថ្មីៗនេះ ចំនួននេះអាចប្រហែលជាត្រូវគេបញ្ចប់សព្វគ្រប់ក្នុងរយៈពេលពី ១០ទៅ១៥ឆ្នាំ ដែលក្រុមវាយតំលៃគិតថា ជាការចំណាយមួយដ៏មាន លក្ខណៈគួរអោយ ចាប់អារម្មណ៍ ថែមទៀតចំពោះអ្នកផ្តល់ជំនួយនៅពេលអនាគត និងបច្ចុប្បន្ន ។ ការផ្តល់អនុសាសន៍របស់ក្រុមវាយតំលៃដែលថា តំបន់ទាំងឡាយកំពុងប្រើប្រាស់រួចហើយនិងមិនមានបញ្ហាចំពោះសហគមន៍ដែលមានស្រាប់ហើយនោះ គួរត្រូវលុបចេញពីការពិចារណាធ្វើការបោសសំអាតមីនដែរ។ ការវាយតំលៃនេះបានបន្ទរតាមការវាយតំលៃមួយក្នុងឆ្នាំ២០០៣ សំរាប់ក្រសួងការបរទេសរបស់ចក្រភពអង់គ្លេសសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ ។ ប្រការនេះបានផ្តល់ជាអនុសាសន៍ថា ការព្យាបាលទៅនៅកំរិតផ្សេងៗគ្នា ដូច្នេះហើយការទទួលនូវកំរិតផ្សេងៗនៃគ្រោះថ្នាក់ដែលបានបន្សល់ទុកនោះ គួរតែត្រូវគេផ្តល់ប្រភេទផ្សេងគ្នានូវការប្រើប្រាស់ដីដែរ។[46] របាយការណ៍ប្រចាំឆ្នាំរបស់ HALO សំរាប់ឆ្នាំ ២០០៤ បានកត់សំគាល់ស្រដៀងគ្នា នេះដែរ ។[47]

ការវាយតំលៃរួមសំរាប់ក្រុមអ្នកផ្តល់ជំនួយបានធ្វើយោងទៅនឹងយន្តការផ្តល់មូលនិធិដែលជាទូទៅមិនបានជំរុញអោយមានការទទួលខុសត្រូវ និង ប្រសិទ្ធភាពឡើយ ។ ក្រុមនេះបានផ្តល់អនុសាសន៍ថា មូលនិធិគាំទ្រការដោះមីនគួរតែត្រូវបានគេបង្កើតឡើង ។ កិច្ចព្រមព្រៀងដោះមីន គួរតែឈរលើមូលដ្ឋាននៃការដេញថ្លៃ និង ដោយមានការត្រួតពិនិត្យបច្ចេកទេស និង ហិរញ្ញវត្ថុអោយបានត្រឹមត្រូវនិងម៉ត់ចត់ ។ ដើម្បីគាំទ្រដល់ការធ្វើអោយជាវិមជ្ឈការនូវការកំនត់ជាអាទិភាពសកម្មភាពសំអាតមីននេះ, ប្រភពឥណទានដែលគាំទ្រគួរតែត្រូវបានគេបញ្ជូនទៅបណ្តាសកម្មភាពអាទិភាពតាមខេត្តរបស់អង្គប្រជុំ ដូចដែលបានកំនត់ដោយ PMACs ។ ការសិក្សាមួយបានស្វាគមន៍ការបង្កើតឡើងនូវអង្គភាព MAPUs ពេលដែលអង្គភាពគាំទ្រដល់គោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាល និងសមត្ថភាពរបស់អាជ្ញាធរនៅតាមខេត្ត ដើម្បីរៀបចំផែនការ និង ធ្វើអោយទៅជាអាទិភាពនូវការបោសសំអាតមីនក្នុងលក្ខណៈមួយដែលមានតម្លាភាព។[48]

---

[45] Robert Griffin and Robert Keeley, "Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action," Volume I, Phnom Penh, 4 December 2004, p. 3.
[46] Serco Assurance, "A Risk Strategy for Mine Action," September 2003, available at www.itep.ws/pdf/risk_strategy?dfif.pdf
[47] HALO Trust, "Annual Report 2004 for submission to the CMAA," 21 January 2005, p. 6.
[48] Robert Griffin and Robert Keeley, "Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action," Volume I, Phnom Penh, 4 December 2004, pp. 4-5.

ការវិភាគពីអត្ថប្រយោជន៍ និងការចំណាយរបស់កម្មវិធីបោសសំអាតមីនដែលកម្ពុជាធ្វើឡើងនៅក្នុងឆ្នាំ២០០៤-២០០៥ ដោយ Bjorn Gildestad សំរាប់អាជ្ញាធរមីននិង UNDP បានចង្អុលបង្ហាញថា ការបោសសំអាតមីនកំពុងចូលរួមចំនែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ។ ការវិភាគរបស់កម្មវិធីបោសសំអាតមីន ឆ្នាំ ២០០៤ បានលាតត្រដាងអោយឃើញនូវអត្ថប្រយោជន៍សរុបជាទឹកប្រាក់ជិត ៣៧លានដុល្លាអាមេរិក ដោយត្រូវបានគេបែងចែក ៨០ភាគរយ ទៅលើការបោសសំអាតមីនសំរាប់អភិវឌ្ឍន៍ និង ២០ភាគរយទៀតលើការកាត់បន្ថយការបាត់បង់ជីវិតមនុស្ស។ ដោយឈរលើមូលដ្ឋាននៃតំលៃបោសសំអាតមីនជាមធ្យម ០.៩០ដុល្លាក្នុង១ម$^2$ ការវិភាគបង្ហាញថា អត្ថប្រយោជន៍ពិតដែលទទួលបានពីការដោះមីនជាទូទៅមាន ៣៨ ភាគរយ ច្រើនជាងការចំណាយ ។ ដូច្នេះហើយ ការបោសសំអាតមីនត្រូវ គេពិចារណាថាមានលក្ខណៈសមហេតុផលច្រើនចំពោះហេតុផលសេដ្ឋកិច្ច។ ការវាយតំលៃពីអត្ថប្រយោជន៍និងការចំណាយគួរតែធ្វើអោយកាន់តែមានលក្ខណៈប្រសើរជាងនេះថែមទៀត ជាមួយនឹងការកើនឡើងផលិតភាពក្នុងការបោសសំអាតមីនដែលគេបានរំពឹងទុកក្នុងរយៈពេលពីរ ឬ បីឆ្នាំខាងមុខនេះ ។ តាមការវាយតំលៃលើការបោសសំអាតមីនចេញពីផ្ទៃដីពេលថ្មីៗនេះបានអោយដឹងថា សកម្មភាពដោះមីនទាំងឡាយបានបោសសំអាតមីនលើផ្ទៃដី ចំនួន ២០គ.ម$^2$ សំរាប់ការប្រើប្រាស់ជាប្រយោជន៍ក្នុងប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ។[49]

## ការស្រាវជ្រាវនិងការប៉ាន់ប្រមាណ

ការកំនត់ទំហំនៃបញ្ហាមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងប្រទេសកម្ពុជានៅតែជួបការលំបាក ។ មុនពេលមានការស្រាវជ្រាវផលប៉ះពាល់ដោយសារមីនកំរិត១(Landmine Impact Survey:LIS) បានចាប់ផ្តើមប្រតិបត្តិនៅដើមឆ្នាំ២០០០នោះ គឺមិនមានការត្រួតពិនិត្យ ដែលមានលក្ខណៈតាមវិធីសាស្រ្តណាមួយទេ ទោះបីជាការត្រួតពិនិត្យបច្ចេកទេស ដែលតូចតាចជាងមុនជាច្រើនត្រូវបានគេធ្វើឡើងបន្ទាប់ពីមានសំណើសុំពីប្រជាជនតាមតំបន់ដែលរស់នៅក្នុងតំបន់នានាដែលគេសង្ស័យនោះក៏ដោយ និងមានទិន្នន័យយ៉ាងច្រើនសន្ធឹកត្រូវបានគេរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌលស៊ីម៉ាក់។

ការស្រាវជ្រាវផលប៉ះពាល់ដោយសារមីនកំរិត១ ដែលត្រូវបានគេចេញផ្សាយកាលពីខែ មេសា ឆ្នាំ ២០០២ បានកំណត់ថាមាន ៣,០៣៧តំបន់ ដែលសង្ស័យថាទទួលរងការប៉ះទង្គិចដោយគ្រាប់មីន គ្រាប់រំសេវ និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដទៃទៀតមានផ្ទៃដីសរុប ៤,៤៦៦គីឡូម៉ែត្រការ៉េ។ គេបានធ្វើការប៉ាន់ស្មានថា មានប្រជាជនចំនួន ៥.១៨លាននាក់ ក្នុងភូមិ ចំនួន ៦,៤២២ភូមិ កំពុងជួបគ្រោះថ្នាក់ និងមានភូមិប្រហែល

[49] Bjorn Gildestad, "Cost-benefit Analysis of Mine Clearance Operations in Cambodia," Nordic Consulting Group, February 2005, conducted for CMAA and UNDP, quoted in “Clearing for Results,” article released by UNDP in Phnom Penh on 28 July 2005.

១,៦៤០ភូមិ ជិត១២ភាគរយនៃភូមិទាំងអស់ក្នុងប្រទេសកម្ពុជា ទទួលរងការប៉ះពាល់ដោយសារគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមានកំរិតខ្ពស់ ។ [50]

គេមានការព្រួយបារម្ភណ៍យ៉ាងខ្លាំង ដែលការស្រាវជ្រាវផលប៉ះពាល់ដោយសារមីនកំរិត១ ខកខានមិនបានពិនិត្យលើតំបន់មានមីនច្រើនកន្លែង ។ ស្របជាមួយគ្នានេះដែរពេលអាជ្ញាធរមីនបានបញ្ជាក់ក្នុងរបាយការណ៍សមិទ្ធិផលសំរេចបានឆ្នាំ ១៩៩២-២០០៤ របស់ខ្លួននោះទិន្នន័យនៃការស្រាវជ្រាវផលប៉ះពាល់ដោយសារមីនកំរិត១ ត្រូវតែធ្វើអោយសមស្របទៅតាមនោះដែរ និងធ្វើការត្រួតពិនិត្យដោយអាជ្ញាធរជាតិ និងក្រុមប្រតិបត្តិករដោះមីន ។[51]

*ការកាត់បន្ថយគ្រោះថ្នាក់ :*

HALO TRUST ជឿថាការធ្វើអត្តសញ្ញាណលើដីដែលគេសង្ស័យចំនួនជាង ៤៥០០គីឡូម៉ែត្រការ៉េរបស់ការស្រាវជ្រាវផលប៉ះពាល់ដោយសារមីនកំរិត១ ធ្វើអោយមានការសង្ស័យទៅលើថា តើប្រសិទ្ធិភាពសកម្មភាពកំចាត់មីនមានកំរិតណាក្នុងប្រទេសកម្ពុជា និង មិនបានជំរុញលើកទឹកចិត្តដល់ការប្រើប្រាស់ធនធានបោសសំអាតមីនអោយបានល្អបំផុតទេ ។ តំបន់ជាច្រើនក្នុងប្រទេសកម្ពុជាដែលមិនបង្កអោយមានគ្រោះថ្នាក់នៅតែមានការមន្ទិលសង្ស័យ និងដោយសារបញ្ហាទូទៅមានវិសាលភាពធំធេងនោះ គឺមិនទំនងជាត្រូវបោសសំអាតដោយមធ្យោបាយធម្មតាទេ ។ HALO Trust បានដឹងថាចំនួនសមាមាត្រនៃគ្រាប់មីន ដែលដាក់ពង្រាយដោយរបបខ្មែរក្រហមដែលមានចំនួនច្រើនដែលមិនធ្លាប់មានពីមុនមកលែងមានដំណើរការទៀតហើយ ទោះតាមការពុករលួយធម្មជាតិ រឺ តាមការលុបចោលសមាសភាគដាក់គ្រាប់មីន (ពិសេសសកម្មភាពរបស់ខ្មែរក្រហមនៅក្នុងខេត្តឧត្តមានជ័យ) ក៏ដោយ ។ ការទន្ទ្រានយកដីតាមតំបន់ជាច្រើន កំពុងកើតឡើងដោយគ្មានគ្រោះថ្នាក់ និងបង្ហាញថាប្រភពបោសសំអាតមីនជាផ្លូវការជាច្រើន គួរតែ តំរង់ទិសដៅទៅរកតំបន់ទាំងឡាយដែលគេដឹងថាមានមីនដែលជាទូទៅបង្កគ្រោះថ្នាក់ហួសពីទំហំនៃការខិតខំប្រឹង ប្រែងបោសសំអាតក្នុងតំបន់ ។ [52]

នៅឆ្នាំ២០០៤ អង្គការ HALO Trust បានរាយការណ៍ថា គ្មានភាពច្បាស់លាស់គ្រប់គ្រាន់ទេពីព្រំដែនកំនត់តំបន់មីនដើម្បីធ្វើការគូសចំនាំបរិវេណតំបន់ដែលសង្ស័យមានគ្រាប់មីនអោយមានប្រសិទ្ធិភាព ។ ទោះបីជាអង្គការ HALO Trust នឹងធ្វើការចំណាំផ្លូវប្រសព្វមុខគ្នានិងតំបន់ដែលសង្ស័យថាជាតំបន់មានគ្រោះថ្នាក់ក៏ដោយក៏គ្មានការខិតខំប្រឹងប្រែងធ្វើការហ៊ុំព័ទ្ធបរិវេណដែលសង្ស័យទាំងមូលឡើយ ។ HALO Trust បានគូសចំណាំរាល់

---

[50] Article 7 Report (for calendar year 2003), Form C, 30 April 2004.
[51] CMAA, "Mine Action Achievements 1992-2004," 31 March 2005, p. 13.
[52] Email from Richard Boulter, Programme Manager, HALO Cambodia, 2 September 2005.

ការងារលើចំការមីនបច្ចុប្បន្នទាំងអស់នៅចំនុចមួយដែលការបោសសំអាតមីនបានចាប់ផ្តើម និងគូសចំណាំចំការមីនចំនួន ២៤០ កន្លែងក្នុងឆ្នាំ ២០០៤។[53]

ក្រុមដើរដាក់តំរុយចំណាំគ្រាប់មីនតាមសហគមន៍(CMMTs)របស់អង្គការ CMAC បានដាក់តំរុយសំគាល់មីនលើចំការមីន ចំនួន ១៧២កន្លែងក្នុងរយៈពេលយូរ និង ១០០ កន្លែងក្នុងរយៈពេលខ្លីស្មើនឹង ១៥,០៣២,៩៣០ម$^{២}$ ក្នុងឆ្នាំ២០០៤។[54] CMMTs មានសមាជិក៥រូប បំពាក់ដោយឧបករណ៍រាវមីន ចំនួន២ និងឡានកាមីញ៉ុងធន់តូចមួយគ្រឿង។ ពួកគេផ្តោតការយកចិត្តទុកដាក់តែទៅលើចំការមីន ដែលបានដាក់តំរុយ និង ការបោសសំអាតខ្នាតតូចៗប៉ុណ្ណោះ។

នៅឆ្នាំ ២០០៤ អង្គការ CMAC បានដាក់ពង្រាយក្រុម CMMTs ចំនួន ១៤ក្រុម ដើម្បីប្រតិបត្តិការបោសសំអាតមីនជាអាទិភាពខ្ពស់ដែលបានស្នើសុំដោយសហគមន៍ តាមតំបន់ និង អង្គការអភិវឌ្ឍន៍ក្រៅរដ្ឋាភិបាល (NGOs) ។[55]

## ការបោសសំអាតមីន និង អាវុធជាតិផ្ទុះដែលសេសសល់ពីសង្គ្រាម

តាមមាត្រាទី៥ នៃសន្ធិសញ្ញាហាមប្រាមគ្រាប់មីន ប្រទេសកម្ពុជាត្រូវតែបោសសំអាតមីនប្រឆាំងមនុស្សអោយអស់ក្នុងតំបន់ដែលមានមីនក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន អោយបានឆាប់តាមលទ្ធភាពអាចធ្វើបានតែមិនអោយយូរជាងថ្ងៃទី១ ខែមីនា ឆ្នាំ២០១០ទេ។ នៅខែ មិថុនា ឆ្នាំ ២០០៥ ប្រទេសកម្ពុជាបានជូនដំណឹងដល់បណ្តាភាគីរដ្ឋស្តីពីការហាមប្រាមគ្រាប់មីនថា ខ្លួននឹងស្នើសុំបន្តរយៈពេលកំនត់ត្រឹមឆ្នាំ ២០១០ បើសិនគ្មានមូលនិធិសំរាប់សកម្មភាពកំចាត់មីនថែមទៀតទេនោះ។ [56] បញ្ហានេះត្រូវលើកឡើងម្តង ទៀតនៅខែ សីហា ឆ្នាំ ២០០៥ ដោយអគ្គរដ្ឋលេខាធិការនៃអាជ្ញាធរមីន។[57]

កំឡុងឆ្នាំ ២០០៤ ក្រុមប្រតិបត្តិការ ដោះមីន ចំនួន ៤ក្រុម បានធ្វើការបោសសំអាតមីនលើផ្ទៃដីសរុបចំនួន៣២,០០៦,៨៨៥ម$^{២}$ ដោយកំទេចចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន ៧១,៤៧៥គ្រាប់,គ្រាប់មីនប្រឆាំងរថយន្តចំនួន ១,៧៤២គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន ១៩៤,១៦៣គ្រាប់។[58] នេះគឺជាការកាត់បន្ថយពីផ្ទៃដីចំនួន ៤១,៧៤៦,៥៤១ម$^{២}$ ដែលគេបានបោសសំអាតមីនក្នុងឆ្នាំ២០០៣។[59] តែទោះបីជាយ៉ាង

---

[53] Article 7 Report, Form I, 22 April 2005.
[54] Article 7 Report (for calendar year 2004), Form I, 22 April 2005.
[55] CMAC, “Annual Report 2004,” 28 April 2005, p. 17.
[56] Interview with Sam Sotha, Secretary General, CMAA, at Standing Committee meetings, Geneva, 15 June 2005; interview with Sam Sotha, Secretary General, CMAA, Phnom Penh, 23 August 2005.
[57] Interview with Sam Sotha, Secretary General, CMAA, 23 August 2005.
[58] Article 7 Report, Form F and Annex 4, 22 April 2005.
[59] See *Landmine Monitor Report 2004*, pp. 252-253.

នេះក្តី ប្រទេសកម្ពុជាបានបញ្ចូលទៅក្នុងការធ្វើរបាយការណ៍លើមាត្រាទី៧ របស់ខ្លួន សំរាប់ឆ្នាំ ២០០៤ នូវចំនួនគ្រាប់មីនប្រឆាំងមនុស្សជាច្រើនគ្រាប់។[60] តាមការប្រៀបធៀបលើទំរង់ F និង G (Form F and G ) និងរបាយការណ៏យោង (Annexes of the Article 7) វាបាក់ដូចជាថា គ្រាប់មីនប្រឆាំងមនុស្ស ចំនួន ១៥,៤00គ្រាប់ទៀតដែលគេបាន "រក្សាទុក" នោះ (មិនបានយកទៅប្រើប្រាស់រឺដាក់ក្នុងបន្ទាយ) គឺត្រូវគេកំទេចចោលក្នុង ឆ្នាំ ២០០៤។[61]

ការបោសសំអាត និង ការកំទេចចោលគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងឆ្នាំ ២០០៤ : [62]

| ប្រតិបត្តិករ | ក្រឡាផ្ទៃ(គិតជាម²) | គ្រាប់មីនប្រឆាំងមនុស្ស | គ្រាប់មីនប្រឆាំងរថយន្ត | គ្រាប់មិនទាន់ផ្ទុះ |
|---|---|---|---|---|
| CMAC | ១១,១៩៧,៣៣៦ | ៤៣,៦៣៥ | ៩៣៦ | ១០៦,៣៦០ |
| Halo Trust | ៥,៦៨១,០៥៤ | ២០,០២០ | ៥៤៨ | ១៨,៧០៩ |
| MAG | ២,០៣៩,៤៩៥ | ៦,៦៨៧ | ៥៨ | ១៦,៣៩៤ |
| កងយោធពលខេមរភូមិន្ទ | ១៣,១២៩,០០០ | ១,១៣៣ | ១៦០ | ១២,៧០០ |
| សរុប | ៣២,០០៦,៨៨៥ | ៧១,៤៧៥ | ១,៧៤២ | ១៥៤,១៦៣ |

ផ្ទៃដីជិត ២៨៤លានម² ត្រូវបានបោសសំអាតចាប់តាំងពីមានប្រតិបត្តិការនានាត្រូវបានចាប់ផ្តើមនៅក្នុង ឆ្នាំ ១៩៩២ ។

*មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា* (CMAC):[63] អង្គការស៊ីម៉ាក់ បានបោសសំអាត និង ប្រគល់អោយសហគមន៍ប្រើប្រាស់នូវផ្ទៃដីចំនួន ១១,១៩៧,៣៣៦ម² ដែលប្រើសំរាប់ការសង់លំនៅ កសិកម្ម ផ្លូវថ្នល់ វត្តអារាម មណ្ឌល សុខភាព អណ្តូងទឹក ត្រពាំង ការិយាល័យឃុំ ប្រឡាយទឹក និង សាលារៀន។ មានគ្រួសារសរុបចំនួន ១,១៧១ គ្រួសារ បានទទួលប្រយោជន៍ផ្ទាល់ពីសកម្មភាពបោសសំអាតមីនរបស់អង្គការស៊ីម៉ាក់ក្នុងឆ្នាំ២០០៤ និង មាន ៥៨,២៥៦ គ្រួសារ និង និស្សិតចំនួន ១៥,០៧៨ នាក់ទៀតជាអ្នកទទួលប្រយោជន៍ដោយប្រយោល ។

---

60 Article 7 Report, Form F and Annex 4, 22 April 2005.

61 Form G reports that CMAC destroyed 33,602 antipersonnel mines in mined areas; HALO Trust:16,447; MAG: 4,906. Only the RCAF total is the same in Forms F and G: 1,133. The total of 56,088 antipersonnel mines destroyed in mined areas indicates that stockpile destruction was around 15,400 antipersonnel mines. Figures for destruction of antivehicle mines are similarly skewed.

62 Article 7 Report, Form F and Annex 4, 22 April 2005.

63 CMAC, "Annual Report 2004," 28 April 2005, pp. iii-vii, 13, 32.

នៅឆ្នាំ ២០០៤ ស៊ីម៉ាក់ បានបង្កើតនិងពង្រាយក្រុមដោះមីនដែលមានមូលដ្ឋាននៅតាមសហគមន៍ចំនួន ២ក្រុម ក្នុងស្រុកកំរៀងខេត្តបាត់ដំបងស្ថិតក្រោមការត្រួតពិនិត្យពីអង្គភាពដោះមីន ២ (DU2) ។ សមាជិកក្រុមទាំង ២ ដែលមានពាក់កណ្តាលជាស្ត្រី ត្រូវបានជ្រើសរើសពីគ្រួសារក្រីក្រ និង គ្រួសារដែលងាយទទួលរងគ្រោះជាងគេក្នុងភូមិ អូរអន្លោក និង អូរចំលង នៅតាមមូលដ្ឋាន ។ ក្រុមត្រួតពិនិត្យបច្ចេកទេសចំនួន ៤ ក្រុម បានកាត់បន្ថយផ្ទៃដីចំនួន ១៧,៨៨២,៨០០ម$^{២}$ ពីតំបន់ដែលសង្ស័យមានមីនដែលធ្វើអត្តសញ្ញាណដោយទិន្ន័យស្រាវជ្រាវផលប៉ះពាល់ដោយសារមីនកំរិត១ (LIS) និងបានត្រួតពិនិត្យ និងបោសសំអាតមីនលើផ្ទៃដីសរុបចំនួន២១៨,០៣១ម$^{២}$ ដែលមានផ្ទៃដីចំនួន២៤៧,៤០៩ ម$^{២}$ ត្រូវបានបោសសំអាត។ ក្រុមរបស់អង្គការស៊ីម៉ាក់ក៏បានធ្វើការដាក់ផ្លាកសញ្ញាសំគាល់មីនបាន៤៧៩,០០០ម៉ែត្រនៃចំនួន២៤៧,៤០៩ ដែលត្រូវបានបោសសំអាត។

អង្គការស៊ីម៉ាក់ មានបុគ្គលិកបំរើការចំនួនប្រហែល ២,៤០០នាក់។ នៅបំណាច់ឆ្នាំ ២០០៤ មជ្ឈមណ្ឌលនេះមាន ៤៤ កងអនុសេនាតូច, ក្រុមកាត់បន្ថយគ្រោះ ថ្នាក់ដោយសារមីនចំនួន ៦ក្រុម ក្រុមកំទេចចោលអាវុធជាតិផ្ទុះចំនួន២១ក្រុម ក្រុមដាក់តំរុយមីននិងត្រួតពិនិត្យបច្ចេកទេសចំនួន១៩ក្រុម ក្រុមពិនិត្យបច្ចេកទេស៤ផ្សេង១ទៀត ក្រុមដាក់តំរុយមីនតាមសហគមន៍ចំនួន១៤ក្រុម ក្រុមអប់រំពីគ្រោះថ្នាក់ដោយសារគ្រាប់មីនចំនួន៦ក្រុម មូលដ្ឋានជួបជុំតាមស្រុក ដើម្បីការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីនអាស្រ័យលើសហគមន៍ចំនួន១៣កន្លែង ក្រុមឃ្លាំមើលការរាវរកមីនចំនួន ៨ក្រុម ក្រុមកាប់ ឆ្ការព្រៃចំនួន ១២ ក្រុម ក្រុមដោះមីនមានមូលដ្ឋាននៅតាមសហគមន៍ចំនួន ២ក្រុម និងភ្នាក់ងារធ្វើគំរោង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះចំនួន ២ក្រុម។ បុគ្គលិករបស់អង្គការ ស៊ីម៉ាក់ សរុបចំនួន ១,២៩៨ នាក់ បានទទួលរ៉ាប់រងវគ្គបណ្តុះបណ្តាលចំនួន៩៦វគ្គ ស្តីពីសកម្មភាពកំចាត់មីន នៅឯមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់អង្គការស៊ីម៉ាក់កំឡុងឆ្នាំ ២០០៤ ។

*ជំនួយរបស់ប្រជាជនណ័រវេស (NPA):* NPA បានបន្តផ្តល់ការឧបត្ថម្ភគាំទ្រដល់អង្គការស៊ីម៉ាក់ ក្នុងកំឡុងពេលធ្វើរបាយការណ៏។ ជំនួយនេះបានផ្តល់ទីប្រឹក្សាបច្ចេកទេសសំរាប់គំរោងកាត់បន្ថយគ្រោះថ្នាក់ដោយសារមីនដែលមានមូលដ្ឋាននៅតាមសហគមន៍ដែលគំរោងនេះបានបញ្ចូលអ្នកភូមិទៅក្នុងការធ្វើផែនការ និងការធ្វើអោយទៅជាអាទិភាពនូវសកម្មភាពបោសសំអាតមីន និងលើកទឹកចិត្តពួកគេអោយទទួលរ៉ាប់រងនូវការអប់រំពីគ្រោះថ្នាក់មីនដោយប្រើប្រាស់ប្រភពធនធានផ្ទាល់របស់ខ្លួន។ អង្គការ NPA, អង្គការ MAG និង អង្គការ Handicap International បានរៀបចំការសិក្សាពីការដោះស្រាយដោយយកចិត្តទុកដាក់ទៅលើគ្រាប់មិនទាន់ផ្ទុះនិងទំនាក់ទំនងរបស់ខ្លួនចំពោះការធ្វើជំនួញលើរបស់របរអេតចាយ។ អង្គការ NPA បានរាយការណ៏ថាការសិក្សានេះធ្វើអោយមានការយោគយល់គ្នាកាន់តែប្រសើរជាងមុនរបស់ក្រុមអ្នកដែលងាយទទួលគ្រោះថ្នាក់ជាងគេ និង

ផ្តល់ហេតុផលជាច្រើនសំរាប់ទង្វើ ដែលប្រឈមមុខនឹងគ្រោះថ្នាក់ដោយអចេតនាដែលកើតមានជាច្រើនឆ្នាំមកនេះ។ ការសិក្សានេះបានផ្តល់អនុសាសន៍ពីការសំរបសំរួលកាន់តែប្រសើរជាងមុនរវាងអង្គការអភិវឌ្ឍន៍ក្រៅរដ្ឋាភិបាល (NGOs) ប៉ូលីសជាតិ និង ក្រុមប្រឹក្សានៅតាម សហគមន៍។[64]

អង្គការ NPA បានផ្តល់មូលនិធិនិងត្រួតពិនិត្យលើ DU1 នៃអង្គការ CMAC នៅប៉ៃលិនពាយ័ព្យ និងបានបន្តផ្តល់ជំនួយក្នុងនីតិវិធីដោះមីនរបស់ MAPU ធ្វើអោយទៅជាអាទិភាពនូវដីសំរាប់ដោះមីន។ចាប់តាំងពីខែមីនា ឆ្នាំ២០០៣ មកអង្គការ NPA បានចុះកិច្ចសន្យាដោយអង្គការស៊ីម៉ាក់ ដើម្បីឧបត្ថម្ភដល់ការអភិវឌ្ឍន៍សមត្ថភាពឃ្លាំមើលការរាវរកមីន។ នៅឆ្នាំ២០០៤ អង្គការ NPA បានចុះកិច្ចសន្យាជាមួយទីប្រឹក្សាបច្ចេកទេស ២នាក់ និង អ្នកផ្តល់ប្រឹក្សាយោបល់ជាតិម្នាក់ ដើម្បីធានានូវការធ្វើសមាហរណកម្មកម្មវិធីឃ្លាំមើលប្រកបដោយប្រសិទ្ធិភាពក្នុងរង្វង់ការងាររបស់អង្គការ CMAC។[65]

*អង្គការ HALO Trust:*[66] HALO បានធ្វើការបោសសំអាតផ្ទៃដីចំនួន ៥,៦៨១,០៥៤ម៉ែ² នៅក្នុងខេត្តចំនួន៥ នាឆ្នាំ២០០៤ ជាមួយបុគ្គលិកខ្មែរចំនួន ១,០៧៤ នាក់ (៩២៧នាក់ ជាអ្នកប្រតិបត្តិ, ១៤៧ ជាអ្នកគាំទ្រ)។ អង្គការ HALO Trust មានផ្នែកដោះមីនដោយដៃចំនួន ១០១ផ្នែក អង្គភាពបោសសំអាតមីនដោយម៉ាស៊ីនចំនួន ១៤អង្គភាព ក្រុមកំទេចគ្រឿងផ្ទុះ (EOD) ចំនួន ២ក្រុម និងក្រុមអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនចំនួន១ក្រុម។ ដីបោសសំអាតរួចត្រូវគេយកទៅប្រើប្រាស់សំរាប់ការសង់លំនៅ(១៩%) ផ្លូវចូល(១៤%) កសិកម្ម(៤៤%) ការការពារគ្រោះថ្នាក់(១១%) ទឹក(៧%) និងហេដ្ឋារចនាសម្ព័ន្ធ(៥%)។ ការបោសសំអាតមីនជាមធ្យមប្រចាំថ្ងៃ ចំពោះអ្នកដោះមីនដោយដៃសំរាប់ឆ្នាំនេះបោសសំអាតបាន ២ម៉ែ² ក្នុងមួយនាក់ក្នុងមួយថ្ងៃ ។

ប្រហែល ១/៣ នៃអ្នកដោះមីនទាំងអស់របស់ HALO ត្រូវបានដាក់ពង្រាយទៅតាមភារកិច្ចនៅតំបន់ ក-៥ ពេញមួយឆ្នាំ ២០០៤ ។ ដោយសារវេយិតភាពព្រំដែន ការបោសសំអាតមីនត្រូវបានដាក់កំរិតជាមុនទោះបីជាមីនដែលកប់ផ្តុំគ្នាយ៉ាងច្រើននោះ (ជាមធ្យមប្រហែល ៣,០០០ គ្រាប់ ក្នុង១គម² នៅតាមបណ្តោយក្បាលដី) បានបង្កអោយមានរបួសជាប្រចាំក៏ដោយ។ នៅឆ្នាំ២០០៤ រដ្ឋាភិបាលកម្ពុជាបានបន្ធូរដល់ការដាក់កំរិត ដែលធ្វើអោយអង្គការ HALO Trust អាចធ្វើការបោសសំអាតមីនបានច្រើនទ្វេរដងជាងក្នុងឆ្នាំ ២០០៣ ។

[64] Email from Krishna Uk, Program Officer, NPA Cambodia, 7 June 2005; Richard Moyes, “Tampering: deliberate handling and use of live ordnance in Cambodia,” Phnom Penh, 2004.
[65] Email from Krishna Uk, Program Officer, NPA Cambodia, 7 June 2005.
[66] HALO Trust, “Annual Report 2004, for submission to the CMAA,” 21 January 2005, pp. 1-8.

នៅក្នុងតំបន់ដែលមានមីនកប់ផ្តុំគ្នាច្រើនបំផុត ក្រុមរបស់អង្គការ HALO Trust បោសសំអាតមីនបានដល់ទៅ៣០គ្រាប់ក្នុងមួយថ្ងៃ ។ បញ្ហានេះនឹងនាំអោយមានការចំណាយពេលច្រើនលើសសប់លើការកំទេចចោល និង នាំអោយផលិតភាពធ្លាក់ចុះយ៉ាងខ្លាំង។ នៅបំណាច់ឆ្នាំ២០០៤ អង្គការ HALO Trust បានបំពាក់ឧបករណ៍កិនមីន Pearson ទៅលើត្រាក់ទ័រឈ្មួសដីម៉ាក D6 ក្នុងគោលបំណងដាក់ពង្រាយមុនពេលអ្នកដោះមីនចូលទៅដោះ ហើយតាមរយៈនេះយើងទទួលបានប្រសិទ្ធិភាពទាំងស្រុង។ នៅឆ្នាំ ២០០៤ អង្គការ HALO Trust ក៏បានរាយការណ៍ពីសំភារៈបរិក្ខារចំនួន ៣សំខាន់ៗ ផ្សេងៗ ទៀតមាន Allu Processing Bucket (SMH), Tampest Mark 5 Group Engaging Flail និង ត្រាក់ទ័កាត់បន្លែដែលផ្នែកខាងក្រោយធ្វើដោយ Ford-New Holland ។

ក្នុងការផ្សារភ្ជាប់គោលបំណងរបស់ខ្លួន ទៅនឹងការបោសសំអាតមីនអោយបានឆាប់រហ័សលើតំបន់កសិកម្មដែលមានគ្រោះថ្នាក់កំរិតទាបនោះ នាបំណាច់ឆ្នាំ២០០៤, HALO បានចាប់ផ្តើមធ្វើការសាកល្បងទៅលើ Tampest Mark 5 ដែលផលិតក្នុងស្រុកជាមួយនឹងក្បាល Ground Engaging Flail។ ក្នុងដំណាក់កាលជាច្រើនបន្ទាប់មកទៀត អង្គការ HALO Trust នឹងធ្វើប្រតិបត្តិការជាមួយអង្គការ MAG និង Internal Testing and Evaluations Process(ITEP) ក្នុងដំណើរការជាការសាកល្បង។ ការសាកល្បងនេះគឺដើម្បីត្រួតពិនិត្យពីប្រសិទ្ធិភាពខាងការចំណាយព្រមទាំងប្រសិទ្ធិភាពខាងប្រតិបត្តិ។

ដើម្បីឆ្លើយតបទៅនឹងការកើនសមាមាត្រនៃគ្រោះថ្នាក់ដោយគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ នៅកំឡុងឆ្នាំ២០០៤ អង្គការ HALO Trust បានបង្កើតក្រុមEODចុះត្រួតពិនិត្យជាប្រចាំទី២មួយក្រុម។ ប្រការនេះត្រូវគេរាយការណ៍ថា មានជោគជ័យធំធេងណាស់ក្នុងការតាមដានពីយុទ្ធភ័ណ្ឌទាំងឡាយមុនពេលបង្កអោយមានរបួស ។ នៅបំណាច់ឆ្នាំ ២០០៤ អង្គការ HALO Trust បានវិលត្រលប់ទៅកាន់បរិវេណដែលគេបោះបង់ចោលនៅប៉ោយប៉ែត ជាកន្លែងដែលបញ្ហាគ្រឿងផ្ទុះត្រូវគេជ្រើសរើសធ្វើអាជីវកម្ម លោហៈអេតចាយនោះ កើតមានឥតឈប់ឈរ ។ ក្នុងឆ្នាំ ២០០៥ អង្គការ HALO Trust បានដាក់ពង្រាយក្រុមកំទេចគ្រឿងផ្ទុះ (EOD) នៅតាមតំបន់ប៉ោយប៉ែតដោយមានមូលដ្ឋានអចិន្រ្តៃយ៍ ចេញពីទីតាំងស្រុកថ្ម ពួក សំរោង អន្លង់វែង និង សៀមរាប ។ នៅឆ្នាំ ២០០៤ HALO បានដាក់ពង្រាយក្រុម EOD ចល័តចំនួន ២ក្រុមនៅពាសពេញតំបន់ពាយ័ព្យនៃប្រទេសកម្ពុជា។ ជារួមក្រុម EOD បានបញ្ចប់ការងារបោសសំអាតមីនបានចំនួន ៦៥០គ្រាប់ និង យុទ្ធភ័ណ្ឌមិនផ្ទុះចំនួន ១៦,៦០៨គ្រាប់ (៣,៦៣២គ្រាប់ជាមីនប្រឆាំងមនុស្ស, ៤២២គ្រាប់ជាមីនប្រឆាំងរថក្រោះ) ។

អង្គការ HALO Trust បានសហការជាមួយកងយោធពលខេមរភូមិន្ទដើម្បីបោសសំអាតឃ្លាំងអាវុធមួយកន្លែងនៅខេត្តសៀមរាបដែលមានគ្រឿងផ្ទុះរាប់ពាន់មុខស្ថិតក្នុងសភាពគ្រោះថ្នាក់ និង សភាពទ្រុឌទ្រោមខ្លាំង។នៅខែ មីនា ឆ្នាំ ២០០៤ HALO ត្រូវបានចុះកិច្ចសន្យាដោយក្រសួងការបរទេសសហរដ្ឋអាមេរិកអោយបំផ្លាញចោលឃ្លាំង ២៣៤ SAM7 Mar Portable Air Defense System របស់ប្រទេសកម្ពុជា ។

អង្គការ HALO រាយការណ៍ថា ខ្លួននឹងស្វាគមន៍នូវសេចក្តីណែនាំរបស់ PMACs និងមើលឃើញសាវនកម្មផ្ទៃក្នុងនោះថាជាការថែមតំលៃទៅលើនីតិវិធីនៃការជ្រើសរើសការងារ។ អង្គការ HALO ជឿថាវាមានសារៈសំខាន់ណាស់ ដែលអង្គការធ្វើផែនការថ្មីទទួលស្គាល់ពីសារៈសំខាន់នៃការប្រើប្រាស់ដីព្រៃក្នុងលក្ខខ័ណ្ឌពិសេស, ដូច្នេះហើយប្រភពធនធានក្នុងការបោសសំអាតមីនត្រូវតំរង់ទិសដៅរកកន្លែង ដែលមានអត្ថប្រយោជន៏ភាគច្រើនត្រូវគេសំរេចបានដោយងាយស្រួលនោះ។ អង្គការ HALO Trust បានចូលរួមក្នុងការបោសសំអាតមីន ដែលជាផ្នែកមួយរបស់គំរោងអភិវឌ្ឍន៏តំបន់ជនបទ ប៉ែកពាយ័ព្យរបស់ប្រទេសកម្ពុជា (NRDP) និងគំរោងហេដ្ឋារចនាសម្ព័ន្ធតាមខេត្ត (Provincial Infrastructure Project) ក្នុងលក្ខខ័ណ្ឌដែលរដ្ឋាភិបាលផ្តល់មូលនិធិដល់ការបោសសំអាតមីននាពេលអនាគត។ ក្នុងខែមករាឆ្នាំ ២០០៥, HALO បានរាយការណ៍ថា ខ្លួនកំពុងចរចាពីកិច្ចសន្យាជាមួយ NRDP ដើម្បីផ្តល់ជំនួយដល់សេចក្តីត្រូវការក្នុងការបោសសំអាតមីនរបស់គំរោងនេះក្នុងឆ្នាំ ២០០៥ ។

អង្គការ HALO Trust បានរាយការណ៍ពីគ្រោះថ្នាក់តូចតាចនៅក្នុងចំការមីន និងគ្រោះថ្នាក់ដ៏ធំមួយនៅក្រៅចំការមីនកំឡុងឆ្នាំ២០០៤។ នៅថ្ងៃទី ៩ ខែ មករា នាយកប្រតិបត្តិដោះមីនម្នាក់បានស្លាប់ពេលមានបំណងបើកគ្រាប់មីនប្រឆាំងរថយន្ត TM - ៤៦ មួយគ្រាប់ជាមួយនឹងឧបករណ៏កាត់រនុកឧស្សាហ៏កម្ម។ នៅថ្ងៃទី ១៣ ខែ កក្កដា មេបញ្ជាការផ្នែកបានបោះចោលដោយអចេតនានូវកិបគ្រាប់បែកដៃមួយគ្រាប់ទៅក្នុងក្រហូងលោហៈមួយ ដែលបណ្តាលអោយវាផ្ទុះ និងបង្កររបួសតិចតួចលើជើងស្តាំរបស់គាត់។ មានគ្រោះថ្នាក់មួយទៀតកើតឡើង នៅថ្ងៃទី ១៦ ខែ កញ្ញា តែមិនបង្កររបួសដល់អ្នកដោះមីនទេ ។

អង្គការដោះមីន MAG:[67] ឆ្នាំ២០០៤, MAG បានរាយការណ៍ថាមានផ្ទៃដីចំនួន ២,០៣៩,៤៩៥ ម$^{២}$ បានធ្វើការបោសសំអាត និង គ្រាប់មីនប្រឆាំងមនុស្សចំនួន ៦,៦៨៧ គ្រាប់ និង មីនប្រឆាំងរថយន្តចំនួន ៥៨ គ្រាប់បានកំទេចចោល។ អង្គការ MAG មានបុគ្គលិកជាតិបំរើការចំនួន៥០០នាក់ និង បរទេសចំនួន ៣នាក់ក្នុងកម្មវិធីនៃប្រទេសកម្ពុជានាឆ្នាំ២០០៤។ អង្គការ MAG បានដាក់ពង្រាយក្រុមសកម្មភាពកំចាត់មីនដែលមានច្រើនជំនាញចំនួន ២៣ក្រុម ក្រុមកំទេចគ្រឿងផ្ទុះ (EOD) ចំនួន ៣ក្រុម ក្រុមសម្ព័ន្ធការ

[67] Information provided by Rupert Leighton, Country Manager, MAG Cambodia, 25 August 2005.

តាមសហគមន៍ (Community Liaision) ចំនួន ៧ក្រុម និង ម៉ាស៊ីន Tempest mini-flail ចំនួន ៥គ្រឿង ។ ក្រុមកំចាត់មីននានា ត្រូវបានដាក់ពង្រាយជាអចិន្ត្រៃយ៍នៅបណ្តាខេត្តចំនួន៥ មានខេត្តបាត់ដំបង ពោធិសាត់ ក្រុងប៉ៃលិន កំពង់ធំនិងព្រះវិហារ ទន្ទឹមពេលក្រុមកំទេចគ្រឿងផ្ទុះ ត្រូវបានដាក់ពង្រាយបន្ថែមនៅក្នុងខេត្តកំពង់ចាម។ អង្គការ MAG បានអភិវឌ្ឍន៍សមត្ថភាព ក្រុមកំទេចគ្រឿងផ្ទុះរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការកើនឡើងគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះ (UXO) នាឆ្នាំ២០០៤។ អង្គការ MAG បន្តប្រើប្រាស់ក្រុមសម្ព័ន្ធការតាមសហគមន៍ ដើម្បីធ្វើការទាក់ទងរវាងសហគមន៍ដែលទទួលរងគ្រោះ និង ការឆ្លើយតបទៅកាន់ពួកគេវិញ ។

នៅខែ ធ្នូ ឆ្នាំ ២០០៤ សមាជិកក្រុម EOD របស់ MAG ម្នាក់បានស្លាប់ និង ២នាក់របួសក្នុងការផ្ទុះគ្រាប់មីនមិនទាន់ផ្ទុះ។ ការស៊ើបអង្កេតបានលាតត្រដាងអោយដឹងថា ក្រុមអ្នកដោះមីនបានបំពានដោយចេតនាលើនីតិវិធីប្រតិបត្តិជាប្រចាំនិង ធ្វើការដោះគ្រាប់មីនមិនទាន់ផ្ទុះយកទៅលក់ជារបស់របរអេតចាយ ។

កងយោធពលខេមរភូមិន្ទ(RCAF): កងយោធពលខេមរភូមិន្ទបានបោសសំអាតមីនលើផ្ទៃដីចំនួន១៣,១២៩,១៣៦ម$^{២}$ រួមមានភូមិមួយកន្លែងនៅតាមព្រំដែនកម្ពុជា-ឡាវ (ចំនួន ១,៤៨៣,៩៨៩ម$^{២}$) ដីសំរាប់សំនង់ស្ពាននិងថ្នល់ (៨,៨៨៣,៣៩៦ម$^{២}$) ប្រព័ន្ធជលវិទ្យា (១,៧០១,៧៥១ម$^{២}$) និង រោងចក្រវ៉ារីអគ្គិសនីមួយកន្លែង (ចំនួន១,០៦០,០០០ម$^{២}$)។ RCAF មានបុគ្គលិកដោះមីនចំនួន ៩៦០នាក់ ដែលមាន ៨២១ នាក់នៅក្នុងអង្គភាព UXO និងបោសសំអាតមីន អ្នកផ្តល់ការណែនាំ និង មន្ត្រីគ្រប់គ្រងចំនួន ១២១នាក់ និង បុគ្គលិក EOD ចំនួន ១៨នាក់។[68]

មជ្ឈមណ្ឌលអន្តរជាតិសំរាប់ការដោះមីនដើម្បីមនុស្សធម៌របស់ទីក្រុងសឺណែវ (GICHD) បានចេញផ្សាយជាសាធារណៈនូវការសិក្សាពីតួនាទីរបស់យោធាក្នុងសកម្មភាពកំចាត់មីន ដែលរួមមានការសិក្សាលើករណីប្រទេសកម្ពុជាផងដែរ ។ ការសិក្សាបានបញ្ជាក់ថា RCAF "បានរាយការណ៍ពីការវាយតំលៃការបោសសំអាតមីនថានៅឆ្ងាយពីអ្វីដែលច្រើនលើសលប់ ដែលសំរេចបានដោយភ្នាក់ងារកំចាត់មីនដទៃទៀតក្នុងប្រទេសកម្ពុជា។ របាយការណ៍បានអះអាងថា មិនមានគ្រោះថ្នាក់កើនឡើងដោយសារការបោសសំអាតមីននិងគ្រាប់មីនមិនទាន់ផ្ទុះទេ។ របាយការណ៍ទាំងនេះ មិនអាចធ្វើការផ្ទៀងផ្ទាត់បានទេ និងនៅតាមសហគមន៍កំចាត់មីនស៊ីវិលត្រូវគេគិតថាមិនអាចទុកចិត្តបានទៀតផង។" [69]

---

[68] RCAF, "Report to Mine Action Achievements Conference," 28 April 2005 (pages not numbered).
[69] GICHD, "The Role of the Military in Mine Action," Geneva, 2003, p. 68, available at www.gichd.ch.

ការវាយតំលៃមួយនៅឆ្នាំ ២០០៤ លើផ្នែកសកម្មភាពកំចាត់មីនក្នុងប្រទេសកម្ពុជា បានចោទជាសំនួរចំពោះសមត្ថភាពនៃ RCAF ដើម្បីធ្វើសកម្មភាពបោសសំអាតមីនអោយស្របតាមស្តង់ដារអន្តរជាតិ។ ការវាយតំលៃនេះ បានផ្តល់អនុសាសន៍ថា បុគ្គលិកទាហានអាចមានលទ្ធភាពចុះកិច្ចសន្យាដោយក្រុមអ្នកប្រតិបត្តិការដោះមីនជាលក្ខណៈពាណិជ្ជកម្មដែលមានសមត្ថភាព (តាមរយៈការផ្ទេរទៅកាន់តំណែងពិសេសណាមួយ វីរំសាយ) ដែលជាទំរង់នៃការហ្វឹកហ្វឺនការងារ ។ ជាជំរើសជំនួយបច្ចេកទេសអន្តរជាតិគួរតែត្រូវតែស្នើសុំដើម្បីធ្វើការអភិវឌ្ឍន៍សមត្ថភាពក្នុងជួរកងទ័ព ។ ប៉ូលីសត្រូវតែផ្តល់យោបល់ថា ជាអង្គភាពមានលក្ខណៈសក្តិសមច្រើន សំរាប់ការអភិវឌ្ឍន៍សមត្ថភាព EOD ជាតិក្នុងរយៈពេលយូរ ។[70]

*ការដោះមីនដោយអ្នកភូមិ*

ការបោសសំអាតមីនដោយអ្នកដោះមីនក្រៅផ្លូវការរីតាមភូមិបានបន្តកើតមានក្នុងទ្រង់ទ្រាយធំក្នុងប្រទេសកម្ពុជា ។ បុគ្គលមួយចំនួន បោសសំអាតមីន ដើម្បីធ្វើកសិកម្ម និង ដើម្បីធានាអោយបាននូវសន្តិសុខខាងផ្នែកសេដ្ឋកិច្ច និង រាងកាយដល់គ្រួសារពួកគេ ។ អ្នកខ្លះទៀតបានជួលអ្នកដោះមីនតាមភូមិ ដើម្បីបោសសំអាតដីឱ្យពួកគេ។ ក្រុមអ្នកស្រាវជ្រាវត្រួតពិនិត្យមីន បានជួបជាមួយអតីតសមាជិករបស់ភ្នាក់ងារបោសសំអាតមីនជាច្រើននាក់ដែលឥឡូវនេះមានការពាក់ព័ន្ធក្នុងតួនាទីនេះ។ កិច្ចពិភាក្សាពីវិធីដែលត្រូវដោះស្រាយលើសកម្មភាពបោសសំអាតមីននានាដោយអ្នកភូមិបានបន្តចាប់តាំងពីដើមទសវត្សឆ្នាំ១៩៩០ និងនៅតែគ្មានដំណោះស្រាយនៅឡើយ ។[71]

គំរោងសាកល្បងមួយធ្វើឡើងដោយអង្គការ MAG និង អាជ្ញាធរតាមមូលដ្ឋាននៅក្នុងស្រុកកំរៀង និង ភ្នំព្រឹក (ខេត្តបាត់ដំបង) គឺមានគោលបំណងធ្វើការហ្វឹកហ្វឺនអ្នកទាំងនោះនូវស្តង់ដាដូចដែលអង្គការ MAG បានហ្វឹកហ្វឺនដល់អ្នកដោះមីន និងប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ដែលទទួលរងការប៉ះពាល់ដោយសារមីន។ ប្រជាពលរដ្ឋ ៤០នាក់ បានទទួលការហ្វឹកហ្វឺនពីខែ មករា ដល់ខែ សីហា ឆ្នាំ ២០០៤ ។ វិធីដោះស្រាយចំពោះ"សកម្មភាពដោះមីនតាមមូលដ្ឋាន"នេះបានផ្តល់គុណសម្បត្តិជាច្រើនដូចជាការចំណាយតិចការគ្រប់គ្រងមានលក្ខណៈល្អប្រសើរជាងមុន និងបានបង្កើនប្រាក់ចំណូលអោយដល់ប្រជាពលរដ្ឋដែលក្រីក្របំផុតមួយចំនួនក្នុងសហគមន៍ដែលទទួលការប៉ះពាល់ដោយសារគ្រាប់មីន។[72]

---

[70] Robert Griffin and Robert Keeley, "Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action," Volume I, Phnom Penh, 4 December 2004, p. 4.

[71] For more details see *Landmine Monitor Report 2001*, p. 446, and *Landmine Monitor Report 2004*, p. 257.

[72] Email from Tim Carstairs, MAG, 5 October 2004; information provided by Rupert Leighton, Country Manager, MAG Cambodia, 25 August 2005.

ចាប់ពីខែ កញ្ញា ឆ្នាំ ២០០៤ ដល់ ខែមករា ឆ្នាំ ២០០៥ ការសិក្សាមួយរៀបចំធ្វើឡើងដោយ Handicap International គឺដើម្បីកំណត់ពីរបៀបដែលអង្គការសកម្មភាពកំចាត់មីននានា គួរតែឆ្លើយតបអោយបានល្អបំផុតចំពោះសកម្មភាពអ្នកដោះមីននៅតាមភូមិ។ ការសិក្សានេះធ្វើឡើងដោយក្រុមមួយមានសមាជិក ៤នាក់ ដឹកនាំដោយនរវិទូម្នាក់ ។ របាយការណ៍ដែលចេញផ្សាយជាសាធារណៈនៅខែ ឧសភា ឆ្នាំ ២០០៥ បានចោទជាសំនួរលើសកម្មភាពអាទិភាព និង វិធីសាស្ត្រការងាររបស់ផ្នែកសកម្មភាពកំចាត់មីន និងបានផ្តល់អនុសាសន៍ថា អ្នកដោះមីននៅតាមភូមិ គួរតែត្រូវគេទទួលស្គាល់ជាផ្លូវការថា ជាសមាសភាគស្ថាបនិក និង ស្របច្បាប់របស់ផ្នែកសកម្មភាពកំចាត់មីន។[73]

ការសិក្សានេះ បង្កអោយមានការ រិះគន់ និង ភាពចំរូងចំរាស់គ្នាយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា ជាពិសេសពីអង្គការស៊ីម៉ាក់ (CMAC) [74] ។ ការសិក្សាក៏បានបង្ហាញផងដែរថា មានកិច្ចខិតខំប្រឹងខ្លាំងក្លា ដើម្បីធ្វើការតាំងលំនៅលើដី ដែលបានដោះមីនដោយក្រុមអ្នកដោះមីនក្រៅផ្លូវការនៅតាមភូមិ និង ដើម្បីធ្វើប្លង់ដីដោយប្រើបច្ចេកវិទ្យា GPS។ ក្នុងការបង្កើនប្រសិទ្ធិភាពលើការងាររបស់អ្នកដោះមីនក្រៅផ្លូវការនោះតាមមធ្យោបាយបច្ចេកទេសត្រួតពិនិត្យដ៏សមស្របទាំងឡាយដែលត្រូវគេយកមកប្រើប្រាស់ ដើម្បីអោយដឹងប្រាកដច្បាស់ថា មានចំនួនឧប្បត្តិហេតុប៉ុន្មានដែលកើតឡើងលើដីដែលបានដោះមីនពីមុនៗ ដោយពួកអ្នកដោះមីនក្រៅផ្លូវការនៅតាមភូមិ។ ការសិក្សានេះក៏បានផ្តល់អនុសាសន៍ថា ដីដែលបានដោះមីនតាមមធ្យោបាយនេះ គួរតែត្រូវបញ្ចូលទៅក្នុងប្រភពទិន្នន័យជាតិ រឺ បញ្ចូលក្នុងប្រភពទិន្នន័យបន្ទាប់បន្សំ ហើយថាបុគ្គលិកទាំងឡាយគួរតែមានសេរីភាពក្នុងការកំនត់យកដីជាកម្មសិទ្ធផ្ទាល់ខ្លួន ដោយគ្មានការដាក់កំរិត, គ្មានការប្តេជ្ញា, ការសន្យាជាក់ស្តែងណាមួយជាមួយរដ្ឋាភិបាល និងផ្នែកសកម្មភាពកំចាត់មីនក្នុងការធ្វើការងារនេះទេ ហើយថាសំភារៈបរិក្ខា និងការហ្វឹកហ្វឺន ដ៏សមស្របគួរតែត្រូវបានគេផ្តល់អោយ ។

## ការអប់រំអំពីគ្រោះថ្នាក់មីន

អង្គការចំនួន៧ បានជាប់ទាក់ទិនទៅនឹងការអប់រំស្តីអំពីគ្រោះថ្នាក់ដោយសាមីន (MRE) នៅក្នុងឆ្នាំ ២០០៤។ អង្គការស៊ីម៉ាក់, អង្គការកាកបាទក្រហមកម្ពុជា, អង្គការ HALO Trust, អង្គការទស្សនៈពិភពលោក បានបន្តប្រតិបត្តិកម្មវិធីដែលមានលក្ខណៈប្រហែលគ្នាទៅនឹងឆ្នាំមុន, អង្គការ UNICEF បានបន្តផ្តល់នូវការឧបត្ថម្ភ ហើយអង្គការ Save Camodia's wildelife បានផ្តើមធ្វើនូវគំរោងការថ្មីមួយគឺការអប់រំអំពីគ្រោះ

[73] Michael L. Fleisher, “Informal Village Demining in Cambodia an Operational Study,” HI, Phnom Penh, May 2005.

[74] See for instance email to wider mine action community from Heng Rattana, Deputy Director, CMAC, 11 May 2005.

ថ្នាក់ដោយសារមីន និងការអភិរក្សបរិស្ថាន។[75] អង្គការទាំងនេះបានរាយការណ៍ផ្តល់នូវការអប់រំពីគ្រោះថ្នាក់មីនដល់ប្រជាជន៦០០,០០០នាក់ ដោយរាប់បញ្ចូលទាំងការចុះទៅសួរសុខទុក្ខភ្លាមៗនូវមនុស្សទាំងឡាយដែលរស់នៅក្នុងសហគមន៍ដែលត្រូវបានកំនត់អោយទទួលនូវការអប់រំពីគ្រោះថ្នាក់មីនក្នុងឆ្នាំមុនៗ។[76]

អាជ្ញាធរមីន(CMAA)គឺទទួលបន្ទុកក្នុងការសំរបសំរួលខាងការអប់រំពីគ្រោះថ្នាក់មីន។ នាខែមករា ឆ្នាំ ២០០៤, អង្គការ UNICEF បានផ្តល់ប្រាក់សំរាប់អ្នកធ្វើការនៅផ្នែកសំរបសំរួលការអប់រំពីគ្រោះថ្នក់មីនពេញម៉ោងដែលស្ថិតតាំងនៅក្នុងអាជ្ញាធរមីនកម្ពុជា ហើយបានបន្តផ្តល់នូវការឧបត្ថម្ភដទៃទៀត ដោយរួមបញ្ចូលទាំងជំនួយសំរាប់បញ្ចប់ការធ្វើផែនការយុទ្ធសាស្ត្រក្នុងការអប់រំពីគ្រោះថ្នាក់មីនឆ្នាំ២០០៤-២០០៩។ យុទ្ធសាស្ត្រគឺមានទិសដៅបង្កើននូវសមត្ថភាពរបស់សហគមន៍ដែលទទួលរងគ្រោះថ្នាក់មីននិងគ្រាប់មិនទាន់ផ្ទុះ ដើម្បីសហការជាមួយនឹងការដោះមីន,ជំនួយដល់ជនរងគ្រោះ និង កម្មវិធីអភិវឌ្ឍន៍សហគមន៍ដើម្បីពង្រឹងនូវការសំរបសំរួលលើការអប់រំពីគ្រោះថ្នាក់មីនជាតិ បង្កើនការផ្សព្វផ្សាយនូវការអនុវត្តល្អបំផុតតាមរយៈការធ្វើសមាហរណកម្មនូវការអប់រំគ្រោះថ្នាក់មីន ដែលមាននៅក្នុងសកម្មភាពមីន និង ដើម្បីបញ្ចូលការអប់រំពីគ្រោះថ្នាក់មីនទៅក្នុងកម្មវិធីសិក្សាក្នុងបឋមសិក្សា។[77]

ស្តង់ដាគំរូនៃសកម្មភាពកំចាត់មីន អន្តរជាតិ (IMAS) សំរាប់ការអប់រំផ្នែកគ្រោះថ្នាក់មីន (MRE) គឺត្រូវបានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ជាការនាំផ្លូវដល់ការប្រតិបត្តិដោយពួកអ្នកប្រតិបត្តិការអប់រំពីគ្រោះថ្នាក់មីននីមួយៗ។ នៅក្នុងខែ មិថុនា ឆ្នាំ ២០០៥ ស្តង់ដារសកម្មភាពកំចាត់មីនទាំងនោះគឺត្រូវបានគេប្រតិបត្តិតាម។ ការអភិវឌ្ឍន៍នូវស្តង់ដានៃសកម្មភាពកំចាត់មីនកម្ពុជា សំរាប់ការអប់រំពីគ្រោះថ្នាក់មីនគឺមិនត្រូវបានគេឃើញថាមានលក្ខណៈចាំបាច់ទេហើយក៏គ្មានផែនការដើម្បីអភិវឌ្ឍន៍នូវកម្មវិធីទាំងនេះឡើយ។[78]

នៅក្នុងខែ មិនា ឆ្នាំ ២០០៥, អាជ្ញាធរមីន បានកត់សំគាល់ឃើញថា ដំណើរផ្លាស់ប្តូរនៃគ្រោះថ្នាក់មីន និងគ្រាប់មិនទាន់ផ្ទុះ មានការពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការអប់រំពីគ្រោះថ្នាក់មីននៅក្នុងប្រទេសកម្ពុជា។ គ្រោះថ្នាក់មីនកើតឡើងយ៉ាងច្រើនតាមព្រំដែន ថៃ-កម្ពុជា ត្រង់តំបន់ខ្សែក្រវ៉ាត់ ក-៥ ទន្ទឹមនេះដែរក៏មានគ្រោះថ្នាក់ស្លាប់មនុស្សដែលបណ្តាលមកពីគ្រាប់មិនទាន់ផ្ទុះគឺ កើតនៅកន្លែងដទៃទៀតដែរ។ ខេត្តបាត់ដំបងគឺនៅតែជាខេត្តមួយ ដែលរងឥទ្ធិពលយ៉ាងខ្លាំងបំផុត, ចំណែក ឯខេត្តកំពង់ចាម, សៀមរាប, កំពង់ធំ, កំពង់ស្ពឺ, ស្វាយរៀង, កណ្តាល និងក្រចេះ ក៏មានគ្រោះថ្នាក់មនុស្ស ស្លាប់មួយចំនួនធំដែរ។[79] ក្មេងប្រុស

---

75 Email from Chan Rotha, MRE Focal Point CMAA, 24 June 2005.
76 Email from Sam Sotha, Secretary General, CMAA, 15 January 2005.
77 CMAA "Cambodia Mine Risk Education Strategy (2005-2009)," 10 November 2004, pp. 3-5.
78 Email from Chan Rotha, MRE Focal Point, CMAA, 24 June 2005.
79 CMAA, "Mine Action Achievements 1992-2004," 31 March 2005, p. 14.

ដែលមានអាយុពី ១០ឆ្នាំ ដល់ ១៥ឆ្នាំ និង បុរសទាំងឡាយណាដែលមានអាយុពី ២៥ឆ្នាំ ដល់ ៣៥ឆ្នាំ គឺជាក្រុមមនុស្សដែលអាចជួបនឹងគ្រោះថ្នាក់បំផុត។ ៧៨% នៃគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រាប់មិនទាន់ផ្ទុះ គឺបណ្តាលមកពីការរុករើលេង និង ការច្នៃយកមកប្រើប្រាស់ដោយចេតនា។[80]

នាឆ្នាំ ២០០៤-២០០៥ អង្គការស៊ីម៉ាក់ បានប្រើប្រាស់នូវការអប់រំពីគ្រោះថ្នាក់មីនដែលត្រូវបានឧបត្ថម្ភឡើងតាមរយៈយុទ្ធនាការប្រើប្រាស់គ្រឿងផ្សាយពតិមានធំៗស្តីពីការយល់ដឹងពីមីនចល័ត យុទ្ធនាការសហគមន៍អប់រំពីគ្រោះថ្នាក់មីន (CBMRR) និងយុទ្ធនាការរបស់អង្គការក្រៅរដ្ឋាភិបាល (NGO)។[81] យុទ្ធនាការដោយប្រើគ្រឿងផ្សាយពតិមានធំៗ ដោយរួមបញ្ចូលទាំងការផលិតតាមស្ថានីយ៍ទូរទស្សន៍ដោយផ្សព្វផ្សាយ ៣២០ដង ហើយនិងស្ថានីយវិទ្យុ និង វលកធាតុអាកាស ៨៤០ដង[82] ព្រមជាមួយដោយការដាក់តាំងនូវផ្ទាំងបដាថ្មី២៦ នៅក្នុងខេត្តចំនួន៨។ អង្គការ ស៊ីម៉ាក់ ប៉ាន់ស្មានថាមាន ៩៧ភាគរយនៃប្រជាជនកម្ពុជាមានលទ្ធភាពមើលតាមទូរទស្សន៍ ហើយ ៧៦ ភាគរយ គឺមានលទ្ធភាពស្តាប់វិទ្យុ។ អង្គការ ស៊ីម៉ាក់ជឿជាក់ថាការផ្តល់ការអប់រំពីគ្រោះថ្នាក់មីនតាមរយៈគ្រឿងផ្សព្វផ្សាយពតិមាន គឺមានប្រសិទ្ធិភាពសំរាប់ការផ្សព្វផ្សាយដំណឹងកាន់តែមានឥទ្ធិពលឡើងជាពិសេសនៅក្នុងខេត្តដែលនៅមានបញ្ហាមីន និង គ្រាប់មិនទាន់ផ្ទុះ ហើយជាកន្លែងដែលមិនមានសកម្មភាពមីន។[83]

អង្គការ ស៊ីម៉ាក់ បានបង្កើតក្រុមពតិមានចល័តស្តីពីមីនចល័ត ៦ក្រុម (ដែលក្រុមនីមួយៗគឺមានអ្នកដឹកនាំក្រុម១រូប អ្នកបើកបរ១រូប និងអ្នកបង្រៀនអំពីគ្រោះថ្នាក់មីន២រូប) ដែលត្រូវបានពង្រាយដើម្បីឆ្លើយតបទៅនឹងកត្តានៃស្ថានការណ៍ ដូចជាការផ្លាស់ប្តូរទីកន្លែងរបស់ប្រជាពលរដ្ឋទៅកាន់តំបន់ដែលអាចនឹងមានគ្រោះថ្នាក់បំផុត ការកើនឡើងនៃគ្រោះថ្នាក់ដោយសារមីន ឬ គ្រាប់មិនទាន់ផ្ទុះ។[84] នៅក្នុងឆ្នាំ ២០០៤ ពួកគេបានធ្វើដំណើរទៅកាន់ភូមិចំនួន៧០៤ភូមិដោយផ្តល់ការបង្ហាញចំនួន៨១៤ដង ដល់អ្នកដែលមានចំនួន ១៤២,៨៩៧នាក់។ ចាប់ពីឆ្នាំ២០០១មក អង្គការស៊ីម៉ាក់ បានកាត់បន្ថយចំនួនក្រុមអប់រំពីគ្រោះថ្នាក់មីនតាមស្តង់ដារ និង បានបង្កើនការផ្សព្វផ្សាយពី សហគមន៍អប់រំពីគ្រោះថ្នាក់មីនមូលដ្ឋាន (Community-Based Mine Risk Reduction:CBMRR)។[85]

---

[80] Richard Moyes,"Tampering: deliberate handling and use of live ordnance in Cambodia," Phnom Penh 2004, p. 14. Another source reported that, in 2004, 58 percent of casualties were due to tampering with UXO. Chiv Lim, Project Manager, CMVIS, 1 August 2005.
[81] CMAA, "Cambodia Mine Risk Education Strategy (2005–2009)," 10 November 2004, p. 10.
[82] Email from Sam Sotha, Secretary General, CMAA, 15 January 2005.
[83] Email from Sam Sotha, Secretary General, CMAA, 15 January 2005.
[84] Email from Chan Rotha, MRE Focal Point, CMAA, 24 June 2005.
[85] CMAC, "Annual Report 2004," 28 April 2005, p. 7.

សហគមន៍អប់រំពីគ្រោះថ្នាក់មីនមូលដ្ឋាន បានអភិវឌ្ឍន៍ក្នុងស្មារតីទទួលស្គាល់ថា ប្រជាជនជាច្រើនដែលរស់នៅក្នុងតំបន់រងគ្រោះដោយសារមីននៃប្រទេសកម្ពុជា គឺតែងតែដឹងថាពួកគេគឺកំពុងតែប្រព្រឹត្តនូវទង្វើប្រកបដោយគ្រោះថ្នាក់តែការខ្វះខាតខាងដីធ្លីនិងសម្ពាធធនធានដទៃទៀត គឺបង្ខំអោយពួកគេប្រព្រឹត្តផ្សងនឹងហេតុការណ៍ដែលអាចមានគ្រោះថ្នាក់។[86] ការអប់រំពីគ្រោះថ្នាក់មីន គឺត្រូវការដំណោះស្រាយដែលបាញ់ឆ្ពោះទៅរកសហគមន៍ក្នុងរយៈពេលវែង គឺមានទិសដៅដើម្បីកាត់បន្ថយនូវគ្រោះថ្នាក់ដោយសារគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះមួយចំនួនដោយការបញ្ជាក់ពីសម្ពាធនៃខ្វះខាតក្នុងជីវភាពចិញ្ចឹមជីវិត ដែលនាំមកនូវការផ្សងនឹងគ្រោះថ្នាក់។[87]

ក្រុមសហគមន៍អប់រំពីគ្រោះថ្នាក់មីនមូលដ្ឋាន សហការយ៉ាងជិតជិតជាមួយនឹងអង្គការស៊ីម៉ាក់, ការអប់រំពីគ្រោះថ្នាក់មីននិងក្រុមកាត់បន្ថយគ្រោះថ្នាក់ដោយប្រើបច្ចេកទេស ហើយមានមូលដ្ឋានជួបជុំតាមស្រុកចំនួន១៣កន្លែង ដែលមានការទាក់ទងគ្នាឋិតក្នុងស្រុកនីមួយៗក្នុងចំណោមស្រុកទាំងឡាយដែលត្រូវប្រតិបត្តិការដោយសហគមន៍អប់រំពីគ្រោះថ្នាក់មីនមូលដ្ឋានក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងតំបន់ប៉ៃលិន។ មូលដ្ឋានជួបជុំទាំងនេះគឺធ្វើការនៅក្នុងភូមិទាំងឡាយដែលទទួលឥទ្ធិពលអំពីមីន និងគ្រាប់មិនទាន់ផ្ទុះ ដោយឧបត្ថម្ភជនស្ម័គ្រចិត្តទាំងឡាយអោយបង្កើតនូវគណៈកម្មការមីន និងគ្រាប់មិនទាន់ផ្ទុះ ។ មកដល់ខែ មេសា ឆ្នាំ ២០០៥ មានអ្នកតំណាងអោយជនស្ម័គ្រចិត្ត ៣០៤រូប ជាមួយគណៈកម្មការថ្នាក់ភូមិនិងស្រុកបានបង្កើតនូវបណ្តាញការងារកាត់បន្ថយគ្រោះថ្នាក់មីន ដែលធ្វើឡើងដោយអ្នកស្ម័គ្រចិត្ត។ របៀបចូលរួមគឺត្រូវបានប្រើប្រាស់ ដើម្បីបញ្ជាក់អំពីរបៀបដែលមីននិងគ្រាប់មិនទាន់ផ្ទុះ ជះឥទ្ធិពលទៅលើភូមិនីមួយៗដែលនឹងត្រូវបោសសំអាតមីន និង គ្រាប់មិនទាន់ផ្ទុះ។ ពត៌មាននេះគឺត្រូវបានប្រើប្រាស់ដើម្បីដាក់ផែនការបោសសំអាតមីននិងធ្វើការសុំនូវធនធានអភិវឌ្ឍន៍។ តំបន់សំរាប់ឧបត្ថម្ភទាំងឡាយត្រូវបានកំណត់ច្បាស់ហើយនោះសេវាផ្នែកអប់រំពីគ្រោះថ្នាក់មីន ដែលសមរម្យគឺត្រូវបានស្នើរសុំ។បណ្តាញការងារសហគមន៍អប់រំពីគ្រោះថ្នាក់មីនមូលដ្ឋាន ក៏បានផ្តល់នូវពត៌មានទំនាក់ទំនងផ្នែកមីន និងគ្រាប់មិនទាន់ផ្ទុះដល់សេវាខាងប្រមូលទិន្នន័យដូចជា Cambodian Mine Victim Information System(CMVIS) និង អង្គភាពផែនការការងារសកម្មភាពមីន( Mine Action Planning Units) ដែរ ។[88] ដោយការប្រើប្រាស់នូវដំណោះស្រាយនេះផ្ទៃដី ៩៤៥,២៣៤ ម$^{២}$ គឺត្រូវបានបោសសំអាត ហើយភ្នាក់ងារដោះមីនដែលទទួលខុសត្រូវចំពោះសំណើរ

---

[86] CMAC, "Annual Report 2004," 28 April 2005, p. 7.

[87] CMAC website, accessed on 22 June 2005 at www.cmac.org.kh/Activities_Awareness.htm. The CBMRR project began in October 2001, implemented by CMAC with technical assistance from HI and UNICEF. Email from Chan Rotha, MRE Focal Point, CMAA, 24 June 2005.

[88] Email from Chan Rotha, MRE Focal Point, CMAA, 24 June 2005.

អំពីបណ្តាញ CBMRR បានបំផ្លាញមីន និងគ្រាប់មិនទាន់ ផ្ទុះជិត ៦,០០០គ្រាប់ នៅក្នុងឆ្នាំ ២០០៤។[89] តំលៃនៃកម្មវិធីប្រចាំឆ្នាំដែលត្រូវបានប៉ាន់ស្មាននោះគឺ ៣៨២,០០០ ដុល្លាអាមេរិក។[90]

នៅក្នុងខែ មេសា ឆ្នាំ ២០០៤ អង្គការ ស៊ីម៉ាក់ បានបង្កើតនូវគំរោងការថ្មីមួយគឺការកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះនៅតាមសហគមន៍ (CBURR) ដែលប្រតិបត្តិការក្នុងមធ្យោបាយដូចគ្នា នឹង កម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះនៅតាមសហគមន៍ ប៉ុន្តែនៅក្នុងតំបន់ណាដែលប្រកបដោយគ្រោះថ្នាក់បំផុតអំពីគ្រាប់ដែលមិនទាន់ផ្ទុះ។ ក្រោយពីគំរោងការសាកល្បងពីខែឧសភាដល់តុលាឆ្នាំ២០០៤ ក្នុងពេលឥឡូវនេះកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះនៅតាមសហគមន៍ គឺដំណើរការពេញលេញនៅក្នុងស្រុកអង្គស្នួល(ខេត្តកណ្តាល) និង នៅក្នុងស្រុកច្បារមន (ខេត្តកំពង់ស្ពឺ)។ ការចុះពិនិត្យដល់ទីកន្លែងគឺបានធ្វើឡើងបានចំនួន៥,៣៥៣ គ្រួសារ។[91] ថវិកាប្រចាំឆ្នាំដែល ត្រូវបានគេសង្ឃឹមទុកជាមុននោះ គឺ ៦៣,០០០ ដុល្លាសហរដ្ឋអាមេរិក។[92]

ក្នុងឆ្នាំ ២០០៤ រហូតដល់ ខែ មីនា ឆ្នាំ ២០០៥ បុគ្គលិកនៃអង្គការក្រៅរដ្ឋាភិបាលចំនួន ១១៦នាក់ដែលបំរើការនៅតាមតំបន់ដែលទទួលការប៉ះពាល់ដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះបានទទួលការបណ្តុះបណ្តាលចំណេះដឹងស្តីពីមីនដែលផ្តល់ដោយអង្គការ ស៊ីម៉ាក់។[93]

ក្នុងកំឡុងឆ្នាំ ២០០៤ អង្គការកាកបាទក្រហមកម្ពុជា បានបន្តនូវកម្មវិធីអប់រំពីគ្រោះថ្នាក់មីនរបស់ខ្លួនដែលបានបើកនៅក្នុងឆ្នាំ ២០០០ ដោយបានផ្តល់នូវការអប់រំពីគ្រោះថ្នាក់មីនបានដល់ប្រជាជនចំនួន ១១៧,០៣៣ នាក់ នៅក្នុងខេត្តចំនួន ៦គឺ បន្ទាយមានជ័យ, បាត់ដំបង, ឧត្តរមានជ័យ, ក្រុងប៉ៃលិន, ព្រះវិហារ និងពោធិសាត់។ គំរោងនេះគឺផ្តោតទៅលើការផ្លាស់ប្តូរផ្នែកទង្វើផ្សេងៗក្នុងចំណោមក្មេងៗ និងមនុស្សវ័យជំទង់ដែលឃ្វាលសត្វ និងមនុស្សពេញវ័យដែលស្វែងរកផ្លែឈើ និងធនធាននៅក្នុងព្រៃនៅពេលដែលមានការបង្កើនសមត្ថភាពរបស់អ្នកដឹកនាំសហគមន៍ ដើម្បីផ្សព្វផ្សាយនូវសេចក្តីណែនាំអំពីគ្រោះថ្នាក់ដោយសារមីន។ តំលៃនៃកម្មវិធីប្រចាំឆ្នាំ គឺ ប្រហែលជា ១០០,០០០ ដុល្លារអាមេរិក។[94]

ពេញមួយឆ្នាំ២០០៤ក្រុមដែលមានមនុស្ស ៣នាក់ របស់អង្គការ HALO Trust បានផ្តល់នូវការអប់រំពីគ្រោះថ្នាក់មីន ដើម្បីឧបត្ថម្ភដល់ការបោសសំអាតកន្លែងមានមីន។ ការផ្តល់ប្រឹក្សាគឺត្រូវបានផ្តល់ជូនក្នុងពេលថ្ងៃតាមសាលារៀន និងដល់ក្រុមនៃមាតានិងបុត្រ ហើយពេលល្ងាចផ្តល់ដល់យុវជន។ ក្រុមនេះបាន

---

89 CMAC, "Annual Report 2004," 28 April 2005, p. 8.
90 CMAA, "Cambodia Mine Risk Education Strategy (2005-2009)," 10 November 2004, p. 7.
91 CMAC, "Annual Report 2004," 28 April 2005, p. 10.
92 CMAA, "Cambodia Mine Risk Education Strategy (2005-2009)," 10 November 2004, p. 9.
93 Email from Chan Rotha, MRE Focal Point, CMAA, 1 September 2005.
94 CMAA, "Cambodia Mine Risk Education Strategy (2005-2009)," 10 November 2004, p. 8.

ប្រើប្រាស់នូវការប្រឹក្សាណែនាំតាមរយៈទូរទស្សន៍ ដែលរួមបញ្ចូលមិនត្រឹមតែការអប់រំពីគ្រោះថ្នាក់មីនប៉ុណ្ណោះទេ តែក៏មានទាំងបញ្ហាសុខភាពសាធារណៈ និង ពតិមានទាក់ទិននឹងកសិកម្មផងដែរ ។ កម្មវិធីអប់រំពីគ្រោះថ្នាក់មីនបានបង្កើតនូវការទាក់ទងផ្នែកសហគមន៍ ដោយមានការបញ្ជាក់អោយឃើញអំពីរបៀបដែលសហគមន៍អាចចូលរួមចំណែកនូវការបោសសំអាតមីនដូចជា ដោយការរក្សាទុកសញ្ញាសំគាល់មីនឬការមិនធ្វើកសិកម្ម ក្បែរនឹងក្រុមបោសសំអាតមីនពេក ។ កំឡុងឆ្នាំ២០០៤ ក្រុមនេះបានផ្តល់នូវការប្រឹក្សាណែនាំអំពីការគ្រោះថ្នាក់មីនដល់អ្នកស្រុក២៦,៤២៤នាក់ ស្ថិតនៅក្នុងសហគមន៍ដែលទទួលរងគ្រោះថ្នាក់ដោយសារមីន ហើយត្រូវការទឹកប្រាក់ប្រមាណប្រហែលជា ១៥,០០០ដុល្លារអាមេរិក ។[95] អង្គការ HALO Trust មានគោលបំណងរក្សាចំនួននេះអោយនៅថេរសំរាប់ឆ្នាំក្រោយៗទៀត ។[96]

នៅក្នុងឆ្នាំ ២០០៤ អង្គការ MAG បានបើកក្រុមសម្ព័ន្ធការតាមសហគមន៍ចំនួន ១១ ក្រុម ដោយក្រុមនីមួយៗគឺត្រូវបានបង្កើតឡើងដោយមានមនុស្ស២នាក់ ។ចំនួន៦ក្រុមនៃក្រុមនេះបានធ្វើប្រតិបត្តិការនៅក្នុងតំបន់នៃខេត្តបាត់ដំបងរហូតដល់ក្រុងប៉ៃលិននិងតំបន់ខេត្តពោធិសាត់ ហើយចំនួន៥ក្រុមទៀតបានធ្វើប្រតិបត្តិការនៅក្នុងតំបន់នៃខេត្តព្រះវិហារ ។ ក្រុមទាំងនេះបានធ្វើសេចក្តីណែនាំដល់ប្រជាជនប្រហែល១៤,០០០នាក់ ។ ក្រុមនៃសកម្មភាពកំចាត់មីនក៏បានផ្តល់នូវប្រឹក្សាណែនាំអំពីគ្រោះថ្នាក់មីនដល់អ្នកដែលត្រូវផ្តល់ដល់មនុស្សចំនួន៧,៦១៣នាក់ ។[97]

អង្គការ World Vision បានបង្កើតនូវកម្មវិធីអប់រំពីគ្រោះថ្នាក់មីន ដោយមានគោលបំណងធ្វើសមាហរណកម្មសកម្មភាពមីននិងរចនាសម្ព័ន្ធតាមសហគមន៍ ។ អង្គការក៏បង្កើតនូវសកម្មភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងកសិកម្ម ហើយផ្តល់នូវការអប់រំពីគ្រោះថ្នាក់មីនដល់អ្នកភូមិដែលជាប់ទាក់ទិននឹងសកម្មភាពទាំងនោះ ។ នៅក្នុងឆ្នាំ២០០៤ ក្រុមទាំងឡាយនោះបានផ្តល់ការអប់រំពីគ្រោះថ្នាក់មីនដល់អ្នកភូមិចំនួន៥,១១២នាក់ដែលត្រូវការថវិកាកម្មវិធីប្រចាំឆ្នាំប្រហែលជា ៦៥,០០០ ដុល្លារអាមេរិក ។[98]

ក្នុងឆ្នាំ២០០៥ ដោយមានការផ្តល់មូលនិធិពីសំណាក់អង្គការ Care International, អង្គការ Save Cambodia Wildlife ក៏បានបើកនូវកម្មវិធីអប់រំពីគ្រោះថ្នាក់មីន និងគំរោងការអភិរក្សបរិស្ថាននៅក្នុងតំបន់ខាងជើងផងដែរ ។ កម្មវិធីគឺដើម្បីផ្តល់នូវការអប់រំពីគ្រោះថ្នាក់មីនតាមភូមិដែលជាផ្នែកនៃកម្មវិធីបរិស្ថានធំធេង និងការឧបត្ថម្ភដល់ក្រសួងអប់រំយុវជននិងកីឡានៅតាមតំបន់ស្រុកខេត្ត ។ថវិកាដែលសង្ឃឹមទុកសំរាប់ឆ្នាំ២០០៥ គឺ ៣៨,០០០ ដុល្លារអាមេរិក ។[99]

---

[95] HALO Trust, "Annual Report 2004 for submission to the CMAA," 21 January 2005, p. 4.
[96] CMAA, "Cambodia Mine Risk Education Strategy (2005-2009)," 10 November 2004, p. 10.
[97]
[98] CMAA, "Cambodia Mine Risk Education Strategy (2005-2009)," 10 November 2004, p. 9.
[99] CMAA, "Cambodia Mine Risk Education Strategy (2005-2009)," 10 November 2004, p. 10.

ក្នុងឆ្នាំ២០០៤ ក្រោមការត្រួតពិនិត្យរបស់ក្រសួងអប់រំ គ្រូចំនួន៤,៧៩១ នាក់ មកពីសាលាបឋមសិក្សា រដ្ឋបានផ្តល់នូវសេចក្តីណែនាំក្នុង៣៨ស្រុកដែលទទួលរងប៉ះពាល់ដោយសារគ្រាប់មិនទាន់ផ្ទុះនិងមីនខ្លាំងបំផុត ដល់សិស្សបឋមសិក្សាចំនួន២១៩,៨៧៨នាក់ ។ ក្រៅពីនេះទៀតសិស្សដែលទទួលការហ្វឹកហាត់ចំនួន៥,០១០នាក់ បានផ្តល់នូវការអប់រំពីគ្រោះថ្នាក់មីនដល់កុមារដែលមិនចូលសាលាចំនួន១១,៧៦៣នាក់និងមាតាបិតារបស់ពួកគេ ។[100]

## មូលនិធិនិងជំនួយសំរាប់សកម្មភាពមីន

ប្រទេសចំនួន ១៣ និងគណៈកម្មការអឺរ៉ុប (EC) បានរាយការណ៍ថា បានបរិច្ចាគប្រាក់ហែលជា ៤១,៦៥២,៩២១ដុល្លារ សំរាប់សកម្មភាពមីននៅកម្ពុជាក្នុងឆ្នាំ២០០៤ ។ នេះគឺច្រើនជាងទ្វេដងនូវការផ្តាច់មូលនិធិដែលរបាយការណ៍ត្រួតពិនិត្យមីនបានរាយការណ៍សំរាប់ឆ្នាំ២០០៣ (ខ្លះ១៧លានដុល្លារអាមេរិក)[101] ហើយច្រើនជាងអាជ្ញាធរមីនកម្ពុជាបានរាយការណ៍ ដែលជាការចំណាយទៅលើសកម្មភាពមីនក្នុងឆ្នាំ ២០០៤ ។[102]

ភាពកើនឡើងមួយធំបំផុតក្នុងមូលនិធិបរិច្ចាគគឺមកពីប្រទេសជប៉ុនដោយមានភាពកើនឡើងដល់ទៅ៥ដង ។ ប្រទេសផ្តល់ជំនួយអន្តរជាតិដែលរួមមាន :

- ប្រទេសអូសាស្រ្តលី: A$ ៤,១៦៧,០១៣ (៣,០៦៩,០០៥ដុល្លាអាមេរិក) កំឡុងឆ្នាំសារពីពន្ធរបស់ខ្លួន, ដោយមាន២លានដុល្លារអូស្រ្តាលី (១,៤៧៣,០០០ដុល្លា) ដល់អង្គការស៊ីម៉ាក់; ១,៩៧៩,២៤៧ ដុល្លាអូស្រ្តាលី (១,៤៣៧,៧១៥,៤២ដុល្លា) សំរាប់សកម្មភាពមីនដែលត្រូវបានបញ្ចូល ហើយនិង ១៨៧,៧៦៦ ដុល្លារអូស្រ្តាលី (១៣៨,២៨៧.៦៦ ដុល្លា) ដល់អង្គការ MAG សំរាប់ម៉ាស៊ីនដោះមីន ។[103]
- ប្រទេសប៊ែលហ្សិក:៥០៦,១២០ហ្វ្រង់(៦២៩,៥១២ដុល្លា) ដោយមាន៤០១,១២០ហ្វ្រង់ត (៤៩៨,៩១៣ដុល្លា) ដល់អង្គការស៊ីម៉ាក់សំរាប់ការបង្កើតនូវសមត្ថភាពខាងការបោសសំអាតគ្រាប់មិនទាន់ផ្ទុះ និង ១០៥,០០០ ហ្វ្រង់(១៣០,៥៩៩ដុល្លា) ដោយត្រូវបានប៉ាន់ស្មានថាជា ការផ្តល់ជាបែបផែននូវទីប្រឹក្សាបច្ចេកទេសដល់ អង្គការស៊ីម៉ាក់ ។[104]
- ប្រទេសកាណាដា:៣,៦០៨,៩២៩ដុល្លាកាណាដា(២,៧៧២,៤៧២ដុល្លាអាមេរិក) ដោយមាន២៤៩,៣៧២ ដុល្លាកាណាដា (១៩១,៥៧៤ដុល្លាអាមេរិក) ដល់អង្គការ Oxfam Quebec សំរាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកដែលនៅរស់ពីមីន, ៣៥៩,១៣៤ដុល្លាកាណាដា(២៧៥,៨៩៦ ដុល្លាអាមេរិក) ដល់អង្គការ

[100] CMAA, “Mine Action Achievements 1992-2004,” 31 March 2005, p. 49.
[101] See *Landmine Monitor Report 2004*, p. 260.
[102] CMAA, “Mine Action Achievements 1992-2004,” 31 March 2005, p. 6.
[103] Email from Doug Melvin, AusAID, 17 June 2005. Average exchange rate for 2004: $1 = A$0.7365 used throughout this report. US Federal Reserve, “List of Exchange Rates (Annual),” 3 January 2005. Differences exist between Australian funding reported for the fiscal year July 2004 to June 2005 and Australia’s 2004 Article 7 Report, 3 May 2005, which reports for the 2004 calendar year.
[104] Article 7 Report, Form J, 2 May 2005.

World Vision ប្រទេសកាណាដា សំរាប់សកម្មភាពមីន ដែលត្រូវបានបញ្ចូល ៣៧៤,៤៣៧ ដុល្លាកាណាដា (២៨៧,៦៥២ ដុល្លាអាមេរិក) ដល់អង្គការ Geo-Spatial សំរាប់ការវាយតំលៃ និង ការដាក់ផែនការការងារ។ ២,៥០០,០០០ ដុល្លាកាណាដា ( ១,៩២០,៥៦៥ដុល្លា អាមេរិក) ដល់អង្គការ UNDP សំរាប់ការអភិវឌ្ឍន៍កសិកម្មក្នុងតំបន់ដែលរងការប៉ះពាល់មីន ១១០,៩០០ ដុល្លាកាណាដា (៨៥,១៩៦ ដុល្លាអាមេរិក) ដល់អង្គការ MAG សំរាប់ក្រុមកំទេចគ្រឿងផ្ទុះនិង ១៥,០៨៦ ដុល្លាកាណាដា (១១,៥៨៩ ដុល្លាអាមេរិក) ដើម្បីសិប្បកម្មទាំងឡាយ។[105]

- សហគមន៍អឺរ៉ុប:៥,១៧០,០០០ហ្វ្រង់ (៦,៤៣០,៤៤៦ដុល្លាអាមេរិក) សំរាប់ការបោសសំអាតមីននិងកម្មវិធីអប់រំពីគ្រោះថ្នាក់មីន ។[106]
- ប្រទេសហ្វាំងឡង់ដ៏: ១,០២០,០០០ហ្វ្រង់ (១២៦,៨៦៧ដុល្លាអាមេរិក) ដោយមាន ១០០,០០០ហ្វ្រង់ (១២៤,៣៨០ដុល្លា) ដល់អង្គការ HI សំរាប់កម្មវិធីស្រង់ស្ថិតិអំពីគ្រោះថ្នាក់ដោយសារមីន ៦៧០,០០០ហ្វ្រង់ (៨៣៣,៣៤៦ ដុល្លាអាមេរិក) ដល់អង្គការ HALO សំរាប់កម្មវិធីបោសសំអាតមីន ២៥០,០០០ ហ្វ្រង់ (៣១០,៩៥០ ដុល្លាអាមេរិក) ដល់អង្គការ Finish Church Aid សំរាប់ការបោសសំអាតមីន។[107]
- ប្រទេសបារាំង: ២៥៥,០០០ហ្វ្រង់ (៣១៧,១៦៩ ដុល្លាអាមេរិក) ដោយមាន ៥៥,០០០ ហ្វ្រង់ (៦៨,៤០៩ ដុល្លាអាមេរិក) សំរាប់ការបណ្តុះបណ្តាលនិង ២០០,០០០ហ្វ្រង់ (២៤៨,៧៦០ ដុល្លាអាមេរិក) ដល់ស្ថាប័នអាជ្ញាធរមីនកម្ពុជាសំរាប់កម្មវិធីដោះមីន។[108]
- ប្រទេសអាល្លឺម៉ង់:៦៧០,០០០ហ្វ្រង់(៨៣៣,៣៤៦ដុល្លាអាមេរិក)ដល់ស្ថាប័នអាជ្ញាធរមីនកម្ពុជា /អង្គការស៊ីម៉ាក់ សំរាប់កម្មវិធីបោសសំអាតមីនក្នុងខេត្តសៀមរាប និង ឧត្តរមានជ័យ។[109]
- ប្រទេសជប៉ុន:២,០២១,១០០,០០០យ៉េន(១៨,៦៨៧,៩៣៣ដុល្លា) ដោយមាន ១,៨៧០,២០០,០០០ យ៉េន (១៧,២៩២,៦៤៩ ដុល្លាអាមេរិក) ដល់អង្គការ ស៊ីម៉ាក់, ១,៧៦១,០០០,០០០ យ៉េន (១៦,២៨២,៩៤០ ដុល្លាអាមេរិក) សំរាប់ការបោសសំអាតមីន និង ៦៣,៤០០,០០០ យ៉េន (៥៨៦,២២៣ ដុល្លាអាមេរិក) និង ១៤៥,៨០០,០០០ យ៉េន (៤២៣,៤៨៦ ដុល្លាអាមេរិក) សំរាប់មូលនិធិទូទៅ ៧៥,៤០០,០០០ (៦៩៧,១៨០

[105] Mine Action Investments database; emails from Elvan Isikozlu, Mine Action Team, Foreign Affairs Canada, June-August 2005. Average exchange rate for 2004: US$1 = C$1.3017, used throughout this report. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2005.

[106] European Community's Contribution to the Landmine Monitor 2005, by email from Nicola Marcel, RELEX Unit 3a Security Policy, European Commission, 19 July 2005.

[107] Mine Action Investments database. Email from Teemu Sepponen, Ministry of Foreign Affairs, 13 July 2005.

[108] Email from Amb. Gerard Chesnel, Ministry of Foreign Affairs, 30 June 2005; emails from Anne Villeneuve, HI, July-August 2005.

[109] Article 7 Report, Form J, 15 April 2005; email from Dirk Roland Haupt, Federal Foreign Office, Division 241, 25 July 2005.

ដុល្លាអាមេរិក) ដល់អង្គការ HALO Trust សំរាប់ការបោសសំអាតមីនហើយ៧៥,៥00,000យ៉េន (៦៩៨,១0៤ ដុល្លាអាមេរិក) អំពីការបោសសំអាតមីន ។[110]

- លុចហ្សាំបួរ : ៤0,000 ហ្វ្រង់ (៤៩,៧៥២ ដុល្លារ) សំរាប់ជំនួយដល់ជនរងគ្រោះ ។[111]
- ប្រទេសនេតឡែនះ ១,២៥៤,៨៧0,00 ហ្វ្រង់ (១,៥៦0,៨0៧ ដុល្លាអាមេរិក) ដោយមាន ៦៨៩,៤៣៥ ហ្វ្រង់ (៨៥៧,៥១៩ ដុល្លាអាមេរិក) ដល់អង្គការ NPA សំរាប់សកម្មភាពបោសសំអាតមីន ហើយ ៥៦៥,៤៣៥ ហ្វ្រង់ (៧0៣,២៨៨ ដុល្លាអាមេរិក) ដល់ អង្គការ HALO Trust សំរាប់កម្មវិធីបោសសំអាតមីន ។[112]
- ញូស៊ីលែនដ៍ះ ៣៥២,៤0៨.00 ហ្វ្រង់ (២៣៤,១0៥ ដុល្លាអាមេរិក) ដោយមាន ៨៩,៦៨១ ដុល្លាញូស៊ីលែន (៥៩,៥៧៥ដុល្លាអាមេរិក) ដល់អង្គការស៊ីម៉ាក់ តាមរយៈមូលនិធិបំរុងរបស់អង្គការ UNDP សំរាប់ការដោះមីន ៦១,៧២៧ ដុល្លាញូស៊ីលែន (៤១,00៥ ដុល្លាអាមេរិក) សំរាប់ជំនួយជនរងគ្រោះថ្នាក់មីននៃសាលា Cambodia School of Prosthetics និង Orthotics ហើយ ២0១,000 ដុល្លាញូស៊ីលែន (១៣៣,៥២៤ ដុល្លាអាមេរិក) ដល់ Cambodia Trust Fund សំរាប់សេវាកែច្នៃ ។[113]
- ប្រទេសន័រវេ ២,៧00,000 Nok (៤00,៥៩៩ ដុល្លាអាមេរិក) ដោយមាន ១,៥00,000 Nok (២២២,៥៥៥ ដុល្លាអាមេរិក) ដល់អង្គការស៊ីម៉ាក់ តាមរយៈ UNDP និង១,២00,000 Nok (១៧៨,0៤៤ ដុល្លាអា មេរិក)ដល់ Save the children for Save the Children សំរាប់ការបោសសំអាតមីននៅជុំវិញសាលារៀន ។[114]
- ប្រទេសស៊្វីសះ ១២,000,000 SEK (១,៦៣៣,0៩៧ ដុល្លាអាមេរិក) ដល់អង្គការ ស៊ីម៉ាក់[115]
- សហរដ្ឋអាមេរិកះ ៣,៧៦៦,000ដុល្លា ដោយមាន ៣,៤៦៦,000 ដុល្លា ពីក្រសួងការបរទេស និង ៣00,000 ពីក្រសួងការពារជាតិ ។[116]

---

[110] Email from Kitagawa Yasu, Japanese International Campaign to Ban Landmines (JCBL), 10 August 2005, with translation of Ministry of Foreign Affairs information sent to JCBL 11 May 2005. Average exchange rate for 2004: ¥108.15 =US$1 used throughout this report. US Federal Reserve, “List of Exchange Rates (Annual),” 3 January 2005.

[111] Email from Francois Berg, Disarmament Desk, Ministry of Foreign Affairs, 2 August 2005.

[112] Email from Freek Keppels, Arms Control and Arms Export Policy Division, Ministry of Foreign Affairs, 4 August 2005.

[113] Letter from Charlotte Darlow, Disarmament Division, Ministry of Foreign Affairs and Trade, 20 April 2005, and email from Jane Coster, Ministry of Foreign Affairs and Trade, New Zealand, 11 August 2005. Average exchange rate for 2004: $1 = NZ$0.6643 used throughout this report. US Federal Reserve, “List of Exchange Rates (Annual),” 3 January 2005.

[114] Article 7 Report, From J, 28 April 2005; emails from May-Elin Stener, Section for Humanitarian Affairs, Department for Global Affairs, Ministry of Foreign Affairs, April-May 2005. Average exchange rate for 2004: $1 = NOK6.7399, used throughout this report. US Federal Reserve, “List of Exchange Rates (Annual),” 3 January 2005.

[115] Letter from Alf Eliasson, SIDA, 23 March 2005. Average exchange rate for 2004: $1 = SEK7.4380, used throughout this report. US Federal Reserve, “List of Exchange Rates (Annual),” 3 January 2005.

[116] USG Historical Chart containing data for FY 2004, by email from Angela L. Jeffries, Financial Management Specialist, U.S. Department of State, Bureau of Political-Military Affairs, 20 July 2005.

អាជ្ញាធរមីនកម្ពុជាបានប៉ាន់ស្មានថាទឹកប្រាក់ប្រហែលជាង៣០លានដុល្លាអាមេរិកគឺត្រូវបានចំណាយទៅលើសកម្មភាពមីននៅកម្ពុជា បានរាយការណ៍អំពីអ្នកទទួលនូវមូលនិធិសំខាន់ៗទាំងឡាយដូចជា អង្គការបោស សំអាតមីនស៊ីម៉ាក់, អង្គការ HALO និងអង្គការ MAG ។ កងយោធពលខេមរភូមិន្ទអនុវត្តនូវសកម្មភាពដោះមីន ដោយប្រើប្រាស់មូលនិធិរបស់រដ្ឋាភិបាល ដែលត្រូវបានផ្តល់តាមរយៈការឧបត្ថម្ភថវិកាដោយធនាគារអភិវឌ្ឍន៍អន្តរជាតិ រដ្ឋាភិបាលចិន និង ប្រភពផ្សេងៗ ទៀត ប៉ុន្តែចំនួនគឺមិនត្រូវបានគេដឹងឡើយ ។[117]

ការចំណាយរបស់អង្គការស៊ីម៉ាក់ឆ្នាំ២០០៤ គឺ ៩,២៣៨,៥៧៧ ដុល្លាអាមេរិក។ គេបានអោយដឹងថាបានទទួលនូវប្រាក់បរិច្ចាគដែលសរុបទៅគឺ ៨,៧៤៣,៥០៤ ដុល្លា (៤,២៦៥,៥៧៧ ដុល្លាពី UNDP Trust Fund, ៤,៣៨០,១៨៥ ដុល្លារ ពីអ្នកបរិច្ចាគទ្វេភាគី, ១៣៨,១៤២ ដុល្លារពីរដ្ឋាភិបាល) ។ ចាប់តាំងពីឆ្នាំ ២០០១ មកការបរិច្ចាគប្រាក់របស់អង្គការ UNDP ទៅអោយអង្គការស៊ីម៉ាក់គឺធ្លាក់ចុះ(៦៤ភាគរយនៃមូលនិធិរបស់អង្គការស៊ីម៉ាក់ឆ្នាំ២០០១, ៤៨ភាគរយក្នុងឆ្នាំ២០០៤), ចំណែកការបរិច្ចាគទ្វេភាគីបានកើនឡើង (៣៥ភាគរយក្នុងឆ្នាំ២០០១ , ៤៩ភាគរយ ក្នុងឆ្នាំ ២០០៤) ។[118]

ធនធានរបស់អង្គការស៊ីម៉ាក់ ក៏ត្រូវបានធ្វើអោយកើនឡើងដោយថវិកាបដិភាគ។ ជប៉ុនបានផ្តល់នូវការបរិច្ចាគជាសំភារៈដែលមានតំលៃជាទឹកប្រាក់ប្រហែលជា១៦លានដុល្លារអាមេរិកដល់អង្គការស៊ីម៉ាក់ ដែលរួមទាំងប្រដាប់ឆ្កាព្រៃយានដឹកជញ្ជូន និងប្រដាប់ការពារ ។ ប្រដាប់ប្រដាគឺត្រូវបានប្រគល់អោយក្នុងខែ មិថុនា ឆ្នាំ ២០០៥។[119] ប្រទេសប៊ែលហ្ស៊ិក, ញូស៊ីលែនដ៏ និង ជប៉ុន បានផ្តល់នូវទីប្រឹក្សាបច្ចេកទេស។[120]

ប្រាក់ចំណូលគំរោងកម្មវិធីដោះមីនសរុបរបស់អង្គការ HALO ឆ្នាំ២០០៤គឺ ៣៨៤,៧៣៧ ដុល្លារអាមេរិក ដោយរួមបញ្ចូលទាំងតំលៃទីបញ្ជាការ និង ការទិញប្រដាប់ប្រដាថ្មីៗ, HALO គណនាឃើញថា តំលៃរបស់វាក្នុង១ម$^{២}$ សំរាប់ឆ្នាំ ២០០៤ គឺ ០,៦៨ដុល្លារអាមេរិក ដែលជាការកើនឡើង ១០% ពេញមួយឆ្នាំ ២០០៣។[121] ការ

[117] CMAA, “Mine Action Achievements 1992-2004,” 31 March 2005, p. 6. In June 2005, Cambodia also stated its future annual mine action funding requirement as being US$30 million, including $29 million for operators and $1 million for CMAA. Presentation by Cambodia, Standing Committee on Mine Clearance, Mine Risk Education and Mine Action Technologies, Geneva, 14 June 2005.

[118] CMAC, "Annual Report 2004," 28 April 2005, p. 6.

[119] “Japan Gives Cambodia Equipment for Mine Clearance,” *Vietnam News Agency*, 06/28/2005; “Remarks at the Donation Ceremony of Mine Clearing Equipments from the Government of Japan to CMAC,” *Cambodia New Vision*, available at http://www.cnv.org.kh/ (accessed 10 September 2005); Robert Griffin and Robert Keeley, “Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action,” Volume I, Phnom Penh, p. 14.

[120] Robert Griffin and Robert Keeley, “Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action,” Volume I, Phnom Penh, p. 14.

[121] HALO, "Annual Report for submission to the CMAA," 21 January 2005, p. 6.

ចំណាយរបស់អង្គការ NPA ឆ្នាំ២០០៤ គឺប្រមាណ១លានដុល្លាដោយរួមបញ្ចូលទាំងជំនួយដល់អង្គការស៊ីម៉ាក់ ។[122] អង្គការ MAG បានចំណាយប្រហែលជា ៣លានដុល្លាក្នុងឆ្នាំ ២០០៤ ។[123]

## អ្នករងគ្រោះថ្នាក់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ

ក្នុងឆ្នាំ ២០០៤, មានអ្នករងគ្រោះថ្នាក់ថ្មីដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះចំនួន ៨៩៨នាក់ត្រូវបានរាយការណ៍ថាកើតមានក្នុងប្រទេសកម្ពុជា ។ ប្រជាជន ១៧១នាក់ ត្រូវបានស្លាប់ ហើយ ៧២៧នាក់រងរបួស, ៥៤៧នាក់ជាបុរស ៧៩នាក់ជាស្ត្រី ហើយ២៧៧នាក់ជាកុមារ, ៨៨៨នាក់ជាជនស៊ីវិល ។ នេះគឺសបញ្ជាក់អោយឃើញអំពីការកើនឡើងជាសំខាន់ (១៦ភាគរយ) ទៅលើគ្រោះថ្នាក់ថ្មី ៧៧២ករណី ដែលបង្កឡើងដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះ (១១៥ នាក់បានស្លាប់, និង ៦៥៧ នាក់រងរបួស) ដែលត្រូវបានរាយការណ៍ក្នុងឆ្នាំ ២០០៣ ។[124] ក្នុងចំណោមអ្នកដែលមានជីវិតរស់នៅទាំងអស់ក្នុងឆ្នាំ ២០០៤នោះ គឺប្រជាជន ១៩៥ នាក់ (២៧%) ត្រូវការការកាត់ដៃជើង ។ គ្រោះថ្នាក់បណ្តាលមកពីគ្រាប់មីន ៣៤០នាក់ (៣៨%) រីឯគ្រោះថ្នាក់ ៥៣៨ (៦២%) បណ្តាលមកពីគ្រាប់មិនទាន់ផ្ទុះ, ជាងនេះទៀតកុមារ៨៧% បានស្លាប់ ឬធ្វើអោយរបួសដោយសារគ្រាប់មិនទាន់ផ្ទុះ ។ របាយការណ៍ពីគ្រោះថ្នាក់មីននិងគ្រាប់មិនទាន់ផ្ទុះក្នុងឆ្នាំ ២០០៥ មានគ្រោះថ្នាក់ថ្មីចំនួន ៥៩៤ បានកើតឡើងរបាយការណ៍នេះត្រូវបានគេកត់ត្រាក្នុងចុង ខែ មិថុនា ២០០៥ ដែលមានប្រជាជន ១២៤នាក់ ស្លាប់ ហើយ ៤៧០ នាក់រងរបួស ។ ក្នុងខែ មីនា ឆ្នាំ ២០០៥, ការផ្ទុះមួយនៅឃ្លាំង អាវុធរបស់កងយោធពលខេមរភូមិន្ទក្នុងខេត្តបាត់ដំបងបានសំលាប់ មនុស្សយ៉ាងតិចបំផុត ៦នាក់ ហើយមនុស្សជាង ២០នាក់ រងរបួស ។[125]

អាត្រានៃគ្រោះថ្នាក់ដោយសាមីន និងគ្រាប់មិនទាន់ផ្ទុះ គឺបានធ្លាក់ចុះពីគ្រោះថ្នាក់ថ្មី៧ចំនួន១២នាក់ ដោយសារមីននិងគ្រាប់មិនទាន់ផ្ទុះក្នុងមួយថ្ងៃនាឆ្នាំ១៩៩៦ ដល់មធ្យមនៃគ្រោះថ្នាក់២នាក់ក្នុង១ថ្ងៃនាឆ្នាំ២០០៤ ដែលជាអត្រាថេរនៅតាំងពីឆ្នាំ២០០០មក ។ ទោះជាយ៉ាងណាក៏ដោយក្នុងឆមាសទី១ នៃឆ្នាំ២០០៥ អត្រាគ្រោះថ្នាក់បានកើនឡើងម្តងទៀតដល់មធ្យមគ្រោះថ្នាក់លើសពី ៣នាក់ក្នុង ១ថ្ងៃ ។[126]

ពតិមានស្តីពីគ្រោះថ្នាក់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ គឺត្រូវបានប្រមូលពីខេត្តទាំងអស់ដោយបណ្តាញរបស់បុគ្គលិកចុះទៅផ្ទាល់របស់អង្គការកាកបាទក្រហមកម្ពុជា (CRC) បន្ទាប់មកទិន្នន័យក៏ចូលទៅក្នុងប្រព័ន្ធទិន្ន័យស្តីពីជនរងគ្រោះដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា (CMVIS) ដោយបានអនុវត្តកម្មវិធីដោយអង្គការ

[122] Email to Landmine Monitor from Krishna Uk, Program Officer, NPA Cambodia, 7 June 2005.
[123] Information provided by Rupert Leighton, Country Manager, MAG Cambodia, 25 August 2005.
[124] Unless otherwise stated, information in this section was provided in email to Landmine Monitor (HI) from Chiv Lim, Project Manager, CMVIS, 1 August 2005.
[125] "RCAF Explosion May Be Sabotage," *Cambodia Daily*, 28 April 2005, p. 12; "Cambodia's RCAF identifies causes of ammunition explosion," *People's Daily Online*, 4 April 2005.
[126] For more details see *Landmine Monitor Report 2004*, p. 262.

កាកបាទក្រហមកម្ពុជា និង អង្គការជនពិការអន្តរជាតិ (Handicap International) ។ គ្រោះថ្នាក់ដោយសារមីនភាគច្រើនបំផុតក្នុងឆ្នាំ ២០០៤ គឺចេញពីសកម្មភាពប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃដូចជា ការធ្វើកសិកម្ម ការឃ្វាលសត្វ, ការសំអាតដីធ្លី, ការនេសាទ និង ការស្វែងរកអាហារ និងឈើ (៥៤%) ឬ ការធ្វើដំណើរ (២៦%) នៅពេលដែលគ្រោះថ្នាក់កើតឡើង ចំណែកឯគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះ ៥៨% គឺកើតឡើងដោយសារការរកេះកកាយគ្រាប់លេង។

គ្រោះថ្នាក់ដោយសារមីនគឺកើតឡើងយ៉ាងច្រើនក្នុងតំបន់ព្រំដែន ថៃ-កម្ពុជា ជិតខ្សែក្រវ៉ាត់ ក-៥ ក្នុងខេត្តបាត់ដំបង, បន្ទាយមានជ័យ, ឧត្តរមានជ័យ, ប៉ៃលិន , ព្រះវិហារ និងពោធិសាត់គ្រោះថ្នាក់ដែលកើតឡើងពីគ្រាប់មិនទាន់ផ្ទុះគឺមានរាយប៉ាយពាសពេញប្រទេស ដោយមានខេត្តបាត់ដំបង, កំពង់ចាម (តាមព្រំប្រទល់វៀតណាម) ឧត្តរមានជ័យ, ព្រះវិហារ និងប៉ៃលិន ដែលប្រាប់អោយដឹងថាមានគ្រោះថ្នាក់ខ្លាំងបំផុត។ [127] គ្រោះថ្នាក់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះគឺត្រូវបានគេរាយការណ៍អោយដឹងនៅក្នុងខេត្ត ២២ ក្នុងចំណោមខេត្ត ២៤ឆ្នាំ២០០៤, គ្រោះ ថ្នាក់ ៧៩% ក្នុងចំណោមគ្រោះថ្នាក់ទាំងអស់ត្រូវបានគេរាយការណ៍អោយដឹងក្នុងខេត្ត៧ ដែលភាគច្រើននៅខេត្ត បាត់ដំបង ដោយមានគ្រោះថ្នាក់ ២៥៣ (២៨%) បន្ទាប់ពីហ្នឹងមកគឺមានខេត្តបន្ទាយមានជ័យដោយមានគ្រោះថ្នាក់ ១៣៤ (១៥%) ក្រុងប៉ៃលិន ,៩៨ (១១%), កំពង់ចាម ៧៦ (៨%) ឧត្តរមានជ័យ ៧៥ (៨%) ពោធិសាត់ ៣៩ (៤%) និងព្រះវិហារ ៣៤ (៤%)។[128]

ឆ្នាំ ២០០៤, ប្រព័ន្ធទិន្នន័យស្តីពីគ្រោះថ្នាក់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ បានកត់ត្រានូវចំនួនមនុស្ស ១៨នាក់ បានស្លាប់ ឬរងរបួសក្នុងសកម្មភាពបោសសំអាតមីន។អង្គការស៊ីម៉ាក់ បានរាយការណ៍អោយដឹងថាអ្នកដោះមីន១២នាក់ គឺរងរបួស ហើយអង្គការ HALO Trust បានរាយការណ៍ថា មានម្នាក់រងរបួសក្នុងពេលប្រតិបត្តិការណ៍បោសសំអាត។ អ្នកត្រួតត្រាសកម្មភាពដោះមីនរបស់ HALO ម្នាក់ ត្រូវស្លាប់ក្នុងខណៈដែលសាកល្បងបើកយកមីនប្រឆាំងនឹងយានយន្តធុន TM-៤៦ ចេញពីកន្លែងមីន វាមិនត្រូវបានគេដឹងថា ហេតុអ្វីបានគាត់ធ្វើដូច្នេះ។[129]

នៅខែ មិថុនា ឆ្នាំ ២០០៥ ប្រភពផ្ទុកទិន្នន័យរបស់ CMVIS មានឯកសារស្តីអំពីគ្រោះថ្នាក់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ ៦៦,៦១១ ចាប់តាំងពីឆ្នាំ ១៩៧៩ មក គឺប្រជាជន ២០,២៥៤ នាក់ត្រូវស្លាប់ ហើយ៩៦,៣៥៧ រងរបួស (ដោយរួមបញ្ចូលទាំងការកាត់អវៈយវៈ៩៨៥០) ៥២,០២៧ គឺជាជនស៊ីវិល ។

[127] CMAA, "Mine Action Achievements 1992-2004," 31 March 2005, p. 13.
[128] CMVIS, "Monthly Mine/UXO Victim Information Report: June 2005," p. 6.
[129] CMAC, "Annual Report 2004," 28 April 2005; HALO Trust, "Annual Report 2004 for submission to the CMAA," 21 January 2005.

## ការឧបត្ថម្ភអ្នកនៅរស់រានជីវិតពីគ្រោះថ្នាក់មីន

នៅសន្និសីទបូកសរុបការងារមីនលើកទី១ (The First Conference) ប្រទេសកម្ពុជាគឺត្រូវបានគេបញ្ជាក់ថាជាភាគីរដ្ឋសមាជិកមួយក្នុងចំណោមភាគីរដ្ឋសមាជិកចំនួន ២៤ ដែលមានចំនួនអ្នកនៅរស់ជីវិតពីមីនយ៉ាងច្រើន និងមាន "តួនាទីធំបំផុតដើម្បីធ្វើ ប៉ុន្តែមានតំរូវការនិងក្តីសង្ឃឹមទៅលើជំនួយខ្លាំងបំផុតដែរ" ក្នុងការផ្តល់នូវសេវាគ្រប់គ្រាន់សំរាប់ការថែរក្សា, ការធ្វើអោយប្រសើរឡើង និង សមាហរណកម្មនូវជនរួចជីវិតពីគ្រាប់មីន ។ [130]

ប្រទេសកម្ពុជាបានផ្តល់នូវឯកសារស្ម័គ្រចិត្តទំរង់ J (Voluntary Form J) ជាមួយរបាយការណ៏តាមមាត្រា៧ (Article 7 report) ប្រចាំឆ្នាំរបស់ខ្លួន ដោយផ្តល់នូវពត៌មានស្តីពីគ្រោះថ្នាក់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ ហើយនិងសេវាធ្វើអោយប្រសើរឡើង ។[131]

ក្នុងខែ មិថុនា ឆ្នាំ ២០០៥ ឋានៈជាផ្នែកមួយនៃកិច្ចប្រេជ្ញាដែលត្រូវធ្វើចំពោះគំរោងផែនការសកម្មភាព ក្រុងណៃរ៉ូប៊ី (Nairobi Action Plan) ប្រទេសកម្ពុជាបានផ្តល់នូវទិសដៅមួយចំនួនក្នុងចំណោមទិសដៅទាំងឡាយរបស់ខ្លួនសំរាប់កំឡុងពេល ២០០៥-២០០៩ ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់អ្នកដែលសល់ជីវិតពីមីន។ គំរោងផែនការសកម្មភាពនឹងត្រូវបានបង្កើតនិងវិវត្តឡើងអោយសមស្របទៅនឹងតួអង្គសំខាន់ទាំងឡាយដូចជា ក្រុមប្រឹក្សាសកម្មភាពជនពិការ (Disability Action Council) ដែលមាននៅក្នុងគំរោងស្តីពីទិសដៅយុទ្ធសាស្រ្តសំរាប់ជនពិការ និងស្តារ (Strategic Direction On Disability and Rehabilitation:SDDR)។ [132] ទិសដៅសំរាប់ជំនួយជនរងគ្រោះដោយសារមីនរួមមាន : ការថែទាំ និងធ្វើសហប្រតិបត្តិការទៅលើការប្រមូលពត៌មានដែលមាននិរន្តភាព និងបណ្តាញការងារស្តីពីគ្រោះថ្នាក់ដោយសារមីននិងគ្រាប់មិនទាន់ផ្ទុះ ។ ការប៉ាន់ស្មាន និងការវិភាគនូវស្ថានការណ៏ជាផ្នែកខាងការធ្វើអោយប្រសើរឡើងវិញនូវវេជ្ជសាស្រ្ត ដើម្បីអភិវឌ្ឍន៏នូវគោលការណ៏ណែនាំ និងយុទ្ធសាស្រ្តសំរាប់ការអភិវឌ្ឍន៏នូវផែនការជាតិ ការធ្វើអោយប្រជាជនពិការមួយចំនួនទៀតអោយបានចូលទៅដល់មជ្ឈមណ្ឌលស្តារយុវនីតិសម្បទារផ្នែករាងកាយ ការបង្កើននូវស្តង់ដារ និង គុណភាពរបស់មជ្ឈមណ្ឌលស្តារយុវនីតិសម្បទារ ការចាប់ផ្តើមពិភាក្សាអំពីទិសដៅអភិឌ្ឍន៏និងផែនការ ឆ្លើយតបទៅនឹងតំរូវការជំនួយផ្នែកផ្លូវចិត្ត និង សមាហរណកម្មជនពិការទៅក្នុងសង្គមឡើងវិញ បង្កើននូវលទ្ធភាព និងការបន្តបណ្តុះបណ្តាលវិជ្ជាជីវៈ គំរោងការសំខាន់ និងឱកាសរកការងារ បង្កើតអោយមានការចូលរួមពីសំណាក់ប្រជាជនពិការនៅក្នុងកម្មវិធីអភិវឌ្ឍន៏តាមរបៀបសំខាន់

130 United Nations, Final Report, First Review Conference of the States Parties to the Convention on the Prohibition of the Use, Stockpiling, Production and Transfer of Anti-Personnel Mines and on Their Destruction, Nairobi, 29 November–3 December 2004, APLC/CONF/2004/5, 9 February 2005, p. 33.

131 Article 7 Report, Form J, 22 April 2005.

132 For more information on SDDR see www.dac.org.kh/strategic-dir/index.htm

និងបង្កើនការធ្វើច្បាប់អោយមានប្រសិទ្ធិភាព ដើម្បីការពារសិទ្ធិរបស់អ្នកដែលរស់រានមានជីវិតពីមីន និងជនពិការដទៃទៀត ។[133]

អាជ្ញាធរមីន ទទួលខុសត្រូវខាងការសំរបសំរួល និង ការត្រួតពិនិត្យលើជំនួយជនរងគ្រោះដោយសារមីន, ទោះដូចនេះក្តី គេបានផ្ទេរនូវការទទួលខុសត្រូវដល់ក្រសួងសង្គមកិច្ចការងារអតីតយុទ្ធជន និងយុវជន (MOSVY)[134] និងក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ។[135] អគ្គលេខាធិការដ្ឋានរបស់នាយកដ្ឋានផ្តល់ជំនួយដល់ជនរងគ្រោះរបស់អាជ្ញាធរមីន បានបង្កើតគំរោងជាយុទ្ធសាស្ត្រមួយសំរាប់ឆ្នាំ ២០០៤-២០០៩ ដើម្បីធ្វើការសំរបសំរួលលើជំនួយដល់ជនរងគ្រោះដោយសារមីន ដែលផ្តល់ដោយស្ថាប័នជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និង អន្តរជាតិ តែទោះជាយ៉ាងនេះក្តី គេគ្មានថវិកាដើម្បីអនុវត្តន៍យុទ្ធសាស្ត្រនេះទេ ។[136]

យោងតាមអាជ្ញាធរមីន បានអោយដឹងថាមានអង្គការជាង ៣០ (អង្គការជាតិ និង អន្តរជាតិ) ដែលមានសកម្មភាពនៅក្នុងប្រទេសកម្ពុជា ដោយធ្វើការជាអ្នកស្តារយុវនីតិសម្បទារអ្នករស់រានមានជីវិតពីមីន និងជនពិការដទៃជាច្រើនទៀត ។ គេបានប៉ាន់ស្មានថា មានជនពិការចំនួន ១១% ជាអ្នករស់រានមានជីវិតពីគ្រាប់មីន ។ អង្គការក្រៅរដ្ឋាភិបាល (NGOs) ជាអ្នកអនុវត្តន៍ដ៏សំខាន់ ដោយផ្តល់ការស្តារយុវនីតិសម្បទារផ្នែករាងកាយ និង ការគាំទ្រដទៃទៀតដូចជា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការយកបំរើការងារ និង ការអភិវឌ្ឍន៍សហគ្រាសធន់តូច ។[137]

អ្នករស់រានមានជីវិតជាច្រើននាក់ក្នុងប្រទេសកម្ពុជាជាប្រជាជនស្ថិតក្នុងចំណោមអ្នកក្រីក្របំផុតក្នុងប្រទេសដ៏ក្រីក្រនេះ ។ អ្នកខ្លះពុំមានលទ្ធភាពទទួលនូវសេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្សទូទៅ ដូចជា ជំរក អាហារបរិភោគ សុខភាព និងការអប់រំ ។[138] ទីប្រឹក្សាមួយដែលផ្តល់មូលនិធិដោយអង្គការ Christian Blind Mission (CBM) បានចងសម្ព័ន្ធជាមួយក្រសួងសុខាភិបាល (MOH) និង ក្រសួងសង្គមកិច្ចការងារ (MoSVY) ស្តីពីបញ្ហាពិការភាព ។ ទិសដៅទាំងឡាយរបស់ផែនការជាយុទ្ធសាស្ត្រ ផ្នែកសុខាភិបាលរបស់ក្រសួងសុខាភិបាល ឆ្នាំ ២០០៣-២០០៧ រួមមានការធ្វើអោយប្រសើរឡើងនូវការផ្សព្វផ្សាយពតិមាន និង លទ្ធភាពទទួលបានសេវាកម្មសុខាភិបាល ជា

133 Presentation by Cambodia, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 16 June 2005; Response by Cambodia to the Co-Chairs of the Standing Committee on Victim Assistance and Socio-Economic Reintegration Questionnaire, June 2005.
134 Formerly the Ministry of Social Affairs, Labor, Vocational Training and Youth Rehabilitation.
135 CMAA, "Mine Action Achievements 1992-2004," 31 March 2005, p. 50.
136 Interview with Kuon Pheng, Director, Victim Assistance Department, Victim Assistance Department, CMAA, Phnom Penh, 22 March 2005; see *Landmine Monitor Report 2004*, p. 271.
137 The estimate is based on a 1999 survey reported in CMAA, "Mine Action Achievement 1992-2004," 31 March 2005, p. 49; see also statement by Sam Sotha, Secretary-General, CMAA, to meeting on victim assistance, Phnom Penh, 10 March 2004.
138 Presentation by Cambodia, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 16 June 2005.

ពិសេសដល់ប្រជាជនក្រីក្រនិងក្រុមដែលងាយទទួលរងគ្រោះជាងគេ ការពង្រឹងនូវការផ្តល់នូវសេវាកម្មសុខាភិបាលជាមូលដ្ឋាន ដែលមានគុណភាពខ្ពស់ការណែនាំពីគុណសម្បត្តិវប្បធម៌ក្នុងសេវាកម្មសុខាភិបាលសាធារណៈ និង ការធានាអោយបាននូវលំហូរមូលនិធិអោយបានគ្រប់គ្រាន់ និងទៀងទាត់ ដល់វិស័យសុខាភិបាលជាពិសេសសំរាប់ការចែកចាយសេវាកម្ម ។[139]

ជំនួយបឋម អាចមាននៅតាមមជ្ឈមណ្ឌលសុខភាពរដ្ឋក៏រិតឃុំ ស្រុក និង ពេលខ្លះនៅក៏រិតភូមិ ប៉ុន្តែអ្នកជំងឺ ភាគច្រើនត្រូវការការព្យាបាលតាមជំនាញឯកទេសពិសេសដូចជាការវះកាត់ ។ ឧប្បត្តិហេតុគ្រោះថ្នាក់ជារឿយៗកើតឡើងនៅតាមភូមិ រឺ ក្នុងព្រៃដែលនៅឆ្ងាយពីមជ្ឈមណ្ឌលសុខភាព ហើយជំនួយសង្គ្រោះជាបន្ទាន់ដំបូងបំផុតត្រូវផ្តល់ដោយអ្នកភូមិតាមលទ្ធភាព ។ ជាឧទាហរណ៏នៅខែធ្នូឆ្នាំ២០០៤មជ្ឈមណ្ឌលសុខភាពទី១ ដែលបានជួយព្យាបាល ដល់អ្នករងគ្រោះដោយគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះថ្មីៗចំនួន៧៩នាក់នោះ គឺមាន៣១%នៅតាមមជ្ឈមណ្ឌលសុខភាពតាមឃុំ១១% ព្យាបាលដោយ ខ្លួនឯង ៩%នៅតាមគ្លីនិកឯកជន ៧% នៅមន្ទីរពេទ្យខេត្ត ៦% នៅមន្ទីរពេទ្យ ស្រុក រឺ "មន្ទីរពេទ្យដទៃៗទៀត" និង ៦% ត្រូវបានគេចុះបញ្ជីពេលដែល ១៩% ទៀតត្រូវគេរាយការណ៏ថា មិនបានផ្តល់ជំនួយអោយ ។[140]

អង្គការជាច្រើនបានកំនត់ទិសដៅផ្តល់ការបណ្តុះបណ្តាលខាងជំនួយសង្គ្រោះបន្ទាន់បឋម និង បច្ចេកទេសទ្រទ្រង់ជីវិតដែលរួមមានមជ្ឈមណ្ឌល Trauma Care Toundation (TCF) នៃអង្គការក្រៅរដ្ឋាភិបាលន័រវេស អង្គការ Catholie Relief Service និងអង្គការ CARE ។[141]

អង្គការមួយចំនួនទៀតដូចជា ភ្នាក់ងារសង្គ្រោះបន្ទាន់នៅខេត្តបាត់ដំបង អង្គការ CMAC, អង្គការ HALO Trust, អង្គការ MAG, អង្គការ Jesuit Service Cambodia (JS) និងអង្គការ Cambodia Family Development Service បានផ្តល់ជាឡានពេទ្យ រឺ មធ្យោបាយដើម្បីដឹកជញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យ ។ កាកបាទក្រហមកម្ពុជា បានជូនដំណឹងដល់ទីភ្នាក់ងារអង្គការផ្សេងៗ អំពីសេចក្តីត្រូវការជាពិសេសរបស់អ្នករងគ្រោះថ្នាក់ដោយសារគ្រាប់មីនដែលស្ថិតក្នុងមន្ទីរពេទ្យ ។ នៅក្នុងខេត្តបន្ទាយមានជ័យ កាកបាទក្រហមកម្ពុជាបានបញ្ជូនអ្នករស់រានមានជីវិតពីមីនដែលត្រូវការជំនួយ ផ្នែកស្បៀងអាហារក្នុងមន្ទីរពេទ្យទៅកាន់អង្គការ JS ហើយសមាគមន៏ផ្តល់ជំនួយដល់កុមារ និង ស្ត្រីមេម៉ាយបានផ្តល់ជាថវិកាសំរាប់ដំណើរការវះកាត់ ។ នៅឆ្នាំ ២០០៤ អង្គការ JS បានផ្តល់ជំនួយដល់អ្នករងគ្រោះដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះចំនួន ៦១នាក់ ដែលស្ថិតនៅក្នុងមន្ទីរពេទ្យ ។

ការវះកាត់សំរាប់គ្រោះថ្នាក់ថ្មីៗដោយសារគ្រាប់មីន និងដល់អ្នករស់រានមានជីវិតពីមីនដែលត្រូវការវះកាត់បន្ថែម គឺត្រូវបានផ្តល់អោយដោយឥតគិតថ្លៃនៅមជ្ឈមណ្ឌលសង្គ្រោះបន្ទាន់ក្នុងខេត្តបាត់ដំបូង និង ដោយ

---

[139] Ministry of Health, "Health Sector Strategic Plan: 2003-2007," August 2002, p. 9.
[140] CMVIS, "Monthly Mine/UXO Victim Information Report: December 2004."
[141] For more information see *Landmine Monitor Report 2004*, p. 265.

មន្ទីរពេទ្យ Sihanouk Hospital Center of Hope ក្នុងទីក្រុងភ្នំពេញ ។ មន្ទីរពេទ្យ Angkor Hospital for children នៅខេត្តសៀមរាបបណ្តាមន្ទីរពេទ្យរដ្ឋនៅទីក្រុង និងតាមខេត្តនិងមន្ទីរពេទ្យ Preah Ket Malea ក៏ផ្តល់ការវះកាត់ផងដែរ ។[142]

មន្ទីរពេទ្យខេត្តបន្ទាយមានជ័យឈ្មោះ មង្គលបូរី នៅក្នុងស្រុកមង្គលបូរីជាមន្ទីរពេទ្យដែលគ្រប់គ្រងដោយរដ្ឋមានបំពាក់បរិក្ខាល្អបំផុតនិងធំបំផុតនៅក្នុងតំបន់។ ហើយបានបំរើជូនប្រជាពលរដ្ឋដែលមកពីបណ្តាខេត្តជាច្រើនដូចជា ខេត្តបាត់ដំបង, ឧត្តរមានជ័យ និង ខេត្តសៀមរាបផងដែរ។ មន្ទីរពេទ្យនេះ បានអោយដឹងថាបានទទួលព្យាបាលអ្នករងគ្រោះថ្នាក់ដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះប្រហែល ៨នាក់ជារៀងរាល់ខែ។ គេមានកន្លែងសំរាប់សង្គ្រោះបន្ទាន់និងការព្យាបាលដោយចលនាផ្តាច់មុខ។ តែទោះជាយ៉ាងនេះក្តីតាមការរាយ-ការណ៍ មន្ទីរពេទ្យនេះមានអ្នកជំងឺច្រើនលើសលប់ និងត្រូវការអោយមានការជួសជុលហេដ្ឋារចនាសម្ព័ន្ធឡើងវិញ។ អ្នកជំងឺត្រូវតែបង់ថ្លៃឈ្នួល ២,៦០០បាត ( ប្រហែល ៦៦ ដុល្លាអាមេរិក) មុនពេលបញ្ចូនចូលទៅក្នុងមន្ទីរពេទ្យ។ បើគ្រួសារណាអាចបង្ហាញភស្តុតាងជាក់ច្បាស់ពីផលវិបាករបស់ខ្លួននោះមូលនិធិសមធមិជូនកាលអាចយកមកផ្តល់អោយចំពោះថ្លៃមន្ទីរពេទ្យ ។[143]

មជ្ឈមណ្ឌលវះកាត់របស់ទីភ្នាក់ងារសង្គ្រោះអង្គការក្រៅរដ្ឋាភិបាលអ៊ីតាលី (Ilaria Alpi Surgical Center) នៅក្នុងខេត្តបាត់ដំបងផ្តល់ជំនួយសង្គ្រោះដល់ការវះកាត់ដោយឥតគិតថ្លៃដល់ជនរងគ្រោះដោយសារសង្គ្រាមរួមមានគ្រោះថ្នាក់ដោយសារមីននិងការវះកាត់ជាលក្ខណៈទូទៅឡើងវិញ ។ទីភ្នាក់ងារសង្គ្រោះបន្ទាន់នេះក៏បានគាំទ្រដល់ប៉ុស្តិ៍ផ្តល់ជំនួយបឋមចំនួន៥កន្លែង ក្នុងតំបន់សំឡូតនិង បានបើកសេវាឡានពេទ្យមួយពីសំឡូត។ ជាមធ្យមវាប្រើពេលប្រហែល១ម៉ោងកន្លះ ដើម្បីដឹកអ្នករបួសដោយគ្រាប់មីនពីស្រុកសំឡូតតាមឡានពេទ្យទៅកាន់ខេត្តបាត់ដំបង។ នៅឆ្នាំ ២០០៤ ទីភ្នាក់ងារសង្គ្រោះបន្ទាន់នេះ បានព្យាបាលអ្នករបួសដោយមីនថ្មីៗចំនួន១០៥នាក់ ដោយសារគ្រាប់មិនទាន់ផ្ទុះចំនួន ៦០នាក់ ទីភ្នាក់ងារសង្គ្រោះបន្ទាន់ ក៏បានផ្តល់ការវះកាត់ដ៏ត្រឹមត្រូវដល់អ្នករស់រានមានជីវិតពីមីនចំនួន៨៥នាក់ និងពីគ្រាប់មិនទាន់ផ្ទុះចំនួន១៥នាក់។ គ្រោះថ្នាក់ធ្ងន់ធ្ងរត្រូវបានបញ្ជូនទៅមន្ទីរពេទ្យពីខេត្តជាច្រើនដូចជា ខេត្តបាត់ដំបង ក្រុងប៉ៃលិន ខេត្តពោធិសាត់ ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ ខេត្តសៀមរាប តំបន់ប៉ោយប៉ែត ខេត្តឧត្តរមានជ័យ, ខេត្តកំពង់ធំ និង ទីក្រុងភ្នំពេញ ។[144]

សេវាស្តារយុវនីតិសម្បទាវផ្នែករាងកាយសំរាប់អ្នករស់រានមានជីវិតពីមីន ជាទូទៅបានគេរៀបចំបានយ៉ាងល្អប្រសើរ និងប្រកបដោយគុណភាពនៅក្នុងប្រទេសកម្ពុជា ជាពិសេសចំពោះអ្នកត្រូវកាត់ដៃជើង ទោះជា

[142] See *Landmine Monitor Report 2004*, p. 265.
[143] Interview with Or Kanal, Chief Administrator, provincial hospital, Mongkol Borei, 17 March 2005.
[144] Interview with Ognjen Predja, Program Coordinator, Emergency, Battambang, 30 March 2005; see also *Landmine Monitor Report 2004*, p. 266.

ត្រូវការនៅតែមានទំហំធំក៏ដោយ។ នៅឆ្នាំ២០០៤ មានមជ្ឈមណ្ឌលស្តារយុវនីតិសម្បទារ ផ្នែករាងកាយចំនួន ១១កន្លែង និងរោងជាងកែច្នៃរូបកាយជាច្រើនដែលគ្របដណ្តប់លើ២៤ខេត្តក្រុង ក្នុងប្រទេសកម្ពុជាបានថយចុះពីចំនួន១៤កន្លែងនាដើមឆ្នាំ២០០៣។ ដោយយោងតាមការផ្តល់សេវាកម្ម ហេតុផលចំបងចំពោះការថយចុះនេះ គឺមកពីការកាត់បន្ថយមូលនិធិតែរាល់ការបិទទាំងអស់មិនមានប៉ះពាល់អ្វីធ្ងន់ធ្ងរទេដល់អ្នកនៅរស់ដែលត្រូវការជំនួយពីក្រុមនេះ។[145] តាមការស្រាវជ្រាវរបស់អ្នកត្រួតពិនិត្យមីន ដែលចុះទៅពិនិត្យគ្រប់ខេត្តក្រុងដើម្បី ធ្វើការវាយតំលៃពីរបៀបណាទៅដែលអ្នករស់រានមានជីវិតពីមីនអាចទទួលបានសេវាកម្មស្តារយុវនីតិសម្បទា។

អ្នករស់រានជីវិតពីគ្រោះថ្នាក់មីន មានការត្អូញត្អែរពីការលំបាកក្នុងការទទួលសេវាស្តារនៅក្នុងខេត្ត ស្ទឹងត្រែង, ខេត្តព្រះវិហារ, ខេត្តកោះកុង និង ខេត្តកំពង់ធំ ។ មន្ត្រីសង្គមកិច្ចតាមខេត្តក៏បានត្អូញត្អែរពីការបិទទ្វារសេវាមួយចំនួនក្នុងខេត្តព្រះវិហារ, ខេត្តកំពង់ធំនិងខេត្តបន្ទាយមានជ័យដែរ។ នៅកិច្ចប្រជុំមួយនាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០០៥ ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បានត្អូញត្អែរមិនត្រឹមតែ ចំពោះការបិទសេវាស្តារកាយសម្បទាប៉ុណ្ណោះទេ ថែមទាំងលើកអំពីការកាត់បន្ថយថវិកាសំរាប់អង្គការក្រៅរដ្ឋាភិបាលចំនួន៤ ដែលពួកគេផលិតអវៈយវៈសិប្បនិមិត្តទៀតផង និងជំរុញអោយម្ចាស់ជំនួយពិចារណាពីការផ្តល់មូលនិធិរដ្ឋាភិបាលដើម្បីបន្តកម្មវិធីនានាបន្ទាប់ពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិចាកចេញទៅ។[146] ការវាយតំលៃមួយចំពោះសេវាកម្មអវៈយវៈសិប្បនិមិត្ត និងសេវារណបក្នុងប្រទេសកម្ពុជាត្រូវបានគេគ្រោងធ្វើសំរាប់ឆ្នាំ ២០០៥ ។[147]

អង្គការអន្តរជាតិចំនួន៥ រួមមាន គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) កាកបាទក្រហមអាមេរិក (ARC), Cambodia Trust (CT), Handicap International (HI) និង Veterans International (VI) បានជួយទ្រទ្រង់វិស័យស្តារជាច្រើនក្នុងឆ្នាំ២០០៤ ក្នុងកិច្ចសហការជាមួយក្រសួងសង្គមកិច្ចការងារ។ ក្រសួងសង្គមកិច្ចការងារ មានថវិកាប្រតិបត្តិការនៅមានកំនត់ក្នុងវិស័យស្តារយុវនីតិសម្បទារ, ដូច្នេះយើងពឹងផ្អែកលើទីភ្នាក់ងារអន្តរជាតិទាំងឡាយ។ ចំណែកនៅខែ មិថុនា ឆ្នាំ ២០០៥ មជ្ឈមណ្ឌលស្តារយុវនីតិ សម្បទារ និងកែប្រែរូបរាងកាយបានផ្តល់ជំនួយដល់អ្នករស់រានមានជីវិតពីមីន និង ជនពិការជាច្រើន គឺមានទីតាំងនៅក្នុងបណ្តាខេត្តជាច្រើនដូចជាៈ ខេត្តបាត់ដំបង (ICRC), កំពង់ស្ពឺ (ICRC), សៀមរាប (HI), កំពង់ចាម (HI), ក្រចេះ (VI), ក្រុងព្រះសីហនុ (CT), ព្រៃវែង (VI), តាកែវ (HI), កំពង់ឆ្នាំង (CT), មានមជ្ឈមណ្ឌលពីរក្នុង

145 For more information see *Landmine Monitor Report 2004*, p. 266.
146 Ith Sam Heng, Minister of Social Affairs, speech at National Mine Action Achievements Conference, Phnom Penh , 28 April 2005.
147 Interview with Edith van Wijngaarden, Coordinator, Rehabilitation Department, HI Cambodia, Phnom Penh, 21 March 2005.

ទីក្រុងភ្នំពេញ(CTនិងVI)។ នៅឆ្នាំ២០០៤ មជ្ឈមណ្ឌលស្តារ យុវនីតិសម្បទាខ្លះបានបិទទ្វារ (ខែ មិថុនា ឆ្នាំ ២០០៤) នៅខេត្តកំពង់ធំ និង ក្នុងខេត្តព្រះវិហារ (VI បិទទ្វារនៅខែតុលា ឆ្នាំ ២០០៤)។[148]

អង្គការកាកបាទក្រហមអន្តរជាតិ (ICRC) បានណែនាំអោយប្រើប្រាស់នូវមូលដ្ឋានទិន្នន័យថ្មីមួយដែលបច្ចុប្បន្ននេះ បានប្រើប្រាស់ដោយមជ្ឈមណ្ឌលស្តារយុវនីតិសម្បទារផ្នែករាងកាយចំនួន ១១ កន្លែង ដើម្បីប្រមូលស្ថិតិដែលទាក់ទិនទៅនឹងសេវាកម្មជាច្រើន។ ស្ថិតិទាំងនេះបានលាតត្រដាងអោយដឹងថាកំឡុងឆ្នាំ ២០០៤ មានប្រជាពលរដ្ឋចំនួន ២៦,៥១៣នាក់ ទទួលបានសេវាកម្ម ១៧% ជាអ្នកជំងឺថ្មី ២៨% ជាស្ត្រី ៣៩% មានអាយុក្រោម ១៨ឆ្នាំ ការវាយតំលៃពីការព្យាបាលដោយគក់ច្របាច់ចំនួន ៩,៦៥៤ ត្រូវបានគេធ្វើឡើង និង ការព្យាបាលជិត ៩៨,០០០ត្រូវបានផ្តល់អោយ។[149] ដោយយោងទៅតាមស្ថាប័នអាជ្ញាធរមីន មានប្រជាពលរដ្ឋចំនួន ៦២% ដែលបានទទួលសេវាកម្មស្តារយុវនីតិសម្បទាផ្នែករាងកាយជាអ្នករស់រានមានជីវិតពីគ្រោះថ្នាក់មីន។[150]

កម្មវិធីស្តារយុវនីតិសម្បទាផ្នែករាងកាយរបស់អង្គការកាកបាទក្រហមអន្តរជាតិ ដែលបានរៀបចំស្របទៅតាមក្រសួងសង្គមកិច្ចការងារនោះមាន២សមាសភាគ គឺមជ្ឈមណ្ឌលស្តារយុវនីតិសម្បទា ផ្នែករាងកាយក៏រិតតំបន់ (Regional Physical Rehabilitation Center) ក្នុងខេត្តបាត់ដំបង និង រោងចក្រផលិត អវៈយវៈ រណប (Orthopedic Component Factory) នៅក្នុងទីក្រុងភ្នំពេញ។ នៅឆ្នាំ ២០០៤ ក្រសួងសង្គមកិច្ចការងារបានយល់ព្រមចេញចំនាយ២០% លើផ្នែកសាធារណៈនិងចំនាយលើសំភារៈនានានៅកន្លែងទាំង២នេះ។ មជ្ឈមណ្ឌលស្តារយុវនីតិសម្បទានេះ បានបំរើការនៅខេត្តជាច្រើន ដូចជា ខេត្តបាត់ដំបង, ក្រុងប៉ៃលិន, ខេត្តបន្ទាយមានជ័យ, ខេត្តឧត្តរមានជ័យ និង ខេត្តពោធិសាត់ (នៅទិសឧត្តរ និងប៉ែកពាយ័ព្យ នៃប្រទេសកម្ពុជា)។ អង្គការកាកបាទក្រហមអន្តរជាតិ បានផ្តល់របៀបព្យាបាលដោយចលនា ឧបករណ៍អវៈយវៈសិប្បនិមិត្ត និង រណប(អ័រតូ) ជំនួយអវៈយវៈសិប្បនិមិត្ត រទេះជនពិការ ការស្នាក់នៅ និង អាហារ ដោយឥតគិតថ្លៃ និង ផ្តល់ប្រាក់ថ្លៃធ្វើដំណើរជូនវិញពី ៨០% ទៅ១០០% ។ ការបណ្តុះបណ្តាលការងារត្រូវ បានផ្តល់ទៅក្រុមបច្ចេកទេសខាងកែប្រែរូបកាយ និងអ្នកផ្តល់ការព្យាបាលដោយចលនា។ មជ្ឈមណ្ឌលនេះក៏បានបើកគ្លីនិកចល័តមួយដែលធ្វើដំណើរពីខេត្តបាត់ដំបងទៅបណ្តាខេត្តប៉ែកពាយ័ព្យ ដើម្បីធ្វើការព្យាបាល ពេលជួបប្រទះនិងព្យាបាលបន្តទៅលើអ្នកត្រូវកាត់ជើង ។ នៅឆ្នាំ ២០០៤ ការចុះធ្វើការតាមភូមិធ្វើបាន ចំនួន ២៥ដង ជួយដល់មនុស្សចំនួន ២,៧៥០ នាក់ ត្រូវបានគេផ្តល់ភ្លាមៗ, អវៈយវៈសិប្បនិមិត្តចំនួន១,៦១៩ ត្រូវបានជួសជុលឡើងវិញនិងអ្នកត្រូវកាត់ដៃជើងចំនួន ១,០៤៧នាក់បានបញ្ជូនទៅមជ្ឈមណ្ឌលដើម្បីផ្លាស់ប្តូរនូវអវៈយវៈសិប្បនិមិត្តរបស់ពួកគេ។ នៅឆ្នាំ ២០០៤ មជ្ឈមណ្ឌល

---

[148] Email from Larrie Warren, VVAF, 16 September 2004; email from Edith van Wijngaarden, Coordinator, Rehabilitation Department, HI Cambodia, 17 September 2004.

[149] "Physical Rehabilitation Center Statistics Report 2004," May 2005, compiled by Edith van Wijngaarden, Coordinator, Rehabilitation Department, HI Cambodia.

[150] CMAA, "Annual Report on Victim Assistance 2004," prepared by Kuon Pheng, Director of Victim Assistance Department, 15 March 2005.

ស្តារថ្នាក់តំបន់(Regional Rehabitition Center)បានផលិតអវៈយវៈសិប្បនិមិត្តចំនួន១,៤៩៤(១,៣៦៣សំរាប់អ្នករស់រានមានជីវិតពីមីន) រណប(អ័រតូ)ចំនួន៧៣២ (១៤សំរាប់អ្នករស់រានមានជីវិតពីមីន) និងបានចែកជូននូវឈើច្រត់ ចំនួន ២,៧៩៧ និង រទេះជនពិការចំនួន ២៨៩ គ្រឿង។ អង្គការកាកបាទក្រហមអន្តរជាតិក៏បានបង្កើតវគ្គរំលឹកឡើងវិញសំរាប់អ្នកបច្ចេកទេសខាងអវៈយវៈសិប្បនិមិត្ត និងអ័រតូមកពី CT និង VI ។[151]

រោងចក្រផលិតជើងសិប្បនិម្មិតរណប (Othopedic Component Factory) របស់អង្គការកាកបាទក្រហមអន្តរជាតិនៅក្នុងទីក្រុងភ្នំពេញ បានបន្តផ្តល់ជំនួយសំភារៈរណបអវៈយវៈសិប្បនិមិត្តដោយឥតគិតថ្លៃ ទៅដល់មជ្ឈមណ្ឌលស្តារនៅទូទាំងប្រទេស។ គ្រឿងសំភារៈរណបទាំងនោះរួមមាន ជើង ដៃ ក្បាលជង្គង់ ប្រព័ន្ធរណប(អ័រតូ) សន្លាក់កែងដៃ ស្នងជើង និងឈើច្រត់។ នៅឆ្នាំ២០០៤ រោងចក្រនេះបានផលិតអវៈយវៈសិប្បនិមិត្តសំរាប់ការកែច្នៃរូបកាយចំនួន ១២,៣៣០ និងសំភារៈសំរាប់ជំនួយការដើរចំនួនជាង ៨,០០០។[152]

អង្គការកាកបាទក្រហមអាមេរិកកាំង (Amcrican Red Cross:ARC) បានផ្តល់ការព្យាបាលដោយចលនា ឧបករណ៏អវៈយវៈសិប្បនិមិត្ត និង គ្រឿងរណប(អ័រតូ) ឈើច្រត់ និង រទេះជនពិការជាច្រើន សំរាប់អ្នករស់រានមានជីវិតពីគ្រាប់មីន និងជនពិការដទៃៗទៀត នៅមជ្ឈមណ្ឌលស្តារយុវនីតិសម្បទានៅខេត្ត កំពង់ស្ពឺ រហូតដល់ខែ ធ្នូ ឆ្នាំ២០០៤ ។ អង្គការ កាកបាទក្រហមអាមេរិកកាំង ក៏បានផ្តល់ការ បណ្តុះបណ្តាល ដល់បុគ្គលិកកម្ពុជា និងបានផ្តល់សេវាកម្មចុះតាមភូមិទៅដល់ប្រជាជននៅតាមតំបន់ដាច់ស្រយាលផងដែរ។ នៅឆ្នាំ ២០០៤ អង្គការកាកបាទក្រហមអាមេរិកកាំងបានផ្តល់អវៈយវៈសិប្បនិមិត្តចំនួន៥៤១និងរទេះជនពិការចំនួន៨១គ្រឿង។ ប្រជាជនជិត ៤០% ដែលទទួលបានសេវាកម្មស្តារយុវនីតិសម្បទា នៅមជ្ឈមណ្ឌលនេះជាប្រជាជនដែលរស់រានមានជីវិតពីគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ។[153] នៅខែ មករា ឆ្នាំ ២០០៥ អង្គការកាកបាទក្រហមអន្តរជាតិទទួលខុសត្រូវចំពោះមជ្ឈមណ្ឌលស្តារយុវនីតិសម្បទានៅ ខេត្តកំពង់ស្ពឺ បន្ទាប់ពីបានជួសជុលកែលំអឡើងវិញរួចរាល់នៅចុងឆ្នាំ ២០០៤ ។[154]

អង្គការ Cambodia Trust (CT) បានឧបត្ថម្ភគាំទ្រដល់បណ្តាសេវាកម្មស្តារយុវនីតិផ្នែករាងកាយនៅមជ្ឈមណ្ឌលជាច្រើន ដូចជានៅក្នុងទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និង នៅខេត្តកំពង់ឆ្នាំងដោយផ្តល់សេវាកម្មព្យាបាលដោយចលនា ដោយផលិត និងចែកជូនអវៈយវៈសិម្បនិមិត្ត និងគ្រឿងមេកានិកសំរាប់អវៈយវៈ

---

151 ICRC Special Report, "Mine Action 2004," Geneva, July 2005, p. 25; ICRC Physical Rehabilitation Program, "Annual Report 2004," Geneva, June 2005, p. 44.

152 ICRC Special Report, "Mine Action 2004," Geneva, July 2005, p. 25; ICRC Physical Rehabilitation Program, "Annual Report 2004," Geneva, June 2005, p. 25.

153 "Physical Rehabilitation Center Statistics Report 2004," May 2005, compiled by Edith van Wijngaarden, HI Cambodia; see also *Landmine Monitor Report 2004*, p. 267.

154 ICRC Special Report, "Mine Action 2004," Geneva, June 2005, p. 25; ICRC Physical Rehabilitation Program, "Annual Report 2004," Geneva, July 2005, p. 25.

សិប្បនិមិត្តនិងដោយចែកជូនរទេះជនពិការជាច្រើនគ្រឿងផងដែរ។ នៅឆ្នាំ២004 មជ្ឈមណ្ឌលទាំងនេះបានផ្តល់ជំនួយដល់ប្រជាជនចំនួន ៦,០៣១ នាក់ ដែលជិត ៤០% ជា អ្នករស់រានមានជីវិតពីគ្រាប់មីន បានផលិតអវៈយវៈសិប្បនិមិត្តចំនួន៧៧៤គ្រឿង និងចែកជូនរទេះជនពិការចំនួន ១៩៤ គ្រឿង និង រទេះកង់បី១គ្រឿង។ អង្គការ CT បានធ្វើប្រតិបត្តិការលើកម្មវិធីចុះតាមភូមិទៅដល់ជនពិការជាច្រើននៅតាមតំបន់ដាច់ស្រយាលដោយផ្តល់ការណែនាំអោយគេទៅរកសេវាកម្មវះកាត់ និង វេជ្ជសាស្ត្រ ការស្តាយុវនីតិសម្បទា ដែលមានមូលដ្ឋាននៅតាមសហគមន៍ និង ដោយលើកកំពស់ការយល់ដឹងពីបញ្ហាពិការភាព។ អង្គការ CT ក៏បានចាត់ចែងរៀបចំគំរោងបណ្តុះបណ្តាលតាមភូមិអោយដល់ប្រជាជន ដើម្បីសំរួលអោយគេទទួលបាន ការបណ្តុះបណ្តាលការអប់រំ ឱកាសបំរើការងារ និង បានផ្តល់ឥណទានឥតសំណងបន្តិចបន្តួច និង លទ្ធភាពអាចទទួលបានកម្មវិធីឥណទាន កំរិតមីក្រូ ដើម្បីប្រកបអាជីវកម្មជាលក្ខណៈគ្រួសារ។ [155]

មជ្ឈមណ្ឌលស្តាររបស់អង្គការ CT នៅក្នុងទីក្រុងភ្នំពេញក៏ជាគ្លីនិកណែនាំដល់សាលា Cambodia School of Prostheties and Orthoties (CSPO) ដើម្បីផ្តល់ការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រ ខាងផ្នែកធ្វើអវៈយវៈសិប្បនិមិត្ត និង អ័រតូសំរាប់ប្រទេសកម្ពុជា និងក្នុងតំបន់។ ជារៀងរាល់ឆ្នាំមានសិស្ស ១២នាក់ត្រូវ បានបណ្តុះបណ្តាលក្នុងរយៈពេល៣ឆ្នាំដែលមកពីបណ្តាប្រទេសផ្សេងៗដូចជាប្រទេសអាហ្វហ្គានីស្ថាន ទីម័រខាងកើត, ឡាវ, មីយ៉ាន់ម៉ា(ភូមា), ហ្វីលីពីន, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី, ចចជៀរ និងប្រទេសស្រីលង្កា។ សាលា CSPO គឺជាមជ្ឈមណ្ឌលមួយក្នុងចំណោមមជ្ឈមណ្ឌលហ្វឹកហ្វឺន Category II ដែលមានចំនួនតែ៤គត់នៅលើពិភពលោក។[156]

អង្គការ Handicap International (HI) មានដំណើរការកម្មវិធីជាច្រើនស្តីពីការស្តារ, ការធ្វើសមាហរណកម្មជនពិការទៅក្នុងសេដ្ឋកិច្ចសង្គមឡើងវិញ, ការប្រមូលទិន្នន័យ, ការកសាងសមត្ថភាព និង ការលើកកំពស់ការយល់ដឹងពីសិទ្ធិនិងសេចក្តីត្រូវការរបស់ជនពិការ។ នៅឆ្នាំ២004 អង្គការ HI បានឧបត្ថម្ភគាំទ្រមជ្ឈមណ្ឌលស្តារយុវនីតិសម្បទាជាច្រើននៅក្នុងខេត្តកំពង់ចាម, សៀមរាប, តាកែវ, និងកំពង់ធំ (រហូតដល់ ខែ មិថុនា ឆ្នាំ ២00៤) ដោយផ្តល់សេវាព្យាបាលដោយចលនា, ផ្តល់អវៈយវៈសិប្បនិមិត្ត និង ឧបករណ៍ជំនួយសង្គ្រោះដទៃទៀត។ កម្មវិធីចុះតាមភូមិ, ការហ្វឹកហ្វឺនការងារដល់អ្នកព្យាបាលដោយចលនានិងអ្នកបច្ចេកទេស។ នៅឆ្នាំ ២00៤ អង្គការ HI បានជួយដល់ប្រជាជនពិការជាង ៥,៣៦៥នាក់ និង ដល់មជ្ឈមណ្ឌលទាំងឡាយដែល

[155] "Physical Rehabilitation Center Statistics Report 2004," May 2005, compiled by Edith van Wijngaarden, HI Cambodia; response to Landmine Monitor Questionnaire by Pith Sokra, Administration Manager, CT, 27 March 2005; see also *Landmine Monitor Report 2004*, p. 267; Standing Tall Australia and Mines Action Canada, "101 Great Ideas for the Socio-Economic Reintegration of Mine Survivors," June 2005, p. 25.

[156] See *Landmine Monitor Report 2004*, p. 268; see also "The Cambodia Trust: Prosthetics & Orthotics Training," available at www.cambodiatrust.com/training.htm (accessed 31 July 2005).

គាំទ្រឧបត្ថម្ភដោយអង្គការ HI ផលិតអវៈយវៈសិប្បនិមិត្តចំនួន ១,០៥០ និងចែកជូនឈើច្រត់ចំនួន ៩៨៧, រទេះជនពិការចំនួន ២២៤ គ្រឿង និង រទេះកង់បីរវៃចំនួន ១២៦គ្រឿង។ កម្មវិធីស្តារយុវនីតិសម្បទាមានមូលដ្ឋាននៅតាមសហគមន៍របស់អង្គការ HI ផ្តោតយកចិត្តទុកដាក់ទៅលើ បន្តគាំទ្រផ្នែកវេជ្ជសាស្ត្រ ការឧបត្ថម្ភផ្នែកចិត្តសាស្ត្រសង្គម ការកាត់ន័យភាពក្រីក្រ និង ការធ្វើសមា ហរណកម្មសេដ្ឋកិច្ចជាថ្មីទៅលើជនពិការតាមរយៈក្រុមជួយខ្លួនឯង ការតំរង់ទិសដៅទៅរកកម្មវិធីបណ្តុះបណ្តាល និងក្រុមជំនួយឥណទានតូចតាច។ អង្គការ HI ក៏បានគាំទ្រក្លឹបកីឡា២ក្រុមសំរាប់ជនពិការនៅខេត្តបាត់ដំបង និង សៀមរាប ហើយបានឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារយុវនីតិសម្បទា Para- Tetra ដែល គ្រប់គ្រងដោយរាជរដ្ឋាភិបាល, គាំទ្រអង្គភាពស្តារយុវនីតិសម្បទា ផ្នែកខួរឆ្អឹងនិងរបួសសរសៃពួរនៅក្នុង ខេត្តបាត់ដំបង ។[157]

អង្គការ Veterans International(VI) បានដំណើរការនូវមជ្ឈមណ្ឌលស្តារយុវនីតិសម្បទាចំនួន៣កន្លែង រួមមានមជ្ឈមណ្ឌលស្តារយុវនីតិសម្បទាជាតិនៅកៀន ឃ្លាំង ក្នុងទីក្រុងភ្នំពេញ មជ្ឈមណ្ឌលនៅតាមបណ្តាខេត្ត ដូចជា ខេត្តក្រចេះ និង ខេត្តព្រៃវែង និង មជ្ឈមណ្ឌលតូចមួយនៅក្នុងខេត្ត ព្រះវិហារ ដែលបានបិទទ្វារឈប់ដំណើរការនៅក្នុងខែ តុលា ឆ្នាំ ២០០៤។ មជ្ឈមណ្ឌលទាំងនេះ បានផ្តល់សេវាកម្មព្យាបាលដោយចលនា ផលិតកម្ម និងការផ្តល់ឧបករណ៍អវៈយវៈសិប្បនិមិត្ត និងអ័រតូ និង រទេះជនពិការ និង ឧបករណ៍ជួយសង្គ្រោះជាច្រើនផ្សេងៗទៀតកម្មវិធីនេះរួមមានការស្តារនៅតាមសហគមន៍ ក្រុមចុះជួយតាមភូមិ និងការណែនាំទៅរកសេវាកម្មផ្សេងៗទៀត។ នៅឆ្នាំ ២០០៤ អង្គការ VI បានជួយដល់ ប្រជាជនចំនួន ២,០០១ នាក់ រួមមានអ្នករស់រានមានជីវិតពីគ្រាប់មីនចំនួន ៩៩៣នាក់ ផលិតអវៈយវៈ សិប្បនិមិត្ត ៧៤៧ និងរទេះជនពិការចំនួន ៣៣២គ្រឿង និងបានចែកជូននូវរទេះកង់បីរវៃចំនួន ៤៧គ្រឿង។[158] នៅក្នុងខែ មីនា ឆ្នាំ ២០០៤ អង្គការ VI បានផ្លាស់អង្គភាពធ្វើរទេះជនពិការទៅកាន់ឧទ្យាន ពាណិជ្ជកម្មក្នុងគោលបំណងផ្លាស់ប្តូរការធ្វើ រទេះជនពិការនេះទៅជាវិស័យឯកជនវិញ នៅក្នុងរយៈពេល ២ឆ្នាំខាងមុខនេះ។ អង្គការ VI បានឧបត្ថម្ភគាំទ្រដល់រោងជាងត្បាញសូត្រមួយកន្លែងក្នុងខេត្តព្រះវិហារ ដែលមានស្ត្រីពិការមួយចំនួនបំរើការនៅទីនោះ។ អង្គការ VI ក៏បានឧបត្ថម្ភដល់គំរោងក្រុមកីឡាបាល់ទះ (The Sport for Life) ដែលបច្ចុប្បន្ននេះ កំពុងធ្វើប្រតិបត្តិការជាមួយអង្គការ ក្រៅរដ្ឋាភិបាលក្នុងស្រុក ដោយគាំទ្រមូលនិធិខ្លួនឯង។[159]

---

[157] "Physical Rehabilitation Center Statistics Report 2004," May 2005, compiled by Edith van Wijngaarden, HI Cambodia; response to Landmine Monitor Questionnaire by Bruno Leclercq, Country Director, HI Cambodia, 1 May 2005; HI, "Quarterly Financial and Narrative Report: 1 October-31 December 2004," Ref.30/12/04 Issue 4; see also Standing Tall Australia and Mines Action Canada, "101 Great Ideas for the Socio-Economic Reintegration of Mine Survivors," June 2005, pp. 31-33; *Landmine Monitor Report 2004*, p. 268.

[158] "Physical Rehabilitation Center Statistics Report 2004," May 2005, compiled by Edith van Wijngaarden, HI Cambodia; response to Landmine Monitor Questionnaire by Hing Chanrith, Country Representative, VI, 19 March 2005.

[159] See *Landmine Monitor Report 2004*, p. 268; see also Standing Tall Australia and Mines Action

សមាគមផ្តល់ជំនួយសង្គ្រោះ (AAR-Japan) របស់ប្រទេសជប៉ុន បានបើកដំណើរការសេវាកម្មធ្វើរទេះជនពិការ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ កៀនឃ្លាំងក្នុងក្រុងភ្នំពេញ។ មជ្ឈមណ្ឌលនេះបានផ្តល់នូវកម្មវិធីហ្វឹកហ្វឺនរយៈពេលមួយឆ្នាំសំរាប់ជនពិការមកពីទីក្រុងភ្នំពេញ និង បណ្តាខេត្តនានានៅជុំវិញចំនួន ៩ខេត្ត។ ការហ្វឹកហ្វឺនត្រូវបានគេផ្តល់អោយនូវអក្ខរកម្មជាមូលដ្ឋាន ការជួសជុលវិទ្យុ និងទូរទស្សន៍ ការ ជួសជុលម៉ូតូ និងដេរប៉ាក់។ នៅឆ្នាំ២០០៤ អង្គការ AAR-Japan បានផលិតនិងចែករទេះជូនដល់ជនពិការចំនួន ៣៣០គ្រឿង ដែលមានរទេះ៨សំរាប់អ្នករស់រានមានជីវិតពីគ្រាប់មីន និង មានប្រជាជន៥០នាក់ បានទទួលការហ្វឹកហ្វឺន ដែលមាន ១៨នាក់ ជាអ្នករស់រានមានជីវិតពីគ្រាប់មីន។[160]

អង្គការ Jesuit Service Cambodia (JS) បានផលិតរទេះជនពិការជាច្រើនដែលមានគោលដៅ និងលក្ខណៈពិសេសតាមតំបន់។ នៅឆ្នាំ២០០៤ រទេះជនពិការចំនួន ១,០៣០គ្រឿង និង រទេះកង់បីរវៃចំនួន ៥១គ្រឿងត្រូវបានគេផលិត។ រទេះជនពិការ និងរទេះកង់បីរវៃរបស់អង្គការ JS ជាច្រើនត្រូវបានចែកជូនដោយ ARC, ICRC, HI និងCT។ អង្គការ JS បានចែកជូនរទេះជនពិការចំនួន ២៤០គ្រឿង និងរទេះកង់បីរវៃចំនួន៤២គ្រឿងក្នុងឆ្នាំ២០០៤។ អង្គការ JS ក៏បានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅមជ្ឈមណ្ឌលបន្ទាយព្រាប ( Center of the Dove)។ នៅឆ្នាំ ២០០៤ សិស្សពិការចំនួន ១២៥នាក់ ដែលមាន ៤៥ នាក់ ជាអ្នករស់រានមានជីវិតពីគ្រាប់មីន បានទទួលវគ្គបណ្តុះបណ្តាលរយៈពេលមួយឆ្នាំជាច្រើនវគ្គ មានដូចជា ផ្នែកកសិកម្ម ចំលាក់ជាងឈើ ជួសជុលអគ្គិសនី ជួសជុលម៉ាស៊ីន ត្បាញ កាត់ដេរការរៀនអក្សរ។ អង្គការ JS ក៏បានធ្វើជាការមួយជនពិការចំនួន ២៣៦នាក់ នៅក្នុងខេត្តសៀមរាប នៅក្នុងភូមិចំនួន ១៧៨ ភូមិ នាស្រុករតនមណ្ឌល ខេត្តបាត់ដំបង ក្នុងស្រុកអូរជ្រៅនិងថ្មពួក ខេត្តបន្ទាយមានជ័យ, ១៣ភូមិនៅខេត្ត ឧត្តរមានជ័យ និងនៅក្នុងអតីតតំបន់ខ្មែរក្រហមនាខេត្តកណ្តាល។ ក្រុម Metta Karuna ដែលមានអ្នករស់រានមានជីវិតជាច្រើននោះ បានផ្តល់ការគាំទ្រខាងផ្នែកចិត្តសាស្ត្រសង្គមដល់អ្នកភូមិជាច្រើន និងបានជួយពួកគេក្នុងការធ្វើផែនការកម្មវិធី ដើម្បីសុខុមាលភាពរបស់ពួកគេ។ កម្មវិធីនេះរួមមានការផ្តល់លំនៅដ្ឋាន ទឹក អាហារបន្ទាន់ ជំនួយសាលាសំរាប់ក្មេងៗ និងការទទួលបានសេវាសុខភាព និង លទ្ធភាពចេញចូលទីផ្សារ តាមរយៈការធ្វើស្ពាន និង ផ្លូវថ្នល់ ។[161]

សេវាកម្មអភិវឌ្ឍន៍ផ្នែកពិការភាពនៅខេត្តពោធិសាត់ (DDSP) បានផ្តល់សេវាកម្មយុវនីតិសម្បទារ ដែលរួមមានការព្យាបាលដោយចលនារ ទេះជនពិការ និង សំភារៈជួយសង្គ្រោះផ្សេងៗ និង សេចក្តី ណែនាំទៅ

Canada, "101 Great Ideas for the Socio-Economic Reintegration of Mine Survivors," June 2005, p. 36.

160 Interview with Daisuke Sagiya, Country Representative, AAR Japan, Phnom Penh, 23 March 2005; response to Landmine Monitor Questionnaire by Daisuke Sagiya, Country Representative, AAR Japan, 8 March 2005.

161 "Jesuit Service Report," December 2004; email to Landmine Monitor (HI) from Denise Coghlan and Ny Nhar, Jesuit Service Cambodia, 11 August 2005; Landmine Monitor (HI) interview with Denise Coghlan and Ny Nhar, Jesuit Service Cambodia, Phnom Penh, 22 March 2005.

រកសេវាកម្មដទៃទៀត ក្នុងភូមិចំនួន ៦ នៅតំបន់ដាច់ស្រយាលក្នុងខេត្តពោធិសាត់។ អង្គការ DDSP ក៏បានផ្តល់នូវការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម បានសំរួលលទ្ធភាពដល់ការទទួលការអប់រំសំរាប់ក្មេងៗ និង ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងលើកកំពស់ការយល់ដឹងពីបញ្ហាពិការភាពផងដែរ។ នៅឆ្នាំ ២០០៤ វាបានផ្តល់ជំនួយដោយផ្ទាល់ដល់ប្រជាជនចំនួន ១១៣នាក់ ដែលមាន ៤៣ នាក់ ជាអ្នករស់រានមានជីវិតពីគ្រាប់មីន។ អង្គការ DDSP បានទទួលមូលនិធិពីមូលនិធិអភិវឌ្ឍន៏តាមសហគមន៏របស់ភ្នាក់ងារជំនួយប្រទេសអូស្ត្រាលី (AusAID), Christian Blind Mission, អង្គការ H I និង ពីម្ចាស់ជំនួយឯកជន។[162]

សមាគមព្រះពុទ្ធសាសនាខ្មែរ បានគាំទ្រដល់ក្រុមដែលងាយទទួលរងគ្រោះជាងគេ ដែលរួមមានជនពិការ ស្ត្រីមេម៉ាយ និង ក្មេងៗក្នុងបណ្តាខេត្តឧត្តរមានជ័យ និង បន្ទាយមានជ័យ ។ សមាគមនេះបានជួយដល់ប្រជាជនជាង១,០០០នាក់ក្នុងមួយឆ្នាំ ដែលមួយចំនួនជាអ្នករស់រានមានជីវិតពីមីនដោយជួយសំរបសំរួលដល់ពួកគេអោយមានលទ្ធភាពក្នុងការទទួលបាននូវសេវាស្តារផ្នែករាងកាយមានដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្លាស់ប្តូររវាងគ្នានិងគ្នានិងជំនួយសង្គ្រោះបន្ទាន់ពេលត្រូវការ។ ឥណទានខ្នាតតូច ក៏អាចរកបានដើម្បីយកទៅធ្វើអាជីវកម្មផងដែរ។[163]

កម្មវិធីអង្គការបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការខ្មែរដោយសង្គ្រាម (Cambodia War Ampatees Rehabilitation Society:CWAR) បានផ្តល់ដល់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់មីន និងជនពិការដទៃទៀតនូវការបណ្តុះបណ្តាលពីអាជីវកម្ម បង្កើតប្រាក់ចំណូល និងសេវាកម្មជាច្រើនទៀតរួមមាន ការជួសជុលកង់កាត់សក់ ការជួលម៉ាស៊ីនធុនតូច និងរថយន្ត ការជួសជុលសំភារៈបរិក្ខាអគ្គិសនីក្នុងលក្ខណៈគ្រួសារ ដេរប៉ាក់និងកាត់ដេរ អ៊ុតសក់ ជាងដែក កាថៃសួនតាមគ្រួសារនិងកសិកម្មតាមមូលដ្ឋាន។ អ្នករៀនចប់កម្មវិធីនេះត្រូវបានផ្តល់ថវិកា/សំភារៈដើម្បីបើកអាជីវកម្មសហគ្រាសក៏រិតមីក្រូផ្ទាល់ខ្លួន ដែលធ្វើអោយពួកគេសំរេចបានភាពឯករាជ្យ និង មានទំនុកចិត្តលើខ្លួនឯង។ នៅឆ្នាំ ២០០៤ មានបុរស និង ស្ត្រីពិការចំនួន ៨៤៣នាក់ បានទទួលផលពីកម្មវិធីនេះ ដែល ៦៣៨នាក់ជាអ្នករស់រានមានជីវិតពីគ្រោះថ្នាក់មីន។[164]

យោងតាមស្ថាប័នអាជ្ញាធរមីនកម្ពុជា,ក្រសួងសង្គមកិច្ចការងារនិងដៃគូអង្គការក្រៅរដ្ឋាភិបាលនានាបានគាំទ្រដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន៩កន្លែង ដែលជួយបណ្តុះបណ្តាលដល់ជនពិការជាច្រើននាក់។

[162] Response to Landmine Monitor Questionnaire by Steve Harknett, Advisor, DDSP, 28 June 2005; see also “101 Great Ideas for the Socio-Economic Reintegration of Mine Survivors,” June 2005, p. 30.
[163] Landmine Monitor (HI) interview with Tuy Sakoeun, Program Coordinator, KBA, Thmar Puok, 17 March 2005.
[164] Landmine Monitor (HI) interview with Dr. David G. Aston and Sam Oeurn Pok, Managing Directors, CWARS, Phnom Penh, 23 March 2005; see also “101 Great Ideas for the Socio-Economic Reintegration of Mine Survivors,” June 2005, pp. 27-28.

នៅឆ្នាំ២០០៤ មានជនពិការសរុបចំនួន ៩១៦នាក់ បានបញ្ចប់ការសិក្សាពីមជ្ឈមណ្ឌលទាំងនេះ។[165] ទីភ្នាក់ងារ និង អង្គការដទៃជាច្រើនទៀតបានកំនត់ទិសដៅលើកកំពស់ពីមីន តាមរយៈការបណ្ដុះបណ្ដាលមុខជំនាញនិងការធ្វើអាជីវកម្ម ឥណទានក៏រិតមីក្រូ និងការរកការងារអោយធ្វើដែលរួមមាន ដូចជា Angkor Association for the Disaled, Clear Path International Cambodian Volunteers for Community Development, Children Affected by Mine, Marynoll, National Center of Disabled Persons, Artisans Association of Cambodia, Business Advisory Council, Cambodian Demining Workshop Cambodian Handicraft Association for Landmine and Polio Disbled, RehabCraft Cambodia, Vireakpheap Komar Pailin,World Rehabilition Fund និង អង្គការ World Vision ។ អង្គការជាច្រើនបានរាយការណ៍ថាមានការខ្វះខាតមូលនិធិសំរាប់អនុវត្តកម្មវិធីទាំងនេះ។ [166]

ក្រុមប្រឹក្សាសកម្មភាពជនពិការ (Disability Action Council) បានចុះបញ្ជីអង្គការដទៃៗជាច្រើនទៀតដែលបានផ្ដល់ជំនួយដល់ប្រជាពលរដ្ឋដែលរស់រានមានជីវិតពីមីន និង ជនពិការជាច្រើនទៀតតាមរយៈក្រុមជួយខ្លួនឯងជាច្រើន ក្រុមជំនួយតាមសហគមន៏ ប្រព័ន្ធផ្ដល់ការប្រឹក្សា, ការអប់រំ ការផ្ដល់ឱវាទ ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និងកម្មវិធីចុះតាមសហគមន៏ភូមិ ដែលមានដូចជាអង្គការ Action for Disability and Development, American Friends Service Committee, Arrupe Center Battambang, Cambodian Disabled Peoples Association, Caritas Cambodia, Operation Enfants de Battambang, និង អង្គការ Social Service of Cambodia ។ [167]

មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនកំពុងនាំគ្នា "ឆ្ពោះទៅកាន់ការអភិវឌ្ឍន៏" ទៅជួយដល់អ្នករួចជីវិតពីមីនដែលតាមរយៈនេះអ្នករស់រានមានជីវិតពីមីន ត្រូវបានគេផ្ដល់ជំនួយរួមជាមួយនឹងសមាជិកជាច្រើននាក់របស់សហគមន៏។ គោលបំណងនេះគឺដើម្បីផ្ដល់ដីសំរាប់ការដាំដំនាំ ធ្វើផ្លូវថ្នល់ ស្ពាន អណ្ដូងទឹក សាលារៀន មន្ទីរពេទ្យ និង ជំនួយឥណទានបង្កើតប្រាក់ចំណូលមួយចំនួន បន្ទាប់ពីមានសកម្មភាពបោសសំអាតមីនរួចមក។ អង្គការដែលធ្វើការឆ្ពោះទៅធ្វើការសមាហរណកម្មនិងការអភិវឌ្ឍន៏រួមមានអង្គការ Care អង្គការ Aust care, អង្គការ World Vision, អង្គការ Lutheran World Federation និងអង្គការ JS ។

អ្នករស់រានមានជីវិតពីមីន២នាក់មកពីប្រទេសកម្ពុជា បានចូលរួមក្នុងសន្និសីទបូកសរុបការងារមីនលើកទី១ នៅក្នុងទីក្រុងណៃរ៉ូប៊ី ប្រទេសកេន្យា នាខែ វិច្ឆិកា ដល់ ខែ ធ្នូ ឆ្នាំ ២០០៤។

## ការអនុវត្តន៍ និងគោលនយោបាយជនពិការ

[165] CMAA, "Annual Report on Victim Assistance 2004," prepared by Kuon Pheng, Director of Victim Assistance Department, CMAA, 15 March 2005.

[166] *Landmine Monitor Report 2004*, pp. 269-270; see also "101 Great Ideas for the Socio-Economic Reintegration of Mine Survivors," June 2005, pp. 24, 26, 29, 35, 37-42.

[167] See *Landmine Monitor Report 2004*, pp. 269-270.

ប្រទេសកម្ពុជាមិនទាន់មានច្បាប់ដែលការពារដល់សិទ្ធិរបស់ជនពិការនៅឡើយទេ ទោះបីជាមានច្បាប់មួយត្រូវបានពង្រាងនៅឆ្នាំ ២០០០ ក៏ដោយ។[168] នៅឆ្នាំ ២០០៤ ក្រសួងសង្គមកិច្ចការងារ បានបង្កើតក្រុមការងារមួយ ដើម្បីធ្វើពង្រាងច្បាប់ស្តីពីសិទ្ធិជនពិការឡើងវិញ។ នៅខែ មករា ឆ្នាំ ២០០៥ ក្រុមប្រឹក្សាសកម្មភាពជនពិការ បានបញ្ជូនច្បាប់ពង្រាងស្តីពីសិទ្ធិជនពិការ (Draft Legislation on Rights of People with Disabilities) ដែលទើបបានត្រួតពិនិត្យសារជាថ្មីមួយទៅអោយក្រសួងសង្គមកិច្ចការងារ ដើម្បីធ្វើការពិចារណាបន្ថែមទៀត។ ច្បាប់ពង្រាងនេះមាន១៣ជំពូក និង៦៨មាត្រា។ ច្បាប់នេះគេបានដាក់ជូនជាផ្លូវការទៅកាន់ក្រុមប្រឹក្សារដ្ឋមន្ត្រីដើម្បីពិនិត្យបន្តមុនពេលបញ្ជូនទៅកាន់សភាជាតិ។[169]

ក្រុមប្រឹក្សាសកម្មភាពជនពិការ ជាអង្គការសំរបសំរួលទូទាំងប្រទេសពាក់កណ្តាលស្វ័យភាពមួយស្តីពីពិការភាពនិងស្តារយុវនីតិសម្បទា។ តួនាទីចំបងរបស់អង្គការនេះ គឺដើម្បីសំរបសំរួល និងផ្តួចផ្តើមសេវាកម្ម និងជំនួយទាំងឡាយសំរាប់ជួយជនពិការក្នុងប្រទេសកម្ពុជា។[170]

---

[168] See *Landmine Monitor Report 2004*, p. 272.

[169] CMAA, "Annual Report on Victim Assistance 2004," prepared by Kuon Pheng, Director of Victim Assistance Department, CMAA, 15 March 2005; email from Ngy San, Program Manager, DAC, 23 August 2005.

[170] Response by Ngy San, Program Manager, DAC, 18 April 2005; for more information see *Landmine Monitor Report 2004*, p. 272.